# អត្ថបទព្រះធម៌

## ភាគ១



ដោយ

ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**

ព.ស.២៥៥២ គ.ស.២០០៨

www.hoksavann.org

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ននន❋៚៚៚

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃ-កប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ** ជាបុត្រទី៣ក្នុងបណ្ដាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ យឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧប-សម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេ-អាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្ត្រជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិក-បឋមសិក្សា ពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើនឆ្នាំ។

---

នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master's degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យាល័យញូដេលលី្ល នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយសង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

# មាតិកាអត្ថបទ

- ប្រវត្តិរូបសង្ខេប ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**

១. លក្ខណៈនៃព្រះពុទ្ធ ១

២. ការត្រាស់ដឹងច្បាប់ហេតុផល ១០

៣. លក្ខណៈនៃព្រះធម៌របស់ព្រះពុទ្ធ ២០

៤. ការធ្វើសង្គាយនា ២៤

៥. ព្រះពោធិសត្វព្រះសិទ្ធត្ថផ្ចាញ់មារ ២៨

៦. ព្រះនាមព្រះពុទ្ធ"សម្មាសម្ពុទ្ធោ" ៣២

៧. សាសនាជាមួយវិទ្យាសាស្ត្រ ៣៤

៨. តើចាត់ព្រះពុទ្ធជាទស្សនវិទូ ត្រឹមត្រូវឬទេ? ៣៨

៩. មិនត្រូវជឿអាការៈ១០យ៉ាង ៤៣

១០. វត្ត និង ព្រះសង្ឃ ៤៧

១១. ប្រទេសកម្ពុជា និង ព្រះពុទ្ធសាសនា ៥២

១២. សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា ៥៦

១៣. ព្រះសង្ឃជាមួយសង្គមខ្មែរ ៦០

១៤. ព្រះពុទ្ធសាសនា និង វិបត្តិនយោបាយ ៦២

១៥. ព្រះពុទ្ធប្រោសមនុស្សសត្វ ៦៧

១៦. ព្រះពុទ្ធសាសនាពុំបង្ខំមនុស្សឱ្យជឿឡើយ ៧០

---

១៧. ព្រះពុទ្ធសាសនាមិនមែនជាគ្រឿងញៀន ៧១
១៨. លក្ខណៈព្រះសង្ឃខ្មែរ ៧៣
១៩. សម្មាទិដ្ឋិ និង មិច្ឆាទិដ្ឋិ ៧៧
២០. ប្រពៃណីខ្លះ តើព្រះសង្ឃគួរអនុវត្តបែបណា? ៨១
២១. អបីយ៍ជំនឿផ្សេងៗ នៅកម្ពុជា ៩៣
២២. ពាក្យឃោសនា សម្តេចជួនណាតដឹងជាតិ ៩៧
២៣. អង្គការមនុស្សធម៌ខ្លះបំផ្លាញវប្បធម៌ខ្មែរ ១០២
- នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព

# លក្ខណៈនៃព្រះពុទ្ធ

ព្រះពុទ្ធពុំមែនជាអាទិទេព ពុំមែនជាទូតរបស់អាទិទេព និងពុំមែនជាអ្នកបែងភាគពីព្រះ **អាទិទេព** ឡើយ *(The Buddha is neither a god nor a prophet nor the incarnation of god)* ។ ប៉ុន្តែព្រះអង្គមានជាតិជាមនុស្សជាន់ខ្ពស់ ដែលមានសេចក្ដីព្យាយាម ស្វែងរក **អរិយសច្ចធម៌** រហូតសម្រេចការត្រាស់ដឹងដល់ការរំដោះទុក្ខបានជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ (*but a supreme human being who, through his own effort, attained to Final Deliverance and perfect wisdom, and became the peerless teacher of gods and man*) ។ សេចក្ដីទុក្ខជាបញ្ហាដែលមនុស្សសត្វត្រូវដោះស្រាយ អ្វីដែលជាហេតុនាំឱ្យកើតទុក្ខ ធម្មជាតិអ្វីជាការរំលត់ទុក្ខនិង មធ្យោបាយបែបណាជាផ្លូវទៅកាន់ការរលត់ទុក្ខ។ បញ្ហាទាំងនេះ ព្រះពុទ្ធបានរកឃើញតាមការត្រាស់ដឹងរបស់ព្រះអង្គ។ ការត្រាស់ដឹងរបស់ព្រះអង្គពុំមែនដូចការរកឃើញរបស់មនុស្សធម្មតា ដូចជាការឃើញអ្វីមួយរបស់ក្រុមអ្នកវិទ្យាសាស្ត្រជាដើមឡើយ។ ក៏ខុសគ្នាពីការបញ្ចេញទស្សនៈរបស់ក្រុមអ្នកទស្សនវិទូបស្ចិមប្រទេសនិងបូព៌ាប្រទេស។ ការត្រាស់ដឹងរបស់ព្រះពុទ្ធជាលទ្ធផលចេញពីការអប់រំព្រះទ័យព្រះអង្គដ៏បរិសុទ្ធផុតចាកសេចក្ដីសៅហ្មងទាំងអស់តាមរយៈសមថៈ វិបស្សនា ចំណែកក្រុមវិទ្យាសាស្ត្រនិងក្រុមទស្សនវិទូពុំមានលក្ខណៈដូចព្រះពុទ្ធឡើយ។ ការរកឃើញអ្វីមួយរបស់ក្រុមវិទ្យាសាស្ត្រ

និងការបញ្ចេញទស្សនៈអ្វីមួយ ដែលហៅថា **ទស្សនវិជ្ជា** របស់ក្រុម **ទស្សនវិទូ** តាមរយៈសម្ភារៈយកមកពិសោធតាមការគិតត្រិះរិះ ពិចារណា ដែលជាគំនិតធម្មតារបស់មនុស្សបុថុជ្ជន ដែលមាន **លោភៈ ទោសៈ មោហៈ** ពុំអាចឃើញការពិតដល់ជម្រៅឡើយ។ មានទស្សនវិជ្ជាខ្លះត្រូវគេយកទៅអនុវត្តធ្វើឱ្យពិភពលោកវិនាសដូចជា ទ្រឹស្តីរបស់កាលម៉ាកមេទ្រឹស្តីកុម្មុយនិស្តជាដើម។ ដូច្នេះទស្សនវិទូទាំងនោះ ពុំឃើញការពិតទៅតាមការពិត ជាមាគ៌ានាំសង្គមមនុស្សទៅរកសុខសន្តិភាពឡើយ។ ចំណែកព្រះពុទ្ធវិញ ព្រះនាមថា **អរហំ** ព្រះអង្គមានព្រះទ័យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាងមានបញ្ញាមុតថ្លា ត្រាស់ដឹងនូវធម៌ពិតដែលហៅថា **អរិយសច្ច** មាន៤ប្រការ គឺ ទុក្ខសច្ច សេចក្តីទុក្ខរបស់មនុស្សសត្វ បានដល់ការកើតមានជាតិ។ សមុទយសច្ច ហេតុនាំឱ្យកើតទុក្ខ បានដល់អវិជ្ជាតណ្ហា សេចក្តីប្រាថ្នារបស់មនុស្សសត្វ។ និរោធសច្ចការរំលត់ទុក្ខ បានដល់ព្រះនិព្វាន។ មគ្គសច្ចផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ បានដល់មគ្គប្រកបដោយអង្គ៨។ ការត្រាស់ដឹងនូវអរិយសច្ច៤នេះហើយទើបព្រះនាមថា **សម្មាសម្ពុទ្ធោ** ប្រែថា ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ដែលជាធម៌ដឹកនាំមនុស្សសត្វឱ្យចេញចាកទុក្ខ។ មគ្គប្រកបដោយអង្គ៨នេះគឺ **សម្មាទិដ្ឋិ** ការយល់ត្រូវ **សម្មាសង្កប្បៈ** ការត្រិះរិះត្រូវ **សម្មាវាចា** វាចាត្រូវ **សម្មាកម្មន្តោ** ការងារត្រូវ **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ **សម្មាវាយាមោ** ការព្យាយាមត្រូវ **សម្មាសតិ** ការនឹករលឹកត្រូវ **សម្មាសមាធិ** ការតម្កល់ចិត្តត្រូវ។ ដោយ

សារព្រះពុទ្ធអង្គឃើញសច្ចធម៌៤ប្រការនេះ ដែលគ្មានតាបសឥសីណាសម័យពុទ្ធកាលឃើញមុនព្រះអង្គនេះហើយបានជាមានតាបសឥសីនិងមនុស្សគ្រប់ឋានៈចូលគោរពធម៌ព្រះអង្គ ទើបមានព្រះនាមមួយទៀតថា **សត្ថាទេវមនុស្សានំ** ប្រែថា ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ។ តាមន័យនេះ គេពុំអាចប្រៀបធៀបព្រះពុទ្ធជាព្រះអរិយៈ ដ៏បរិសុទ្ធមកជាមួយនឹងទស្សនវិទូក្នុងលោក ដែលមានចិត្តសៅហ្មង ប្រកបដោយអវិជ្ជាតណ្ហាបានឡើយ។ គេពុំត្រូវប្រើពាក្យថា ព្រះពុទ្ធក៏ជាទស្សនវិទូមួយព្រះអង្គដែរ ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាទស្សនវិជ្ជានោះឡើយ ព្រោះព្រះពុទ្ធបានកំចាត់បង់អវិជ្ជាតណ្ហា និងមិច្ឆាទិដ្ឋិការយល់ខុសហើយ។ ចំណែកទស្សនវិទូក្នុងលោកដែលបានបញ្ចេញទស្សនៈអ្វីមួយ ស្របទៅតាមសមត្ថភាពធម្មតារបស់ខ្លួន ពុំអាចឃើញការពិតថ្នាក់បរមត្ថវិជ្ជាកំចាត់បង់នូវការយល់ខុស ដូចជា ព្រះពុទ្ធបានឡើយ។ ប៉ុន្តែបើគេនៅតែទទូចចង់ប្រើពាក្យ ចាំបាច់គេត្រូវតែបញ្ចូលពាក្យ **ញាណ** មួយទៀតទៅជាញាណទស្សនវិទូ គឺព្រះអង្គជាញាណទស្សនវិទូប្រែថា ព្រះអង្គត្រាស់ដឹងដោយ **ញាណ** និង **ទស្សនៈ** គឺប្រាជ្ញាឃើញការពិត។ ក្រុមទស្សនវិទូក្នុងលោកមានមួយភាគមានទស្សនៈត្រូវជាលោកិយសច្ចបម្រើសេចក្តីសុខដល់សង្គមមនុស្សបានមួយផ្នែក។ ចំណែកទស្សនវិជ្ជាមួយផ្នែកទៀត បញ្ចេញទស្សនៈខុសធ្វើឱ្យសង្គមបង្កើតជម្លោះកាប់សម្លាប់គ្នា ដូចជាទ្រឹស្តី **ការលម៉ាក** ជនជាតិអាល្លឺម៉ង់ដែលលោក **ឡេនីន** ជនជាតិរុស្ស៊ីយកទៅអនុវត្តចេញជាកុម្មុយនិស្តជាដើម។ ចំណែកពាក្យប្រៀនប្រដៅរបស់

ព្រះពុទ្ធធ្វើឱ្យអ្នកប្រតិបត្តិតាមបានទទួលសុខសន្តិភាព តាំងពីបច្ចុប្បន្ននេះទៅ រហូតសម្រេចព្រះនិព្វានការរំលត់ទុក្ខ ។

សម័យទំនើបនេះវិទ្យាសាស្ត្រខាងវិជ្ជាពេទ្យបានចំរើនលូតលាស់យ៉ាង អស្ចារ្យទាំងបរិមាណនិងគុណភាព មានសម្ភារៈទំនើប និងបច្ចេកទេសដ៏ខ្ពស់ របស់វេជ្ជបណ្ឌិតក្នុងការព្យាបាលមនុស្សលោក ។ ប៉ុន្តែទោះបីវិជ្ជាពេទ្យបានចំ រើនលូតលាស់យ៉ាងនេះក៏ដោយ ក៏ពុំអាចព្យាបាលមនុស្សឱ្យផុតពីការចាស់ឈឺ ស្លាប់បានឡើយ ព្រោះការកើតចាស់ឈឺស្លាប់ជាច្បាប់ធម្មជាតិដែលគេពុំអាច កែប្រែបាន ។ មនុស្សខ្លះពេទ្យព្យាបាលឱ្យបាត់ឈឺ និងឱ្យផុតពីស្លាប់ គ្រាន់តែ ជាការពន្យាពេលនៃជំងឺនិងការស្លាប់ទៅថ្ងៃមុខប៉ុណ្ណោះ ។ បានសេចក្ដីថាមនុស្ស សត្វកើតមក ត្រូវតែស្លាប់ទៅវិញ ។ ដូច្នេះការកើតចាស់ឈឺស្លាប់ហួសពីសមត្ថ ភាពរបស់វិជ្ជាពេទ្យក្នុងផ្លូវអាណាចក្រដែលអាចកែប្រែបាន ។ ចំណែកព្រះពុទ្ធ ព្រះបរមគ្រូវិញ ព្រះអង្គមានសមត្ថភាពអាចធ្វើឱ្យមនុស្សសត្វចេញផុតពីការ កើតចាស់ឈឺស្លាប់ បើគេប្រតិបត្តិតាមធម៌របស់ព្រះអង្គឱ្យបានហ្មត់ចត់ គឺបាន សម្រេចព្រះនិព្វានជា **អមតធម៌** ប្រែថា ធម៌មិនស្លាប់ ។

ព្រះពុទ្ធសំដែងអំពីព្រះនិព្វានជាការរំលត់ទុក្ខ ដោយព្រះអង្គសំដែងក្នុងអរិយ សច្ចទីមួយ គឺទុក្ខសច្ច បានដល់ការមានជាតិប្រកបដោយខន្ធ៥គឺ **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** ដែលប្រព្រឹត្ត ទៅជា **អនិច្ចំ ទុក្ខំ** និង **អនត្តា** ។ ដូច្នេះបញ្ជាក់ថា សេចក្ដីទុក្ខកើតឡើងពីការមានជាតិ ។ កាលណាមានជាតិតែង បញ្ជូនទៅរកការចាស់ឈឺស្លាប់ ។ ចំណែកសាសនាដទៃក្រៅពីព្រះពុទ្ធសាសនា

និយាយតែស្ថានសួគ៌និងស្ថានព្រហ្ម។ គេនិយាយថា ស្ថានសួគ៌និងស្ថានព្រហ្មជាសេចក្តីសុខរបស់សាសនាទាំងនោះ។ បានសេចក្តីថា បើគេជឿព្រះ ស្មោះត្រង់នឹងព្រះនៃសាសនារបស់គេ ព្រះអង្គនឹងឱ្យទៅកើតក្នុងស្ថានសួគ៌និងស្ថានព្រហ្ម។ តាមព្រះពុទ្ធសាសនាពោលថា ស្ថានមនុស្ស ស្ថានសួគ៌ និងស្ថានព្រហ្ម ហៅថាភពបីតែវិលកើតវិលស្លាប់ក្នុងសង្សារវដ្ត។ ភពទាំងបីនេះ ប្រកបដោយសេចក្តីទុក្ខទោស ដែលព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើមបានច្រានចោលហើយបានសម្រេចព្រះនិព្វានលែងវិលស្លាប់វិលកើត។ ភពទាំងបីនេះមានសុខខ្លះហៅថា **អាមិសសុខ** គឺសុខដោយអាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅប៉ះគ្នា ក៏បានកើតជាវេទនាជាសុខជាទុក្ខ ហើយសុខបែបនេះជាសុខពុំទៀងទាត់ ទីបំផុតត្រូវរលាយបាត់ទៅវិញ ឧទាហរណ៍ សុខរបស់មនុស្សដូចអណ្តាតប៉ះរសជាតិអាហារដឹងរសជាតិឆ្ងាញ់ពិសារតែត្រង់អណ្តាត លុះលេបកន្លងផុតពីបំពង់កទៅការឆ្ងាញ់ពិសារនោះក៏បាត់ទៅ។ ស្ថានព្រហ្មនិងស្ថានទេវតាបានសុខជាងស្ថានមនុស្ស ប៉ុន្តែអស់បុណ្យ ក៏ត្រូវច្យុតប្រកបដោយអនិច្ចតាធម៌ដូចស្ថានមនុស្សដែរ។ ស្ថានឬភពទាំងបី កើតពីកម្មផលរបស់សត្វដែលបានកសាង ពុំមែនកើតឡើងពីព្រះជាម្ចាស់អង្គណាមួយកសាងឡើយ។

ពាក្យថា **ព្រះ** សំដៅយកបុគ្គលបែបណា? ពាក្យថា **ព្រះ** មកពីពាក្យថា **វរៈ** ប្រែថា ប្រសើរ ផ្លាស់ **វ** ជា **ព** ឯ **រ** ផ្លាស់ធ្វើជាជើងទៅជា **ព្រះ** ប្រែថាប្រសើរ។ ពាក្យ **ព្រះ** នេះសម្រាប់ដាក់ពីមុខនាមចំពោះបុគ្គលឬវត្ថុ ដែលមានគុណធម៌ឬប្រយោជន៍ ដូចពាក្យថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះមាតា

ព្រះបិតា ឬរហូតប្រើជាមួយធម្មជាតិដូចជាព្រះអាទិត្យ ព្រះចន្ទ ព្រះធរណីជាដើម។ម្យ៉ាងទៀត ពាក្យ **ព្រះ** នេះគេអាចប្រើតែម្នាក់ឯងសម្រាប់បុគ្គលដែលគេលើកតម្កើងថាជាកំពូលនៃលោកគ្មានបុគ្គលណាស្មើ ដូចជាព្រះពុទ្ធក្នុងព្រះពុទ្ធសាសនាដែលខ្មែរគោរពជាដើម។ សាសនាដទៃក្រៅពីព្រះពុទ្ធសាសនាតែងឱ្យតម្លៃខ្លួនឯងថា ព្រះពិតប្រាកដគឺព្រះបង្កើតលោក ចំណែកព្រះពុទ្ធមិនបង្កើតលោក គេថាពុំមែនជាព្រះពិតប្រាកដទេ គឺគ្រាន់តែជាគ្រូបង្រៀនប៉ុណ្ណោះ។ គេថាព្រះរបស់គេបង្កើតលោក ប៉ុន្តែគេពុំអាចរកភ័ស្តុតាងត្រង់ណាដែលបញ្ជាក់ថា ព្រះសាងលោក ឬបង្កើតលោកពិតប្រាកដមែន។ មួយទៀតគួរឱ្យស្តាយបើព្រះបង្កើតលោកពិតមែន គួរណាស់តែបង្កើតមនុស្សនិងវត្ថុល្អៗដើម្បីឱ្យបានសុខចំរើនដល់សង្គម ពុំគួរបង្កើតមនុស្សមានចិត្តអាក្រក់ ពុំគួរបង្កើតរន្ទះបាញ់ ភ្នំភ្លើងផ្ទុះ រញ្ជួយផែនដី ដូចពេលថ្មីៗនេះមានរញ្ជួយបាតសមុទ្រហៅថា Tsunami ធ្វើឱ្យមនុស្សជាងមួយសែននាក់ត្រូវស្លាប់របួសប្រាំសែននាក់ និងគ្មានជម្រកប្រាំលាន ហើយសំណង់ផ្សេងៗក៏ត្រូវវិនាស។ តើព្រឹត្តិការណ៍ទាំងអស់នេះ ព្រះបង្កើតពិតមែន ឬជាច្បាប់ធម្មជាតិ និងច្បាប់កម្មផលដូចវិទ្យាសាស្ត្រ និងព្រះពុទ្ធសាសនាពោលទេ។ ព្រហ្មញ្ញសាសនា ក៏ថាព្រះព្រហ្មបង្កើតលោក គ្រិស្តសាសនាក៏ថាព្រះអាទិទេព គឺព្រះយេហូវ៉ាបង្កើតលោក ឥស្លាមសាសនាក៏ថា ព្រះអាទិទេពគឺព្រះអាឡាបង្កើតលោក ហាក់ដូចជាចម្លងតាមគ្នា ព្រោះសាសនាព្រាហ្មណ៍កើតមុនសាសនាទាំងពីរ។ គេចង់ដឹងមួយទៀតថា តើអ្នកណាបង្កើតព្រះទាំងនោះ តើព្រះទាំងនោះមានមាតាបិតា

មានរូបរាងបែបណា ហើយនៅឯណា? ចំណែកព្រះពុទ្ធវិញ ព្រះអង្គជាជាតិមនុស្ស មានព្រះមាតាបិតា មានទីកន្លែងពិតប្រាកដ មានរយៈពេលស្វែងរកព្រះធម៌ បានត្រាស់ដឹងធម៌ បានសំដែងធម៌ប្រោសសត្វ មានពាក្យប្រៀនប្រដៅរបស់ព្រះអង្គមានភ័ស្តុតាងពិតប្រាកដ ដែលអ្នកប្រវត្តិសាស្ត្រទទួលស្គាល់។ ការឃើញសច្ចធម៌៤ គឺសេចក្តីទុក្ខហេតុដែលនាំឱ្យកើតទុក្ខការរំលត់ទុក្ខផ្លូវទៅកាន់ការរំលត់ទុក្ខ ទើបឈ្មោះថាព្រះអង្គត្រាស់ដឹង គឺត្រាស់ដឹងនូវធម៌ចេញចាកទុក្ខ ទើបមានព្រះនាមកើតឡើងជា **ពុទ្ធោ** ឬ **សម្មាសម្ពុទ្ធោ** ដែលភាសាខ្មែរថាព្រះពុទ្ធនេះឯង។ ព្រះនាមរបស់ព្រះពុទ្ធមួយបទទៀតថា **លោកវិទូ** ប្រែថា ព្រះអង្គត្រាស់ដឹងនូវលោក។ បានសេចក្តីថា លោកនិងរចនាសម្ព័ន្ធរបស់លោកកើតមានជាធម្មតា ពុំមែនព្រះអង្គបង្កើតឡើងទេ ព្រះអង្គគ្រាន់តែឃើញការពិតប៉ុណ្ណោះ។ លោកដែលព្រះអង្គត្រាស់ដឹង មានបីប្រការគឺ **សត្វ-លោក** បានដល់មនុស្សសត្វមានវិញ្ញាណទាំងអស់ ដែលអន្ទោលទៅមកស្លាប់កើតនៅភពណាជាតិណាស្របតាមអំពើរបស់ខ្លួន។ **សង្ខារលោក** សំដៅយកវត្ថុគ្មានវិញ្ញាណទាំងអស់ ដូចជាព្រះអាទិត្យ ព្រះចន្ទ ផែនដី ព្រៃភ្នំ បឹងទន្លេ សមុទ្រជាដើមកើតពីការផ្សំធាតុដោយខ្លួនឯង។ **ឱកាសលោក** បានដល់រចនាសម្ព័ន្ធនិងទំនាក់ទំនងរវាងវត្ថុធាតុទាំងនោះ។ ធម្មជាតិទាំងនោះគ្មានអ្នកណាបង្កើតទេ គឺកើតពីសង្ខារ គឺធាតុនិងធាតុជុំគ្នាកើតបានជាអ្វីមួយស្របតាមច្បាប់របស់ធម្មជាតិ ឧទាហរណ៍ តាមគីមីវិទ្យា $H_2+O=H_2O$ គឺអ៊ីត្រូសែន២បូកនឹងអុកស៊ីសែន១ កើតបានជាទឹកជាដើម។ ព្រះពុទ្ធសំដែងថា អ្វីទាំងអស់

កើតពីការផ្សំ(**សង្ខារ**)រវាងហេតុបច្ច័យដែលអ្នកវិទ្យាសាស្ត្រថា ការផ្សំបរមាណូធាតុល្អិតជាទីបំផុតកើតបានជាម៉ូលីគីលផ្សំគ្នាច្រើនទៀតទើបកើតបានជាអង្គធាតុ។ ដូច្នេះបញ្ជាក់ថា វត្ថុធាតុពុំមានតួខ្លួនវាពិតទេ វាកើតឡើងពីការផ្សំធាតុទឹកដីភ្លើងខ្យល់នេះឯង។ ដូចជាបេះដូងរបស់មនុស្សវាមានសាច់សម្រាប់ឱ្យមានចលនាកម្រើក បើវាខូចផ្នែកនោះ វាត្រូវឈប់ដើរ ទោះបីអាទិទេពបញ្ជាវាក៏វាឈប់ដើរដែរ ប៉ុន្តែបើសាច់ផ្នែកនោះនៅល្អ វាតែងដើរជាធម្មតា ទោះបីអាទិទេពមិនបញ្ជាក៏ដោយ។ ដូច្នេះព្រះពុទ្ធ ត្រាស់ដឹងនូវច្បាប់ធម្មជាតិហើយយកមកប្រកាសប្រាប់មនុស្សសត្វទាំងអស់គ្នា។ ព្រះអង្គគ្រាន់តែបង្ហាញផ្លូវឱ្យមនុស្សសត្វដើរដោយខ្លួនឯង ព្រះអង្គពុំទទួលបាបមនុស្សសត្វទេ ព្រោះសេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាចញុំាងអ្នកដទៃឱ្យបរិសុទ្ធឬសៅហ្មងបានឡើយ។ ក៏ដូចជាគ្រូបង្រៀនខំពន្យល់សិស្សនូវមុខវិជ្ជាណាមួយ បើសិស្សនោះពុំយកចិត្តទុកដាក់ស្តាប់ទេ គ្រូពុំអាចបញ្ជូនវិជ្ជានោះទៅក្នុងខួរក្បាលសិស្សបានឡើយ។ ព្រះពុទ្ធអង្គសំដែងអំពីបាបនិងបុណ្យ ប៉ុន្តែព្រះអង្គពុំសម្រេចថាឱ្យអ្នកនេះទទួលផលបាបឱ្យអ្នកនោះទទួលផលបុណ្យឡើយ។ គឺបាបបុណ្យឱ្យផលដោយខ្លួនឯងជាស្វ័យប្រវត្តិ អាងដោយពុទ្ធភាសិតថា កម្មផលបែងចែកសត្វឱ្យខ្ពង់ខ្ពស់និងថោកទាប។

សរុបសេចក្តីមក **ព្រះ** ពិតប្រាកដនោះ គឺបុគ្គលដែលរកឃើញ **អរិយសច្ចធម៌** ដែលជាមាគ៌ាដឹកនាំមនុស្សសត្វឱ្យចេញចាកទុក្ខពិតប្រាកដ គឺព្រះពុទ្ធក្នុងព្រះពុទ្ធសាសនានេះឯង។ ព្រះអង្គត្រាស់ដឹងដោយប្រើប្រដាប់ផ្លូវ គឺអរិយមគ្គ

ញ្ញាណដោយប្រាជ្ញាដ៏មុតថ្លា។ ព្រះអង្គជាបុគ្គលឈ្នះលោក ពុំវិលវល់ជាប់ជំពាក់វង្វេងក្នុងលោកឡើយ។ ដោយមានការអាណិតអាសូរមនុស្សសត្វដែលមានទុក្ខវិលកើតវិលស្លាប់ក្នុងសង្សារវដ្ដ ទើបព្រះអង្គសំដែងធម៌ប្រោសហាក់ដូចជាពន្លឺដែលបំភ្លឺក្នុងទីងងឹត។ មូលហេតុដែលនាំឱ្យកើតជាតិប្រកបដោយខន្ធ៥ មកពី **អវិជ្ជា តណ្ហា ឧបាទាន** និង **កម្ម**។ ការកើតឡើងនៃខន្ធ៥ មានរូបក្ខន្ធជាដើមជាតួទុក្ខ ព្រោះកាលណាមានជាតិ តែងតែបញ្ជូនទៅរកជរាព្យាធិនិងមរណៈ។

ដូច្នេះបើមានព្រះជាម្ចាស់អង្គណាបង្កើតខន្ធប្រាំ ដែលជាតួទុក្ខនេះ ចាត់ទុកជាមូលហេតុ បង្កើតទុក្ខដល់មនុស្សសត្វដូច **អវិជ្ជា តណ្ហា ឧបាទាន កម្ម** ដែរ។ ព្រះពុទ្ធសាសនាសំដែងថា សេចក្ដីទុក្ខទាំងអស់កើតមកពីការមានជាតិ គឺមានខន្ធប្រាំនេះឯង។ ដើម្បីកុំឱ្យមានជាតិជាតួទុក្ខ ត្រូវកំចាត់បង់ហេតុដែលនាំឱ្យកើតទុក្ខគឺ បំបាត់ **អវិជ្ជា តណ្ហា ឧបាទាន** និង**កម្ម**។

# ការត្រាស់ដឹងច្បាប់ហេតុផល

**ព្រះពុទ្ធជាម្ចាស់** បានត្រាស់ដឹងច្បាប់ហេតុផលដែលកើតឡើងក្នុងលោក គឺត្រាស់ដឹងពិតទៅតាមពិតបាលីថា **យថាភូតញ្ញាណទស្សនៈ** ប្រែថា ប្រាជ្ញាឃើញទៅតាមសភាពពិតដែលកើតឡើង។ ក្នុងពេលនេះ យើងសូមលើកយកតែហេតុផលមួយដែលទាក់ទងនឹងរូបរាងកាយនិងចិត្តគំនិតរបស់មនុស្សក្នុងព្រះធម៌ ដែលហៅថា **បដិច្ចសមុប្បាទធម៌** ។

ពាក្យថា **បដិច្ចសមុប្បាទធម៌** ប្រែថា ធម៌កើតឡើងព្រម ព្រោះអាស្រ័យហេតុ។ មានន័យដោយសង្ខេបគឺ របស់នេះមាន របស់នោះក៏មានដែរ **ឥទំ ហោតិ** របស់នេះកើតឡើង របស់នោះក៏កើតឡើងដែរ **ឥមស្សុប្បាទោ ឥទំ ឧបជ្ជតិ** របស់នេះរលត់ របស់នោះក៏រលត់ដែរ **ឥមស្ស និរោធោ ឥទំ និរុជ្ឈតិ** គឺផលមួយកើតឡើងព្រោះមានហេតុរបស់វា ហើយផលនោះធ្វើជាហេតុម្តងសម្រាប់បង្កើតផលមួយជាបន្តទៀត មានរហូតដល់១២ប្រការដូចជាវណ្ឌមណ្ឌលមួយផ្តក់ជាប់បន្តគ្នា ហៅថា **បដិច្ចសមុប្បាទធម៌** ។ ធម៌ទាំង១២ប្រការនោះគឺ **អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ជរាមរណៈ** ។ ធម៌១២ប្រការនេះហើយ ដែលហៅថា **វដ្តសង្សារ** ធ្វើឱ្យមនុស្សសត្វវិលកើតវិលស្លាប់។ មានវដ្តៈ៣គឺ **អវិជ្ជា តណ្ហា ឧបាទាន** ឈ្មោះថា **កិលេសវដ្តៈ**។ **កម្មភព** និង **សង្ខារ** ឈ្មោះថា **កម្មវដ្តៈ**។ **ឧបបត្តិភព**

**វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជរាមរណៈ** ឈ្មោះថា **វិបាកវដ្តៈ២** អ្វីដែលហៅថា **អវិជ្ជា?** គម្ពីរមជ្ឈិមនិកាយនិយាយថា ការមិនស្គាល់ទុក្ខ មិនស្គាល់កំណើតនៃទុក្ខ មិនស្គាល់ការរលត់ទុក្ខ មិនស្គាល់ផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយនេះហើយ ដែលតថាគតហៅថា **អវិជ្ជា** ។ ដូច្នេះអវិជ្ជាពុំមែនទឹកដីភ្លើងខ្យល់ទេ, **អវិជ្ជា** គឺចិត្តដែលពុំដឹងឬពុំស្គាល់នូវសច្ចធម៌នោះឯង។ កាលណាពុំដឹង នាំឱ្យមានសង្ខារ គឺចេតនាឬបំណងផ្លូវចិត្តឬក៏ចលនាផ្លូវគំនិតនៅក្នុងលោកដែលបង្កើតជាវិបាកវិញ្ញាណចាប់បដិសន្ធិបន្តទៅទៀត, ដែលជាហេតុនាំឱ្យមាននាមនិងរូប ឬចិត្តនិងរូបបានដល់ខន្ធ៥ (**រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ**) នេះឯង។ នាមនិងរូបជាហេតុនាំឱ្យមានអាយតនៈ៦គឺ **ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ** និង**មនោ**។ **អាយតនៈ**ខាងក្នុង៦នេះហើយដែលនាំឱ្យមាន **ផស្សៈ** គឺការទង្គិច**អាយតនៈ**៦ខាង ក្រៅគឺ **រូប សំឡេង ក្លិន រស សម្ផស្ស** និង**ធម្មៈ**។ **ធម្មៈ** បានដល់អ្វីទាំងអស់ដែលចិត្តនឹកគិត ឬទាញយកមកជាអារម្មណ៍ដែលហៅថា **ធម្មារម្មណ៍**។ **ផស្សៈ**នាំឱ្យមាន **វេទនា** គឺការទទួលអារម្មណ៍ជាសុខជាទុក្ខនិងជាឧបេក្ខា។ **វេទនា** នាំឱ្យមាន**តណ្ហា**គឺចំណង់។ **តណ្ហា** នាំឱ្យមាន **ឧបាទាន** គឺការប្រកាន់ខ្ជាប់។ **ឧបាទាន** នាំឱ្យមាន **ភព** គឺទីកើត។ **ភព** នាំឱ្យមាន**ជាតិ**កំណើតណាមួយក្នុងភពនោះ។ **ជាតិ**នាំឱ្យមាន**ជរា** និង**មរណៈ** គឺចាស់និងស្លាប់។ ឯសេចក្តី

សោកខ្សឹកខ្សួលទោមនស្សតូចចិត្តការចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតឡើង ព្រោះមានជាតិជាបច្ច័យ ។ ធម៌នេះ ព្រះសម្ពុទ្ធបានលើកយកមកពិចារណាភ្ជាប់ជាមួយរូបធម៌និងនាមធម៌ ដែលមានទំនាក់ទំនងរវាងហេតុ និងផលជាអនុ-លោមនិងបដិលោមគឺពិចារណាបណ្តោយនិងបញ្ច្រាស់ ទើបព្រះអង្គត្រាស់ដឹងនូវ **អរិសច្ចធម៌៤** ។ ដើម្បីងាយយល់អំពីសភាពនិងលក្ខណៈនៃរូបធម៌និងនាមធម៌នេះ គប្បីពិចារណានូវន័យភេទ៤ប្រការទើបអាចដឹងថារូបរាងកាយចិត្តគំនិតរបស់បុគ្គលមួយរូបៗ ពុំមែនជារបស់ខ្លួនពិតទេ គឺវាកើតឡើងដោយហេតុបច្ច័យហើយត្រូវរលត់ទៅវិញជាធម្មតា ពុំស្តាប់បង្គាប់បញ្ជាអ្នកណាឡើយ នេះជាច្បាប់ធម្មជាតិ ។

**ន័យភេទ៤ប្រការនោះគឺ**

**១.** **ឯកត្តន័យ** = **រូបធម៌** និង **នាមធម៌** (ខ្លួនយើងនេះ) ជាធម្មជាតិតែមួយនៅជាមួយគ្នា ។

**២.** **នានត្តន័យ** = រូបធម៌ មានលក្ខណៈទ្រុឌទ្រោមទៅវិនាសទៅ ឯនាមធម៌ជាធម្មជាតិចេះរេទៅ ចេះឱនទៅរកអារម្មណ៍ ។

**៣.** **អព្យាបារន័យ** = រូបធម៌និងនាមធម៌នេះពុំចេះខ្វល់ខ្វាយដល់គ្នានឹងគ្នាឡើយ គឺរូបពុំដឹងនាម១ពុំដឹងរូបថា ឱ្យមកអាស្រ័យនឹងខ្លួនឡើយ ។

**៤.** **ឯវំ ធម្មតាន័យ** = ទោះបីរូបនិងនាមពុំដឹងគ្នាក៏ដោយ បើរូបនាមនេះធ្វើបាបតែងបានផលបាបធ្វើបុណ្យតែងបានផលបុណ្យគ្រប់កាលទាំងបី គឺអតីតជាតិបច្ចុប្បន្នជាតិនិងអនាគតជាតិ ។ បាបបុណ្យនេះស្ថិតនៅក្នុង

មនោប្រៀបដូចជារឿងរ៉ាវដែលគេចុចទុកក្នុងកុំព្យូទ័រ(Computer) ទោះបីបុគ្គលចែកស្ថានទៅក៏បាបបុណ្យ ដែលគេបានធ្វើក្នុងជាតិនេះនឹងបន្តផលនៅក្នុងជាតិមុខទៀត។ ដើម្បីបញ្ជាក់ថាតើត្រូវបន្តការទទួលផលនៃបាបបុណ្យនេះរបៀបណា គប្បីពិនិត្យមើលចម្លើយក្នុងមិលិន្ទបញ្ហាថា ភ្លើងដែលឆេះពីក្បាលព្រលប់ដល់ពាក់កណ្តាលអធ្រាត្ររហូតដល់ភ្លឺពុំមែនជាភ្លើងដដែលទេ គឺជាភ្លើងថ្មីតែវាទាក់ទងមកភ្លើងចាស់ គឺភ្លើងដែលឆេះពីក្បាលព្រលប់ យ៉ាងណាមិញ បាបនិងបុណ្យដែលបុគ្គលបានសាងក្នុងរូបនិងនាមដែលកន្លងទៅហើយ វាត្រូវបន្តឱ្យផលក្នុងរូបនិងនាមមួយទៀត។ នេះពោលអំពីបុគ្គលបុថុជ្ជនទូទៅដែលនៅមាន **អវិជ្ជា តណ្ហា ឧបាទាន កម្ម** ជាហេតុជាបច្ច័យបន្តជាតិកំណើតតទៅទៀត វៀរលែងតែព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម លោកកាត់ផ្តាច់នូវហេតុបច្ច័យនេះហើយ ទើបលោកពុំបន្តជាតិកំណើតដែលជាតួទុក្ខតទៅទៀត លោកបរិនិព្វានជាបរមសុខ។ ព្រះពុទ្ធដីកាសំដែងថា **យំ អនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាមិនទៀងជាទុក្ខ របស់នោះជាអនត្តាគ្មានខ្លឹមសារមិនស្តាប់បង្គាប់បញ្ជា នេះជាន័យសេចក្តីតាមបរមត្ថអភិធម្មជាគម្ពីរដ៏មានជម្រៅរបស់ព្រះពុទ្ធសាសនា។

ជនជាតិខ្មែរ ធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់តាំងពីសម័យបុរាណ បានគោរពព្រះពុទ្ធសាសនាទុកជាមាគ៌ាប្រចាំជីវិតរបស់ខ្លួន ដោយពិចារណាឃើញថា ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅដ៏ត្រឹមត្រូវក្នុងការដឹកនាំខ្លួននិងសង្គមខ្មែរឱ្យបានសុខសាន្ត។ ដូចបានពោលមកហើយ របស់អ្វីមួយបានកើតឡើងសុទ្ធតែ

កើតឡើងពីហេតុបច្ច័យ គ្មានអ្វីមួយកើតឡើងប្រាសចាកហេតុបច្ច័យឡើយ។ ព្រះពុទ្ធសំដែងថា គ្រប់ធម្មជាតិទាំងអស់កើតឡើងដោយខ្លួនឯងតាមធម្មតារបស់លោកធាតុ ឬចក្រវាល ដូចជា ព្រះអាទិត្យ ព្រះចន្ទ ផែនដី ភ្នំ ទន្លេ សមុទ្រជាដើម គ្មានអ្នកណាបង្កើតទេ។ ឯរបស់មានវិញ្ញាណ ដូចមនុស្សសត្វ អន្ទោលស្លាប់កើតតាមអំពើរបស់ខ្លួន ពុំមែនព្រះជាម្ចាស់ណាចាត់ចែងទេ។ មួយទៀត ព្រះពុទ្ធពុំសំដែងត្រង់ណាដែលពុំអាចលើកយកភ័ស្តុតាងមកបញ្ជាក់ប្រាប់គេបាន ដូចព្រះអង្គពុំសំដែងថា ក្នុងលោកនេះ តើមនុស្សណាឈ្មោះអ្វីកើតមុនគេ។ ព្រះអង្គមានព្រះពុទ្ធដីកាដោយលើកយកឧទាហរណ៍មួយមកបញ្ជាក់ថា បើគេសួរថា កូនមាន់កើតមកពីណា មុខជាឆ្លើយថា កើតមកពីពងមាន់ ចុះពងមាន់កើតមកពីណា មុខជាឆ្លើយថា កើតមកពីមេមាន់ ចុះមេមាន់កើតមកពីណា មុខជាឆ្លើយដដែល១ កើតពីពងមាន់កូនមាន់ ពុំអាចកំណត់បានថា មាន់ណាកើតមុនគេដែលអាចយកភ័ស្តុតាងមកបញ្ជាក់ប្រាប់គេបានឡើយ។ ព្រះពុទ្ធបានបញ្ជាក់បន្ថែមទៀតថា ប្រៀបដូចកង់រទេះមួយដែលមានវង់មូលហើយគេបង្វិលឱ្យវិល គេពុំអាចកំណង់ថា ត្រង់ណាជាចំណុចដើមឡើយ។ ព្រះពុទ្ធសាសនាក៏គ្មានពាក្យប្រៀនប្រដៅថា មនុស្សដើមដែលកើតមុនគេធ្វើបាប វាមានបាបដល់មនុស្សក្រោយទៀតដែលមិនបានធ្វើបាបឡើយ។ នេះជាទ្រឹស្តីអយុត្តិធម៌ណាស់ព្រោះមនុស្សមុនមិនជឿព្រះ ព្រះអង្គឱ្យមានបាបឱ្យបាបដល់អ្នកកើតក្រោយទៀត។ តុលាការបច្ចុប្បន្ននេះ គេសម្រេចឱ្យមានទោសចំពោះមនុស្សណាដែលប្រព្រឹត្តខុស។ ពុំមែនមានន័យថា ឪពុកម្តាយប្រ

ព្រឹត្តខុសមានទោសតាមផ្លូវរដ្ឋ កូនដែលមិនបានប្រព្រឹត្តក៏ត្រូវមានទោសដូច្នេះឡើយ។ ព្រះពុទ្ធសាសនានិយាយថា អ្នកដែលធ្វើបាបត្រូវទទួលផលបាបដោយខ្លួនឯង។ ព្រះពុទ្ធសាសនាក៏គ្មានទ្រឹស្តីថា មនុស្សណាជឿព្រះអង្គ មានភក្តីភាពចំពោះព្រះអង្គ ព្រះអង្គសព្វព្រះទ័យឱ្យមនុស្សនោះកើតក្នុងស្ថានសួគ៌ ឯមនុស្សដែលមិនស្តាប់បង្គាប់ ព្រះអង្គដាក់បណ្តាសាមនុស្សនោះឱ្យទទួលទុក្ខទោសរហូតឱ្យធ្លាក់នរកយ៉ាងនេះឡើយ។ ព្រះពុទ្ធជាបុគ្គលបរិសុទ្ធផុតចាកការបៀតបៀនហើយ ព្រះអង្គពុំឱ្យមនុស្សកើតស្ថានសួគ៌និងចុះនរក ដោយសារមិនជឿព្រះអង្គឡើយ ប៉ុន្តែព្រះអង្គគ្រាន់តែបង្ហាញផ្លូវទៅកាន់ទីនោះប៉ុណ្ណោះ ទុកសិទ្ធិឱ្យមនុស្សសត្វសម្រេចចិត្តធ្វើដំណើរដោយខ្លួនឯង។ សូម្បីព្រះអង្គសំដែងធម៌ក៏គ្មានបង្ខំមនុស្សសត្វឱ្យជឿព្រះអង្គឡើយ ថែមទាំងព្រះអង្គរំលឹកថា មនុស្សមុននឹងជឿធម៌តថាគត ចូរអ្នកពិចារណាជាមុនសិន។ បរិស័ទគ្រប់សាសនាទាំងអស់ ពុំមែនប្រតិបត្តិបានត្រឹមត្រូវតាមឱវាទសាសនារបស់ខ្លួនទាំងអស់ឡើយ តែងលាយឡំដោយទំនៀមទម្លាប់ប្រពៃណីជាតិដែលមានជាច្រើនតំណមក។ យ៉ាងណាមិញ ជនជាតិខ្មែរពេលមានទុក្ខតែងបន់ស្រន់ឱ្យខ្លួនបានទុក្ខជាដើម ក៏ដូចជាព្រះសង្ឃសូត្រជូនពរពុទ្ធបរិស័ទ ជាការលើកទឹកចិត្តឱ្យមានកម្លាំងផ្លូវចិត្តតាមរបបសុជីវធម៌ ជាមួយនោះមានប្រទានឱវាទឱ្យគេប្រព្រឹត្តល្អ ដើម្បីឱ្យការជូនពរនោះមានប្រសិទ្ធភាពពុំមែនជាការខុសទេ។ មានសាសនាមួយនិយាយថា ព្រះរបស់គេបង្កើតលោក ឯព្រះពុំមានសាច់ឈាមរាងរៅអ្វីឡើយ គឺទ្រង់ជាព្រះវិញ្ញាណ។ ព្រះពុទ្ធសាសនាសំដែងថា វិញ្ញាណ

កើតមានព្រោះអាស្រ័យអាយតនៈខាងក្នុង៦គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនិងមនោប៉ះ (ផស្សៈ) នឹងអាយតនៈខាងក្រៅ៦គឺ រូប សម្លេង ក្លិន រស សម្ផស្សនិងធម្មៈ (**ធម្មារម្មណ៍**) ទើបកើតចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃាន-វិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ។ ដូច្នេះព្រះជារបស់អវិជ្ជមាន ទៅបង្កើតរបស់វិជ្ជមានតើមានការពិតឬទេ។ សាសនានោះនិយាយទៀតថា ព្រះបង្កើតអ្វីទាំងអស់ គ្មានវត្ថុនិងមនុស្សណា ដែលព្រះមិនបានបង្កើតនោះទេ ព្រះធ្វើអន្តរាគមន៍បញ្ហាមនុស្សលោកតាំងពីនយោបាយទៅរហូតទ្រង់អនុញ្ញាតឱ្យកើតខ្យល់ព្យុះភ្លើងភ្នំផ្ទុះជាដើម ដោយមនុស្សមិនស្តាប់បង្គាប់ទ្រង់ ទ្រង់ត្រូវតែដាក់បណ្តាសាដូច្នេះ។ អស្ចារ្យណាស់គ្រាន់តែគេមិនស្តាប់បង្គាប់មិនធ្វើតាម ទៅធ្វើបាបគេ នេះជាការរំលោភសិទ្ធិនៃជំនឿរបស់គេដែលផ្ទុយពីរបបប្រជាធិបតេយ្យនិងយុត្តិធម៌។ ចំពោះព្រះពុទ្ធនៃព្រះពុទ្ធសាសនាវិញ ព្រះអង្គមិនធ្វើទោសបុគ្គលណាឡើយ ទោះបីគេមិនជឿធម៌ទេសនារបស់ព្រះអង្គក៏ដោយ ដូចពួកនិគ្រន្ថមិនជឿហើយប្រឆាំងនឹងព្រះអង្គក៏មិនឃើញក្នុងពុទ្ធប្រវត្តិថា ព្រះអង្គតបទៅពួកនិគ្រន្ថទាំងនោះដោយហិង្សាបែបណាមួយឡើយ។ សាសនានោះនិយាយបន្តទៀតថា គ្មានអ្វីដែលព្រះបង្កើតឡើងដោយឥតប្រយោជន៍ឡើយ។ សូមសួរតែវត្ថុមួយថា ចុះពោះវៀនដុះខ្នែងព្រះបង្កើតឡើងដើម្បីអ្វី មនុស្សគ្រប់រូបមានពោះវៀនដុះខ្នែងបានសុខស្រួលនៅពេលដែលអាហារមិនទាន់ចូលទៅក្នុងពោះវៀននោះទេ ពេលដែលអាហារចូល ត្រូវឈឺចុកចាប់ បើមិនកាត់ចោលឱ្យបានឆាប់ទេ នឹងទទួលគ្រោះ

ថ្នាក់រហូតដល់ស្លាប់។ គេពោលថា ព្រះបង្កើតមនុស្សច្រើនធុន មានល្អ មានអាក្រក់ ដើម្បីដឹងល្អត្រូវមានអាក្រក់។ ក្នុងពាក្យនេះមានន័យថា គ្រាន់តែចង់ដឹងល្អ ទៅបង្កើតមនុស្សអាក្រក់ឱ្យពិភពលោកមានទុក្ខដោយមនុស្សអាក្រក់ដែលព្រះបង្កើតនេះបៀតបៀន។ អ្នកមានវិជ្ជាមានបញ្ញាគេយល់លក្ខណៈមនុស្ស ដោយមិនបាច់បង្កើតមនុស្សអាក្រក់ទើបដឹងមនុស្សល្អនោះទេ។ គេពោលថា មនុស្សពិការមានមនុស្សខ្វាក់ជាដើមពុំមែនកើតឡើងដោយបាបខ្លួនឯង ពុំមែនឪពុកម្ដាយតែបណ្ដាលឡើងពីព្រះជាម្ចាស់បណ្ដាលឱ្យពិការមានខ្វាក់ជាដើម ទើបព្រះអង្គព្យាបាលឱ្យជា ដោយព្រះសំដែងក្នុងខ្លួនមនុស្សខ្វាក់នោះ ដើម្បីសំដែងការលើកតម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់។ ពាក្យនេះមានន័យថា មនុស្សពិការមានខ្វាក់ជាដើម គឺព្រះធ្វើឱ្យខ្វាក់។ គ្រាន់តែចង់លើកតម្កើងព្រះ បែរទៅជាធ្វើទុក្ខទោសដល់មនុស្ស ធ្វើឱ្យគេឈឺ ហើយទៅព្យាបាល។ ឥឡូវនេះ មនុស្សពិការខ្វាក់ខ្វិនគថ្លង់ច្រើនណាស់ សូមព្រះយាងមកព្យាបាលផង ដើម្បីជួយសម្រាលគ្រូពេទ្យកុំឱ្យចំណាយថវិកាច្រើនពេក។ គេពោលថា មនុស្សមានទុក្ខដោយសារមានបាបខុសគ្នា តែផ្ទុយពីព្រះពុទ្ធសាសនាដែលពោលថា មនុស្សមានទុក្ខដោយសារមានខន្ធ៥ (**បញ្ចុប្បាទានក្ខន្ធាទុក្ខា**)។ តើពុទ្ធសាសនានិយាយការពិតឬទេ មនុស្សចាស់ឈឺស្លាប់ដោយមានការកើត គឺការកើតមានខន្ធ៥នេះឯង។ ឯ **សោកទុក្ខ បរិទេវទុក្ខ ទោមនស្សទុក្ខ ឧបាយស្សទុក្ខ** ជាដើម កើតមានព្រោះមានជាតិជាបច្ច័យ។ បើមនុស្សគ្មានបាបទៅចុះគ្រាន់តែបានសុខខ្លះក្នុងស្ថានមនុស្ស ប៉ុន្តែ

គេចពុំផុតពីជរាទុក្ខព្យាធិទុក្ខនិងមរណទុក្ខដែរ បើកើតក្នុងស្ថានសួគ៌អស់បុណ្យត្រូវច្យុត វិលស្លាប់វិលកើតក្នុងវដ្តសង្សារដដែល។ សាសនាដទៃថា មនុស្សបើបានទៅកើតក្នុងស្ថានសួគ៌ទៅរស់នៅជាមួយព្រះមានជីវិតរស់នៅរហូត។ តាមពិត ស្ថានមនុស្សស្ថានសួគ៌ស្ថានព្រហ្ម ជាភពបីស្ថិតនៅ ក្រោម **អនិច្ចំ ទុក្ខំ អនត្តា** ជាតួសង្ខតធម៌តែងវិលស្លាប់វិលកើត មានតែព្រះនិព្វានទេដែលចេញផុតពីសង្ខតធម៌ជា **អមតំ និព្វានំ** ប្រែថា និព្វានមិនស្លាប់។ គេនិយាយថាមានតែព្រះទេដែលអាចសង្គ្រោះមនុស្សឱ្យផុតពីបាប ពុំមែនដោយការប្រព្រឹត្តទេ គឺដោយការស្រឡាញ់មេត្តាពីព្រះដោយខ្លួនមានជំនឿទៅលើព្រះ។ ចំពោះព្រះពុទ្ធសាសនាវិញពោលថា សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាចញ៉ាំងអ្នកដទៃឱ្យបរិសុទ្ធនិងសៅហ្មងបានឡើយ។ ចិត្តជាធំ ជាប្រធានលើសកម្មភាពល្អអាក្រក់របស់មនុស្ស បើចង់ឱ្យចិត្តបរិសុទ្ធផុតចាកបាបត្រូវអប់រំចិត្តនេះ លះអំពើអាក្រក់គ្រប់យ៉ាងដោយខ្លួនឯងតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធសំដែងថា គ្មានឥទ្ធិពលខាងក្រៅណាមួយមកជួយឱ្យមនុស្សសត្វផុតទុក្ខឡើយ បើខ្លួនមិនប្រព្រឹត្តខ្លួនឯងទេ។ គេពោលថាវិទ្យាសាស្ត្រគ្រាន់តែពន្យល់នូវអ្វីៗដែលព្រះបង្កើតឡើងប៉ុណ្ណោះ។ អ្នកដែលពោលបែបនេះ តើបានឃើញព្រះលោកបង្កើតធម្មជាតិទាំងនោះដោយផ្ទាល់ខ្លួន ឬសំអាងលើអ្វីដែលអាចថាជាការពិតបាន ព្រោះមិនថាតែព្រះពុទ្ធសាសនាទេ ទោះបីក្រុមវិទ្យាសាស្ត្រក៏បានយល់ស្របគ្នាថា ការកើតឡើងនៃធម្មជាតិនិងរចនាសម្ព័ន្ធរបស់ធម្មជាតិ វាប្រព្រឹត្តទៅនឹងកើតឡើងដោយខ្លួនវា។ គេ

ពោលទៀតថា ពុទ្ធសាសនាថាពឹងខ្លួនឯង ចុះដូចមនុស្សហែលក្នុងសមុទ្រ បើមិនពឹងកប៉ាល់ឬទូកទេ នឹងត្រូវស្លាប់។ នៅតែខ្លួនពឹងខ្លួនដដែល ព្រោះអ្នកដែលគេជួយនោះដោយសារមនុស្សល្អដែលគួរឱ្យគេជួយ បើជាមនុស្សចោរប្រព្រឹត្តអំពើឧក្រិដ្ឋគេពុំមានសទ្ធាជួយទេ ហើយអ្នកនោះសុំឱ្យគេជួយផង។ ដូចគ្រូពន្យល់សិស្ស បើសិស្សនោះមិនជួយខ្លួនដោយខំប្រឹងស្តាប់ទេ ចំណេះវិជ្ជានោះពុំអាចចូលក្នុងខួរក្បាលសិស្សបានទេ។ ក៏ដូចជាពុទ្ធបរិស័ទចង់សម្រេចព្រះនិព្វាន ត្រូវប្រតិបត្តិខ្លួនឯង (**អត្តទីបោ**) តាមព្រះធម៌គឺសីលសមាធិបញ្ញា (**ធម្មទីបោ**) អ្វីដទៃទៀត ពុំមែនជាទីពឹងរបស់អ្នករាល់គ្នាឡើយ (**អនញ្ញសរណា**) នេះជាពុទ្ធភាសិត។

# លក្ខណៈនៃព្រះធម៌របស់ព្រះពុទ្ធ

គោលបំណងរបស់អ្នកបង្កើតឱ្យមានសាសនា តែងបំណងឱ្យបរិស័ទរបស់ខ្លួនបានសុខ ប៉ុន្តែមធ្យោបាយទៅរកបំណងនោះពិតជាមានលក្ខណៈផ្សេងគ្នា បើនិយាយពីភាពល្អមានបីថ្នាក់គឺ :

១- ល្អធម្មតា

២- ល្អដោយប្រៀបធៀបគ្នា

៣- ល្អបណ្តាច់ គឺល្អដាច់គេ ។

ចំពោះព្រះពុទ្ធសាសនា ធម៌វិន័យរបស់ព្រះអង្គដែលប្រៀនប្រដៅមនុស្សសត្វ ជាធម៌បរិសុទ្ធ ជាធម៌មិនបៀតបៀន ។ លក្ខណៈវិនិច្ឆ័យធម៌វិន័យ ៨ប្រការ តទៅនេះចាត់ជាធម៌វិន័យរបស់ព្រះពុទ្ធគឺ :

១- **វិរាគាយៈ** ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក

២- **វិសំយោគាយៈ** ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ

៣- **អបចយាយៈ** ប្រព្រឹត្តទៅដើម្បីមិនសន្សំកិលេស

៤- **អប្បិច្ឆតាយៈ** ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច

៥- **សន្តុដ្ឋិយា** ប្រព្រឹត្តទៅដើម្បីត្រេកអរវត្ថុតាមមានបាន

៦- **បវិវេកាយ** ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ

៧- **វិរិយារម្ភាយ** ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម

៨- **សុភរតាយ** ប្រព្រឹត្តទៅដើម្បីចិញ្ចឹមងាយ ។

ធមិទាំង៨នេះ គប្បីដឹងថាជាធម៌វិន័យរបស់ព្រះពុទ្ធ ។ ធមិផ្ទុយពីនេះ គប្បីដឹងថា មិនមែនជាធម៌វិន័យពាក្យប្រដៅរបស់ព្រះពុទ្ធឡើយ ។ លក្ខណៈវិនិច្ឆ័យជាធម៌វិន័យរបស់ព្រះពុទ្ធដែលប្រៀនប្រដៅមនុស្សសត្វ តើដូចពាក្យប្រៀនប្រដៅរបស់សាសនាណាមួយឬទេ ? ពិតជាពុំដូចឡើយ ។

ព្រះពុទ្ធមិនបង្ខំឱ្យគេជឿ គឺព្រះអង្គគោរពសិទ្ធិមនុស្សខាងជំនឿ ដោយព្រះអង្គបានប្រកាសជាមុនថា មុននឹងជឿធម៌វិន័យដែលតថាគតបានសំដែង អ្នកមានសិទ្ធិពេញទីក្នុងការពិចារណាឱ្យបានល្អិតល្អន់ និងពិសោធឱ្យយល់ច្បាស់ជាមុនសិន។ តើលក្ខណៈព្រះពុទ្ធបែបនេះ មានសាសនាណាមានលក្ខណៈដូចនេះឬទេ។ ផ្ទុយទៅវិញ មានសាសនាខ្លះយកអំណោយទៅឱ្យប្រជាជននៃប្រទេសក្រីក្រ ហើយបង្ខំឱ្យគេជឿសាសនារបស់ខ្លួន រហូតបង្ខំកូនក្មេងដែលជាវ័យមិនទាន់ចេះពិចារណាឱ្យជឿទៀតផង។ ចំពោះអំណោយទានខាងព្រះពុទ្ធសាសនាចំពោះជនណាម្នាក់ គឺធ្វើឡើងដើម្បីលះមច្ឆរិយៈ គឺសេចក្តីកំណាញ់ ដោយបូជាគុណក្តី ដោយសង្គហធម៌ក្តី ដោយចិត្តបរិសុទ្ធ គ្មានចង់បានអ្វីមកវិញឡើយ។ នេះបញ្ជាក់ថា មានជនជាតិនៃប្រទេសអ្នកមានកំពុងព្យាយាមបំបាត់វប្បធម៌នៃជនជាតិប្រទេសក្រីក្រ។ មានសាសនាខ្លះបង្រៀនមនុស្សមិនឱ្យបៀតបៀនគ្នាដែរ ប៉ុន្តែមានលក្ខណៈចង្អៀតដោយមានព្រំដែនដូចជាការរក្សាសីលរបស់ពួកនិគ្រន្ថហៅថា និគ្រន្ថឧបោសថ ដែលព្រះពុទ្ធមិនឱ្យរក្សាសីលតាមពួកនោះ ដូចវៀរចាកការសម្លាប់សត្វទិសខាងកើតចម្ងាយមួយយោជន៍ ឯសត្វទិសដទៃសម្លាប់បាន។ សាសនាខ្លះមិនឱ្យសម្លាប់

មនុស្សតែសត្វសម្លាប់បាន ព្រោះសត្វទាំងអស់នោះព្រះរបស់គេបង្កើតឡើង សម្រាប់ជាអាហារមនុស្ស។ មានសាសនាខ្លះបើកឱ្យសម្លាប់មនុស្ស បើមនុស្ស នោះជាសត្រូវរបស់សាសនាខ្លួន។ ចំពោះព្រះពុទ្ធសាសនាវិញ ហាមមិនឱ្យ សម្លាប់ជីវិតមនុស្សនិងសព្វសត្វទាំងអស់។ បានសេចក្តីថា ឱ្យតែគេមានជីវិត សញ្ញាចង់រស់នៅមិនចង់ស្លាប់មិនត្រូវសម្លាប់ឡើយ ត្រូវគោរពជីវិតមនុស្ស សត្វទាំងអស់សូម្បីតែសត្រូវរបស់ខ្លួនក៏ដោយ។ មួយទៀត គ្មានសត្វណាកើត មកសម្រាប់មនុស្សស៊ីឡើយ ប៉ុន្តែសត្វត្រូវតែចាញ់ ព្រោះពុំអាចទាមទារសិទ្ធិ របស់ខ្លួនបាន។ ចំណែកព្រះពុទ្ធសាសនាឱ្យគោរពរហូតដល់ជីវិតសត្វដូចជាមាន ចែងក្នុងសិក្ខាបទទី១ នៃសីល៥ គឺជាសីលធម៌គ្មានកំណត់ព្រំដែនជាសីលធម៌ ដ៏ខ្ពង់ខ្ពស់គ្មានរបបលទ្ធិសាសនាណាប្រៀបប្រដូចបានឡើយ។ ដូច្នេះហើយបាន ជានៅក្នុងឆ្នាំ២០០៦នេះ ប្រទេសកាន់សាសនាក្នុងពិភពលោកបានប្រគល់ឱ្យ ប្រទេសកម្ពុជារៀបចំបុណ្យវិសាខបូជានៅទីស្នាក់ការអង្គការសហប្រជាជាតិ ដែលបុណ្យនេះបានត្រូវអង្គការពិភពលោកអនុម័តឱ្យធ្វើនៅទីស្នាក់ការរបស់ ខ្លួនតាំងពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៩ ដែលចាត់ទុកជាបុណ្យអន្តរជាតិ ព្រោះគេ មើលឃើញថាព្រះពុទ្ធសាសនាជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្សត្រង់ធម៌ អហិង្សា ការមិនបៀតបៀន សូម្បីសត្វតិរច្ឆានក៏ព្រះអង្គមិនឱ្យបៀតបៀនដូចគ្នា។ ក្នុងធម្មគុណពោលថា **ស្វាក្ខាតោ** ប្រែថា ធម៌ គឺព្រះមានព្រះភាគសំដែងល្អ ហើយ ត្រឹមត្រូវហើយ ជានិយ្យានិកធម៌ជាធម៌ដឹកនាំសត្វឱ្យចេញចាកទុក្ខមាន ជាតិទុក្ខជាដើម **បច្ចត្តំ វេទិតព្វោ** ជាធម៌ គឺព្រះអរិយបុគ្គលគប្បីដឹងពិត

ឃើញពិតក្នុងចិត្តនៃខ្លួន។ ដូចបានពោលមកហើយបញ្ជាក់ថា ពាក្យប្រៀនប្រដៅរបស់សាសនាដទៃមានភាពល្អខ្លះ ប៉ុន្តែជាល្អធម្មតារបស់មនុស្សបុថុជ្ជន ល្អមានព្រំដែន ល្អមានលក្ខខណ្ឌ ល្អមានបំណងអ្វីមួយ ល្អពុំមានភាពបរិសុទ្ធ ។ ចំណែកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់វិញ មានភាពសុក្រិត មានភាពបរិសុទ្ធ អាចញុំាងអ្នកប្រតិបត្តិតាមឱ្យចេញចាកទុក្ខ ជាធម៌របស់ព្រះអរិយបុគ្គលនាំសត្វឱ្យរំលត់ទុក្ខ ពោលគឺព្រះនិព្វាន ឈប់វិលកើតវិលស្លាប់ ។ ឯសាសនាដទៃនិយាយថា នាំសត្វទៅស្ថានព្រហ្ម និងស្ថានសួគ៌ ដែលស្ថានទាំងនោះព្រះពុទ្ធសំដែងថា ស្ថិតក្នុងភពនៅវិលកើតវិលស្លាប់ទទួលទុក្ខវេទនាគ្មានទីបំផុតឡើយ ។

# ការធ្វើសង្គាយនា

ពាក្យថា **សង្គាយនា** ប្រែថា ការរួបរួមធម៌វិន័យទុកជាពួកជាក្រុម ដើម្បីឱ្យងាយស្រួលក្នុងការរៀនសូត្រ។ បន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅដោយខ្លាចធម៌វិន័យរបស់ព្រះអង្គបាត់បង់ ព្រះសង្ឃដែលជាព្រះអរហន្តបានរួមប្រជុំគ្នាជាមហាសន្និបាតចំនួន៥លើកក្នុងសម័យកាលផ្សេងៗគ្នាដើម្បីផ្ទៀងផ្ទាត់ធម៌វិន័យឱ្យបានត្រឹមត្រូវតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហៅថា ការធ្វើ **សង្គាយនា** ដែលមានព្រឹត្តិការណ៍តាមដំណើរសង្គាយនានីមួយៗដូចតទៅនេះ :

**១.** **<u>បឋមសង្គាយនា</u>** = សង្គាយនាលើកទី១ធ្វើក្នុងពេលដែលព្រះពុទ្ធបរិនិព្វានទៅបាន៣ខែ ដើម្បីរក្សាការពារធម៌វិន័យរបស់ព្រះពុទ្ធដោយលើកយកបញ្ហាភិក្ខុមួយអង្គនាម **សុភទ្ទៈ** បានពោលតិះដៀលធម៌វិន័យ។ ព្រះសង្ឃដែលមកប្រជុំមានចំនួន៥០០អង្គ ដែលមាន**ព្រះមហាកស្សបៈ**ជាអ្នកសួរ ព្រះ**ឧបាលី** ជាអ្នកឆ្លើយព្រះវិន័យ **ព្រះអានន្ទ** ជាអ្នកឆ្លើយព្រះសូត្រនិងព្រះអភិធម្ម។ ព្រះអរហន្តទាំងបីអង្គសួរឆ្លើយត្រូវគ្នាហើយទើបសួរបញ្ជាក់ទៅព្រះអរហន្ត **បដិសម្ភិទាញាណ** ជាសមាជិកអង្គប្រជុំទាំង៥០០អង្គឆ្លើយត្រូវគ្នាទៀតទើបចាត់ទុកជាបានការ។ **សង្គាយនា** នេះធ្វើនៅក្រុងរាជគ្រឹះមានព្រះបាទអជាសត្រូវជាសាសនូបត្ថម្ភក៍ ធ្វើអស់រយៈវេលា៧ខែទើបចប់។ ព្រះនាមព្រះមហាថេរទាំងបីអង្គ ដែលសួរឆ្លើយក្នុងសង្គាយនាលើកទី១នេះហើយដែល

អ្នកទេសនាគ្រៃបីសម័យក្រោយមកដល់សព្វថ្ងៃនេះ យកមកប្រើដាក់នាមរបស់ខ្លួនក្នុងពេលទេសនាគ្រៃបី ។

២. **<u>ទុតិយសង្គាយនា</u>** = សង្គាយនាលើកទី២ធ្វើនៅពេលព្រះពុទ្ធបរិនិព្វានបាន១០០ឆ្នាំ ដោយប្រារព្ធចំពោះ **ភិក្ខុវជ្ជីបុត្រ** ដោយបញ្ញត្តិប្រកាន់វត្ថុ១០ប្រការខុសធម៌វិន័យ ។ មានព្រះសង្ឃជាព្រះអរហន្ត បដិសម្ភិទាញាណជាសមាជិកប្រជុំចំនួន៧០០អង្គ ។ **ព្រះរេវតៈ** ជាអ្នកចោទសួរនូវវត្ថុ១០ប្រការ **ព្រះសព្វកាមី**ជាអ្នកឆ្លើយធ្វើនៅ**នគរវេសាលី** ព្រះបាទ**កាលាសោក**ជាសាសនូបត្ថម្ភក៏ធ្វើអស់រយៈពេល៨ខែទើបចប់ ។

៣. **<u>តតិយសង្គាយនា</u>** = សង្គាយនាលើកទី៣ធ្វើក្នុងពេលព្រះពុទ្ធបរិ-និព្វានទៅបាន២១៨ឆ្នាំ ។ ព្រះបាទធម្មាសោកបានសោយរាជ្យសម្បត្តិក្នុងសកលជម្ពូទ្វីប គឺប្រទេសឥណ្ឌាក្រុង**បាដលិបុត្រ** ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានញុំាងលាភសក្ការៈជាច្រើនដល់ព្រះសង្ឃ ពេលនោះពួកនិគ្រន្ថដែលមានការក្រលំបាកប្រាថ្នាលាភសក្ការៈ ក៏លបចូលបួសបន្លំជាច្រើន ហើយយកលទ្ធិរបស់ខ្លួនមកសំដែងថា ជាពុទ្ធសាសនាដែលធ្វើឱ្យព្រះពុទ្ធសាសនាមានមន្ទិលសៅហ្មង ។ គ្រានោះព្រះសង្ឃបែកគ្នា ខានធ្វើឧបោសថអស់៧ឆ្នាំ ទើបព្រះបាទធម្មាសោកជម្រះមន្ទិលទាំងនោះដោយប្រើអាមាត្យឱ្យចាប់ពួកនិគ្រន្ថផ្សឹកទាំងអស់ ទុកតែព្រះសង្ឃដែលបរិសុទ្ធ ។ បន្ទាប់មកផ្ដើមធ្វើសង្គាយនាលើកទី៣ ដោយ**ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ** ជាប្រធានមានព្រះ

អរហន្ត១០០០អង្គ ធ្វើក្នុង **អសោការាម** ក្រុង**បាដលិបុត្រ** មានព្រះបាទធម្មាសោកជាសាសនូបត្ថម្ភក៏ធ្វើអស់រយៈពេល៩ខែទើបចប់ ។

**៤.<u>ចតុត្ថសង្គាយនា</u>** = សង្គាយនាលើកទី៤ ធ្វើក្នុងពេលព្រះពុទ្ធបរិនិព្វានទៅបាន២៣៦ឆ្នាំ បំណងដើម្បីឱ្យព្រះពុទ្ធសាសនាតាំងនៅស៊ប់សួនក្នុងលង្កាទ្វីប ដោយ**ព្រះមោគ្គលិបុត្តតិស្សត្ថេរ** បានចាត់ឱ្យព្រះអរហន្តផ្សាយព្រះពុទ្ធសាសនានៅប្រទេសផ្សេងៗក្នុងបច្ចន្តប្រទេសជាពិសេស បានចាត់**ព្រះមហិន្ទត្ថេរ** ឱ្យផ្សាយពុទ្ធសាសនានៅលង្កាទ្វីបរហូតដល់ព្រះបាទទេវានម្បិយតិស្សៈនៃនគរនោះ មានសទ្ធាជ្រះថ្លាសុំ**ព្រះសង្ឃមិត្តាថេរី** ជាព្រះរាជធីតានៃព្រះបាទធម្មាសោកទីក្រុង**បាដលិបុត្តជម្ពូទ្វីប** មកបំបួសព្រះនាងអនុឡាជាព្រះអនុជទៀតផង។ ដើម្បីឱ្យព្រះពុទ្ធសាសនាចាក់ឫសនៅលង្កាទ្វីបក៏ចាប់ផ្តើមធ្វើសង្គាយនាដោយ **ព្រះមហិន្ទត្ថេរ** ជាអ្នកបុច្ឆា **ព្រះអរិដ្ឋត្ថេរ** ជាអ្នកវិស្សជ្ជនាមានព្រះសង្ឃ៦៨០០០អង្គធ្វើនៅ**ថូបារាម**ក្នុង**អនុរាធបុរី**ព្រះបាទ **ទេវានម្បិយតិស្សៈ** ជាសាសនូបត្ថម្ភក៏ធ្វើអស់វេលា១០ខែទើបចប់ ។

**៥.<u>បញ្ចមសង្គាយនា</u>** = សង្គាយនាលើកទី៥ប្រារព្ធចំពោះព្រះសង្ឃដែលបែកគ្នាជាពីរពួកគឺព្រះសង្ឃខាង**មហាវិហារ** និងព្រះសង្ឃខាង**អភយ-គីរីវិហារ** ធ្វើនៅលង្កាទ្វីបមានព្រះសង្ឃ១០០០អង្គមាន**ព្រះពុទ្ធទត្តត្ថេរ**ជាអ្នកសួរ **ព្រះតិស្សត្ថេរ**ជាអ្នកឆ្លើយ ព្រះបាទ**វដ្តគាមិនីអភ័យ**ក្សត្រក្រុង**លង្កាទ្វីប**ជាសាសនូបត្ថម្ភក៏ធ្វើអស់រយៈពេល១២ខែទើបចប់ ។ បន្ទាប់មកទើបចារឹកព្រះត្រៃបិដកជាតួអក្សរដាក់ក្នុងស្លឹករឹត ។ ដូច្នេះពុទ្ធវចនៈពាក្យ

ប្រៀនប្រដៅរបស់ព្រះពុទ្ធបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងសង្គាយនាលើកទី៥នេះឯង ដែលកាលមុនព្រះសង្ឃជាព្រះអរហន្តចេះចាំពុទ្ធវចនៈនៅក្នុងចិត្ត។

តមកអស់កាលជាច្រើនសតវត្សរ៍គ្មានឃើញធ្វើសង្គាយនាដើម្បីប្រារព្ធរឿងហេតុអ្វីឡើយ។ ទើបតែមកដល់សតវត្សរ៍ទី២០នៃគ.ស.ទើបមានធ្វើ **ឆដ្ឋសង្គាយនា** គឺសង្គាយនាលើកទី៦នៅក្រុងរង្គូនប្រទេសភូមា ដែលមានព្រះមហាសុមេធាធិបតីសង្ឃនាយក **ជួន-ណាត** និមន្តទៅជាតំណាងប្រទេសកម្ពុជានៅពេលនោះ។ ក្រៅពីនោះនៅថ្ងៃទី២៦ ខែឧសភា ដល់ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៥០ មានធ្វើសមាជសកលពុទ្ធសាសនានៅទីក្រុងកូឡុំបូប្រទេសស្រីលង្កា ដែលមានប្រទេសជាង៤០បានចូលរួម។ បន្ទាប់មក នៅថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៥២ មានធ្វើសមាជសកលពុទ្ធសាសនាម្តងទៀតនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដែលមានប្រទេសចំនួន៥០បានចូលរួមប្រជុំ។ ការប្រជុំព្រះពុទ្ធសាសនាទាំងពីរលើកនេះ ដើម្បីរកសន្តិភាពជូនសកលលោក។

# ព្រះពោធិសត្វព្រះសិទ្ធត្ថផ្ចាញ់មារ

មារដែលព្រះពោធិសត្វបានផ្ចាញ់មុនត្រាស់ដឹងនោះ មានពីរប្រភេទ គឺ មារក្តៅមួយ មារត្រជាក់មួយ។ មារក្តៅ តាមការនិទានក្នុងពុទ្ធប្រវត្តិថា បន្ទាប់ពីព្រះពោធិសត្វព្រះសិទ្ធត្ថបានសោយមធុបាយាសដែលនាងសុជាតា បានថ្វាយមក ព្រះអង្គបានពិចារណាឃើញនៅយប់នោះថា ព្រះអង្គពិតជាបាន ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោក។ បានជាព្រះអង្គហ៊ានសន្និដ្ឋានទុកជា មុនដូច្នេះ ព្រោះព្រះអង្គបានរកឃើញមាគ៌ាជាផ្លូវត្រាស់ដឹងនៅពេលនោះឯង។ ព្រះអង្គបានគត់ព្រះភ្នែនពែនព្រះបាទនៅក្រោមដើមពោធិព្រឹក្សតាំងព្រះទ័យ ប្រតិបត្តិតាម **សីល សមាធិ បញ្ញា** ដែលជាមគ្គប្រកបដោយអង្គ៨ជាផ្លូវ នៃការត្រាស់ដឹង។ ពេលនោះឯង មានពួកមារាធិរាជព្រមទាំងសេនាបានលើក ទ័ពច្រើនមីរដេរដាសស្ថិតនៅពីមុខ ពីក្រោយ ពីចំហៀង ខ្លះហោះហើរដើរលើ អាកាស ខ្លះជិះសត្វពាហនៈផ្សេងៗ ដែលមានដៃ កាន់ដាវ លំពែង ធ្នូស្នា បញ្ចេញឫទ្ធិរបស់ខ្លួនកក្រើកព្រះធរណី នាំគ្នាមកគំរាមកំហែងព្រះពោធិសត្វ ដែលកំពុងគង់ចំរើនធម៌យ៉ាងស្ងៀមស្ងាត់។ គោលបំណងនៃពួកមារដែលមក ច្បាំងនឹងព្រះពោធិសត្វពេលនោះ គឺមិនចង់ឱ្យព្រះពោធិសត្វត្រាស់ជាព្រះពុទ្ធ កន្លងវិស័យរបស់ខ្លួន ពុំមែនត្រឹមតែដណ្តើមបល្ល័ង្កដែលព្រះអង្គកំពុងគង់នោះ ទេ។ ឯព្រះពោធិសត្វបានផ្ចាញ់វិញដោយបារមីធម៌ ដែលព្រះអង្គបានកសាង ជាច្រើនជាតិមក ហើយបំណងត្រាស់ជាព្រះពុទ្ធដើម្បីចម្លងសត្វឱ្យបានសម្រេច

ព្រះនិព្វានជាការរំលត់ទុក្ខ។ ទីបំផុតពួកមារព្រមទាំងសេនាបានត្រូវបរាជ័យដោយបារមីរបស់ព្រះអង្គមានទានបារមីជាដើម។ បន្ទាប់ពីសង្គ្រាមក្តៅបានផុតរលត់ទៅពួកមារបានគិតថា នៅមានមធ្យោបាយមួយទៀតដើម្បីយកជ័យជំនះពីព្រះសិទ្ធត្ថពោធិសត្វ គឺសង្គ្រាមត្រជាក់។ មធ្យោបាយទីពីរនេះ គឺពួកមារបានបញ្ជូនបុត្រីរបស់ខ្លួន៣នាក់ ដែលមានរូបឆោមលោមពណ៌ដ៏ល្អឆើតឆាយលើសស្ត្រីក្នុងសួគ៌ា គឺនាងរាគី នាងអរតី និងនាងតណ្ហា ដោយមានគំនិតថាបើព្រះពោធិសត្វមានព្រះទ័យស្រឡាញ់ជាប់ចិត្តនឹងបុត្រីខ្លួនក្នុងផ្លូវកាមគុណគឺ រូប សម្លេង ក្លិន រស និង សម្ផស្ស នឹងមិនបានត្រាស់ជាព្រះពុទ្ធឡើយពេលនោះខ្លួនបានទទួលជ័យជំនះ។ បុត្រីទាំង៣របស់មារក៏បានបញ្ចេញជំនាញរបស់ខ្លួនដោយបច្ចេកទេសដ៏ខ្ពស់តាមការបង្ហាត់បង្រៀនរបស់បិតាខ្លួនដោយការរាំច្រៀងកាច់ក្បាច់យ៉ាងទន់ភ្លន់ប្រើអស់ចំណេះអស់សមត្ថភាពដែលខ្លួនមាន ក៏ពុំអាចធ្វើឱ្យព្រះទ័យរបស់ព្រះអង្គកំរើកទៅរកកាមគុណទាំងនោះឡើយ។ សង្គ្រាមត្រជាក់ទីពីរនេះ ពួកមារបានត្រូវបរាជ័យទៀត ហើយសុំចុះចាញ់ រួចក៏បាត់ខ្លួនអស់ទៅ។ ពេលនោះហើយ ដែលព្រះពោធិសត្វសិទ្ធត្ថបានឈ្នះពួកមារដោយដាច់ខាត ហើយការត្រាស់ដឹងជាសម្មាសម្ពោធិញ្ញាណ ក៏កើតឡើងក្នុងពេលនោះឯង ក្នុងថ្ងៃ១៥កើត ខែពិសាខ ពេលភ្លឺស្រាងៗ។ នៅពេលនោះពពួកទេវតាបានជ្រាបពីការត្រាស់ដឹងនេះក៏ថ្វាយព្រះពរស័ព្ទសាធុការចំពោះព្រះពុទ្ធឈ្នះមារ។ ផ្កាឈើគ្រប់ធុនក៏បានរីកស្គុះស្គាយជាសញ្ញានៃការត្រាស់ដឹងរបស់ព្រះពុទ្ធ។

ពួកមារទាំងពីរប្រភេទដែលបានពោលមកនេះ បើនិយាយតាមផ្លូវចិត្តវិញ គឺពួកមារដែលច្បាំងនឹងព្រះពោធិសត្វ ដោយប្រើយុទ្ធភណ្ឌផ្សេងៗ នោះជានិមិត្តរូបនៃទោសៈជាសង្គ្រាមក្ដៅ ដែលស្ថិតនៅក្នុងព្រះទ័យព្រះពោធិ-សត្វសិទ្ធត្ថពេលមិនទាន់បានត្រាស់ដឹង ព្រោះមនុស្សដែលប្រើធមិហឹង្សាច្បាំងកាប់សម្លាប់គ្នាដោយសារទោសចិត្ត។ ឯបុត្ររបស់មារទាំងបី គឺនាងរាគី នាងអរតី និងនាងតណ្ហា ជានិមិត្តរូប នៃលោភៈ ឬ រាគៈ ជាសង្គ្រាមត្រជាក់ដែលស្ថិតនៅក្នុងព្រះទ័យព្រះពោធិសត្វសិទ្ធត្ថ ពេលមិនទាន់បានត្រាស់ជាព្រះពុទ្ធ ព្រោះមនុស្សដែលជាប់ចិត្តក្នុងកាមគុណ៥ មានរូបជាដើមដោយធមិរាគៈ។ មធ្យោបាយយកឈ្នះចាញ់គ្នាក្នុងផ្លូវអាណាចក្រ ក៏គេប្រើវិធីទាំងពីរប្រភេទ គឺវិធីលួងលោមផ្លូវចិត្តជាសង្គ្រាមត្រជាក់ គឺការផ្សាយមនោគមវិជ្ជាបញ្ចុះបញ្ចូលទាញមនុស្សឱ្យជឿនូវជំនឿរបស់ខ្លួន។ វិធីមួយទៀត គឺមធ្យោបាយក្ដៅដោយការគំរាមកំហែងដោយសំដីរហូតប្រើអាវុធយុទ្ធភណ្ឌ ដើម្បីឱ្យខ្លាចហើយចុះចាញ់ វិធីនេះជាមធ្យោបាយក្រៅច្បាប់ ភាគច្រើនអ្នកមានអំណាចប្រើមកលើអ្នកទន់ខ្សោយគ្មានអំណាច។ អកុសលមូលទាំង៣ គឺ **លោភៈ ទោសៈ មោហៈ** ជាឫសគល់ដែលនាំឱ្យបុគ្គលសាងបាបកម្ម តែមាន **ទោស**ធ្ងន់ស្រាលជាងគ្នា គឺលោភៈមានទោសស្រាលតែពិបាកលះ។ ឯ**ទោសៈ** មានទោសធ្ងន់តែងាយលះ, ចំណែក **មោហៈ** មានទោសធ្ងន់ផង ពិបាកលះផង។ អកុសលមូលទាំងបីនេះ ព្រះពោធិសត្វព្រះសិទ្ធត្ថលះបានទាំងបីដោយដាច់ខាត ទើបព្រះអង្គបានត្រាស់ជា **ព្រះពុទ្ធ**។ លោភៈ និង រាគៈ ការជាប់ចិត្តទៅលើកាម

គុណ៥ មានរូបជាដើម ពិបាកលះណាស់។ តាមប្រវត្តិសាស្ត្រ អ្នកកាន់អំណាចរដ្ឋខ្លះចាញ់សង្គ្រាមដោយសារគេបញ្ចូលស្ត្រីមកធ្វើជានុយ ក៏ដូចគ្នានឹងប្រទេសកម្ពុជាបានបាត់បង់ទឹកដីក្នុងសម័យកាលខ្លះ ក៏ដោយសារតែអ្នកដឹកនាំខ្មែរសប្បាយភ្លេចខ្លួននឹងស្ត្រីដែលគេយកមកឱ្យជានុយដូច្នោះដែរ។

# ព្រះនាមព្រះពុទ្ធ"សម្មាសម្ពុទ្ធោ"

ព្រះនាមព្រះពុទ្ធថា សម្មាសម្ពុទ្ធោ ប្រែថា ព្រះអង្គត្រាស់ដឹងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។ ពាក្យថា ត្រាស់ដឹងដោយប្រពៃ បានសេចក្តីថាត្រាស់ដឹងនូវ អរិយសច្ច៤។ ការត្រាស់ដឹងនូវអរិយធមិសច្ច៤ ទើបឈ្មោះថាត្រាស់ដឹងដោយប្រពៃ ព្រោះថាការឃើញនូវអ្វីផ្សេងពីអរិយសច្ច៤ ពុំឈ្មោះថាឃើញដោយប្រពៃឡើយ ព្រោះមាគ៌ាក្រៅពីនេះ ពុំអាចធ្វើទុក្ខឱ្យអស់ទៅបានឡើយ។ ពាក្យថា ចំពោះព្រះអង្គបានសេចក្តីថាត្រាស់ដឹងដោយការព្យាយាមនិងពិសោធដោយខ្លួនព្រះអង្គឯង ពុំមែនត្រាស់ដឹងដោយឥទ្ធិពលខាងក្រៅ មានទេវតា ព្រះឥន្ទ ព្រះព្រហ្ម ព្រះញាតិ មិត្តភ័ក្ត្រ ឬអ្នកដទៃណាមួយឡើយ។ ពាក្យថា ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ បានសេចក្តីថា ព្រះអង្គរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ ពុំបានរៀនផ្លូវត្រាស់ដឹងនេះពីគ្រូណាឡើយ។ មួយទៀត ពុំមានគ្រូណាត្រាស់ដឹងមុនព្រះអង្គ ហើយព្រះអង្គទៅរៀនពីគ្រូនោះឡើយ។ ឯតាបសទាំងពីរគឺ **ឧទកតាបស** និង **អាឡារតាបស** ដែលព្រះអង្គទៅរៀននោះ គឺរៀនបានត្រឹមតែផ្លូវឈានសមាបត្តិប៉ុណ្ណោះ គឺគ្រូទាំងពីរចេះតែផ្លូវឈាន ពុំមែនបង្រៀនផ្លូវត្រាស់ដឹងឡើយ។ ប្រៀបដូចអ្នកវិទ្យាសាស្ត្ររកឃើញវិជ្ជាណាមួយមុនគេ ព្រះពុទ្ធត្រាស់ដឹងមុនគេ ក៏ដូច្នោះដែរ។

ការត្រាស់ដឹងរបស់ព្រះពុទ្ធនិងការរកឃើញរបស់អ្នកប្រាជ្ញក្នុងលោក មានលក្ខណៈខុសគ្នា គឺអ្នកប្រាជ្ញផ្លូវលោករកឃើញវិជ្ជាផ្នែកណាមួយតាមការពិសោធផ្លូវអាយតនៈ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និង កាយ ដោយប្រើប្រដាប់ជាឧបករណ៍ជាមួយផង។ ឯការត្រាស់ដឹងរបស់ព្រះពុទ្ធកើតឡើងពីបញ្ញាដ៏ជ្រាលជ្រៅ ដែលជាលទ្ធផលចេញមកពីការកសាងបារមីធម៌ ហើយទីបំផុតព្រះអង្គបានអប់រំព្រះទ័យតាមមគ្គប្រកបដោយអង្គ៨មានព្រះទ័យបរិសុទ្ធមានបញ្ញាញាណដ៏ជ្រាលជ្រៅ ទើបឃើញការពិតគឺអរិយសច្ច៤ដោយឧបករណ៍គឺ **វិបស្សនាញាណ**។ ការរកឃើញវិជ្ជាណាមួយរបស់ក្រុមអ្នកវិទ្យាសាស្ត្រ គ្រាន់តែជួយសម្រួលដល់ការរស់នៅរបស់មនុស្សឱ្យបានប្រសើរប៉ុណ្ណោះ ប៉ុន្តែវិជ្ជាទាំងនោះពុំអាចធ្វើទុក្ខឱ្យអស់ទៅបានឡើយ។ ចំណែកធម៌ដែលព្រះពុទ្ធត្រាស់ដឹងទើបធ្វើឱ្យអ្នកប្រតិបត្តិតាមដល់នូវទីបំផុតទុក្ខ។

# សាសនាជាមួយវិទ្យាសាស្ត្រ

ហេតុផលរបស់ព្រះពុទ្ធសាសនា ជាហេតុផលមានកម្រិតខ្ពស់មាននិយាយទាំង **រូបធម៌** និង **នាមធម៌** ទាំងលោកិយសច្ចៈ ទាំងលោកុត្តរសច្ចៈ។ ចំណែកហេតុផលរបស់វិទ្យាសាស្ត្រភាគច្រើននិយាយហេតុផលផ្នែករូបហើយជាលោកិយសច្ចៈ។

ហេតុផលរបស់វិទ្យាសាស្ត្រផ្នែករូបវិទ្យា សិក្សាអំពីផ្នែករូប និងគីមីវិទ្យា សិក្សាអំពីការផ្សំធាតុ មានហេតុផលពិតទៅតាមរូបធាតុជាលោកិយសច្ចៈ។ ការផ្សំធាតុសំរាប់ផលិតគ្រឿងបរិភោគដូចជាចំណីអាហារបរិភោគគ្រប់យ៉ាង ផលិតគ្រឿងប្រើប្រាស់គ្រប់បែបដូចជាប្រដាប់ដើរដោយម៉ាស៊ីនជាដើម ផលិតថ្នាំពេទ្យគ្រប់ប្រភេទសំរាប់ព្យាបាលជម្ងឺ និងផលិតសំលៀកបំពាក់សំរាប់ស្លៀកពាក់ជាដើម។ នេះជាហេតុផលរបស់វិទ្យាសាស្ត្រ ផ្នែករូបធាតុសំរាប់បំរើសង្គមមនុស្សគួរឱ្យកោតសរសើរណាស់ ប៉ុន្តែគួរឱ្យរិះគន់ចំពោះការលូតលាស់វិទ្យាសាស្ត្រមួយផ្នែកទៀតធ្វើឱ្យលោកវិនាស គឺការបង្កើតកាំភ្លើង គ្រាប់បែកគ្រប់ធុន រហូតបង្កើតគ្រាប់បែកបរមាណូប្រល័យលោកថែមទៀត។ ផ្នែកចិត្ត ក្រុមវិទ្យាសាស្ត្របានលើកយកមកសិក្សាដែរ ហៅថាចិត្តវិទ្យា ប៉ុន្តែពុំមានជម្រៅដូចចិត្តវិទ្យារបស់ព្រះពុទ្ធសាសនាឡើយ។ ពុទ្ធសាសនាសិក្សាអំពីចិត្តដោយផ្ទាល់តែម្តង ចំណែកក្រុមវិទ្យាសាស្ត្រពុំដូច្នេះទេ គេសិក្សាអំពីចិត្តដោយពិនិត្យមើលអាកប្បកិរិយាខាងក្រៅ ទើបគេដឹងថាចិត្ត

មានសភាពយ៉ាងណា ដូចជាមនុស្សទឹកមុខញញឹម ឬសើច គេថាមនុស្សនោះសប្បាយចិត្ត បើមនុស្សមានទឹកមុខស្រងូតស្រងាត់ ឬទឹកមុខក្រៀមក្រំ គេថាមនុស្សនោះមានការព្រួយចិត្ត បើមនុស្សមានទឹកមុខឡើងក្រហមមានអាការៈច្រងេងច្រងាង គេថាមនុស្សនោះមានចិត្តក្រោធខឹង។ ប៉ុន្តែការដឹងចិត្តរបៀបនេះ អាចភ័ន្តច្រឡំឬខុសតែម្តង ព្រោះជួនកាលចិត្តនិងអាការៈខាងក្រៅពុំស្របគ្នា គឺជាការបញ្ចេញដោយចិត្តក្លែងធ្វើដូចជាក្រោធខឹង។ ដូច្នេះការទាយចិត្តដោយមើលអាការៈខាងក្រៅបែបនេះ ពុំត្រឹមត្រូវតាមការពិតទាំងអស់ឡើយ ហើយពុំដឹងថាហេតុដូចម្តេចបានជាចិត្តកើតឡើងដូច្នេះ ចំណែកព្រះពុទ្ធសាសនាទើបដឹងសភាពចិត្តបែបណាៗទាំងអស់។

ព្រះពុទ្ធសាសនានិយាយ ទាំងផ្នែករូប ទាំងផ្នែកចិត្ត ទាំងលោកកិយសច្ចៈ ទាំងលោកុត្តរសច្ច និង បរមត្ថសច្ច។ **អត្ថរបស់អភិធម្ម** និយាយពី **ចិត្ត ចេតសិក រូប** និង **និព្វាន**។ ផ្នែករូបនិយាយអំពីរចនាសម្ពន្ធនៃរូប គឺកើតអំពីមហាភូតរូប៤ គឺ ធាតុទឹក ធាតុដី ធាតុភ្លើង និងធាតុខ្យល់ និង ឧបាទាយរូបគឺរូបផ្សំ២៤ទៀត មានបសាទរូប៥ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយជាដើម។ ព្រះពុទ្ធជាម្ចាស់ជ្រាបផ្លូវចិត្តដោយញាណទស្សនៈ គឺដឹងនូវបុព្វចរិយា ការប្រព្រឹត្ត និងនិស្ស័យសន្តានរបស់មនុស្សសត្វពីដើមមកមានសភាពយ៉ាងណា ព្រះអង្គជ្រាបយ៉ាងនោះ ពុំមែនទាយចិត្តដោយមើលអាកប្បកិរិយាដូចអ្នកវិទ្យាសាស្ត្រឡើយ។ នៅក្នុងគម្ពីរអភិធម្ម ចិត្តពីកំណើតគ្មានទេ ចិត្តកើតមានដោយភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ប៉ះអាយតនៈ

ខាងក្រៅ គឺ រូប សម្លេង ក្លិន រស សម្ផស្ស និង ធម្មា (គឺអារម្មណ៍ដែលចិត្តតោង) ទើបកើតចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ។ ទំរាំកើតចិត្តវិញ្ញាណ ត្រូវប្រព្រឹត្តទៅជាច្រើនខណៈ ចាប់ពីភវង្គមក។ ក្នុងន័យទូទៅថា អ្វីមួយកើតឡើង ត្រូវអាស្រ័យហេតុបច្ច័យផ្សំគ្នា ដែលហៅថា **សង្ខារ** ហើយវាតាំងនៅ និងរលត់ទៅវិញតាមកម្រិតកម្លាំងធាតុ នេះជាច្បាប់ធម្មជាតិដែលព្រះសម្ពុទ្ធត្រាស់ដឹង គឺវាមានហេតុផល ក្នុងខ្លួនរបស់វា គ្មានព្រះជាម្ចាស់អង្គណាបង្កើតឡើងឡើយ។ ពាក្យថា លោកិយសច្ច គឺពិតទៅតាមលោកវោហារសន្មត់ ដូចជាឈ្មោះមនុស្ស ឈ្មោះសត្វ ឈ្មោះរុក្ខជាតិផ្សេងៗជាដើម ដែលមនុស្សដាក់ឈ្មោះដើម្បីស្រួលចំណាំ កុំឱ្យច្រឡំគ្នា ពុំមែនការពិតនៅត្រង់ឈ្មោះនោះឡើយ ដូចជាមនុស្សឈ្មោះ **សុខ** ពុំមែនបានន័យថាមនុស្សនោះគ្មានទុក្ខឡើយ។ ឯ **បរមត្ថសច្ច** ដាក់ត្រូវពិតទៅតាមពិតដូចបញ្ញត្តិថា រូបបានដល់ធម្មជាតិដែលកើតឡើងតែងតែវិនាសទៅវិញដោយក្តៅ និងត្រជាក់ជាដើម ហៅថារូប។ ធម្មជាតិដែលចេះនឹក ចេះគិត ហៅថាចិត្តជាដើម។ ព្រះពុទ្ធសំដែងថា សេចក្តីសុខរបស់មនុស្សពុំមែនស្ថិតនៅលើសម្ភារៈតែម្យ៉ាងទេ គឺត្រូវស្ថិតនៅលើផ្លូវចិត្តជាសំខាន់ គឺចិត្តជាអ្នកប្រើប្រាស់សម្ភារៈ បើរបស់អ្វីមួយប្រែប្រួលពុំកើតទុក្ខផ្លូវចិត្ត ព្រោះអ្វីទាំងអស់ពុំទៀងទេ។ បើមានសម្ភារៈគឺទ្រព្យសម្បត្តិច្រើន តែគេកើតទុក្ខផ្លូវចិត្តដោយមានវិបត្តិអ្វីមួយ នោះគេពុំបានសេចក្តីសុខឡើយ។ ហេតុផលរបស់ព្រះពុទ្ធសំដែងថា សេចក្តីសុខកើតពីការស្ងប់ មានសេចក្តីស្ងប់ ដោយការមិន

បៀតបៀនគ្នាជាដើម ហើយស្ងប់ខ្ពស់បំផុត គឺស្ងប់របស់ **ព្រះនិព្វាន** ដោយកាត់ផ្តាច់នូវឫសគល់ដែលនាំឱ្យសាងបាបកម្មទាំងអស់។ ព្រះពុទ្ធសំដែងថា អ្វីទាំងកើតពីគ្រឿងផ្សំ, **"សង្ខារ"** ពាក្យមួយម៉ាត់នេះ ទុកជាមូលដ្ឋានរបស់វិទ្យាសាស្ត្រ ទោះបីព្រះអង្គពុំបានសំដែងអំពីធាតុនេះផ្សំគ្នាទៅកើតជាធាតុនោះក៏ដោយ ក៏ព្រះអង្គពិតជាបានជ្រាបខាងវិទ្យាសាស្ត្រ, ប៉ុន្តែព្រះអង្គបានទុកមុខងារនេះឱ្យក្រុមវិទ្យាសាស្ត្រស្រាវជ្រាវទៅទៀតចុះ ព្រះអង្គគ្រាន់តែផ្តាំថា បើក្រុមវិទ្យាសាស្ត្រចង់បង្កើតអ្វីក៏បង្កើតទៅចុះ ដើម្បីបំរើសេចក្តីសុខដល់សង្គមមនុស្ស កុំបង្កើតគ្រឿងសាស្ត្រាវុធយកទៅសម្លាប់គ្នា ដែលពាក្យផ្តាំនេះមានចែងក្នុងជំនួញខុស៥យ៉ាង មានមិនឱ្យផលិត មិនឱ្យធ្វើជំនួញគ្រឿងសា-ស្ត្រាវុធគ្រប់ប្រភេទ ព្រោះនាំឱ្យយកទៅសម្លាប់គ្នា។ បេសកកម្មរបស់ព្រះអង្គគឺសម្តែងធម៌ដើម្បីរំលត់ទុក្ខរបស់មនុស្ស។ ធម៌នោះគឺ **អរិយសច្ច៤** គឺ **ទុក្ខសច្ច សេចក្តីទុក្ខ បានដល់ការកើតឡើង នៃខន្ធ៥ ត្រូវកំណត់ដឹង, ហេតុដែលនាំឱ្យកើតទុក្ខបានដល់តណ្ហា ត្រូវលះបង់, ការរំលត់ទុក្ខបានដល់ព្រះនិព្វាន ត្រូវធ្វើឱ្យជាក់ច្បាស់, ផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ ត្រូវចំរើនឱ្យកើតឡើង។**

# តើចាត់ព្រះពុទ្ធជាទស្សនវិទូ ត្រឹមត្រូវឬទេ?

ការបញ្ចូលព្រះពុទ្ធជាទស្សនវិទូ *(Philosophe)* ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាទស្សនវិជ្ជា *(Philosophy)* ក្នុងចំណោមទស្សនវិទូទាំងឡាយក្នុងលោកពុំត្រឹមត្រូវឡើយ ព្រោះព្រះពុទ្ធត្រាស់ដឹង *(Enlightenment)* នូវ **អរិយសច្ច** *(Noble Truth)* ជាធម៌ពិតសំរាប់រំដោះមនុស្សសត្វដែលប្រតិបត្តិតាមឱ្យរួចចាកទុក្ខ ហើយព្រះអង្គមានព្រះទ័យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង ហើយមានលក្ខណៈផ្ទុយអំពីការរកឃើញធម្មតារបស់ទស្សនវិទូទាំងឡាយក្នុងលោក។ ពាក្យថា ទស្សនវិជ្ជាដែលកើតពីការរកឃើញឬការយល់ឃើញរបស់ទស្សនវិទូទាំងនោះ មានពីរបទ គឺ **ទស្សនៈ**១បទ និង **វិជ្ជា**១បទ ប្រែថា **វិជ្ជាអំពីទស្សនៈ** *(Point of View)* គឺជាវិជ្ជាសិក្សាអំពីទស្សនៈឬមតិយោបល់ផ្សេងៗរបស់អ្នកប្រាជ្ញទាំងឡាយជាទស្សនវិទូក្នុងលោក។ ពាក្យថា**ទស្សនវិជ្ជា**នេះ គេឱ្យអត្ថន័យម្យ៉ាងទៀតថា **ការស្រឡាញ់គតិបណ្ឌិត** *(Love of Wisdom)*។ ទស្សនៈនេះមានបទវិគ្គហៈថា **ទិដ្ឋន្តិ ទស្សនំ** ប្រែថា **ទស្សនៈ** គឺទិដ្ឋិនេះឯង។ ក្នុងបាលីព្រះពុទ្ធសាសនា បើឃើញពាក្យថា **ទិដ្ឋិ** បានដល់ **មិច្ឆាទិដ្ឋិ** ដូចធម៌នៅក្នុងអាសវៈ៤យ៉ាងគឺ **ទិដ្ឋាសវៈ** ប្រែថាអាសវៈ គ្រឿងដេកត្រាំ គឺទិដ្ឋិការយល់ខុស។ ដូច្នេះ ទស្សនវិជ្ជាដែលកើតអំពីគំនិតទស្សនវិទូនោះ នៅមានគំនិតយល់ខុស ពុំអាចប្រៀបធៀបការ

ត្រាស់ដឹងរបស់ព្រះពុទ្ធបានឡើយ។ ពាក្យថា **សម្មាទិដ្ឋិ** ប្រែថា ការយល់ត្រូវ *(Right Undertanding)* ដោយបន្ថែមសម្មានៅខាងដើមទិដ្ឋិ។ ទស្សនវិជ្ជាគឺជាការបញ្ចេញមតិយោបល់របស់មនុស្សបុថុជ្ជន ដែលហៅថា ទស្សនវិទូដោយពុំបានអប់រំចិត្តឱ្យបានបរិសុទ្ធដូចព្រះពុទ្ធជាម្ចាស់ឡើយ។ មូលដ្ឋាននៃទស្សនវិជ្ជា គឺសិក្សាអំពីសង្គមវិទ្យា *(Sociology)* ចិត្តវិទ្យា *(Psychology)* និងតក្កវិទ្យា *(Logic)*។ ទស្សនវិទូសម័យបូរាណនៅក្រិក ដូចលោក**ប្លាតុង** លោក**សូក្រាត** លោក**អារីស្តូត** នៅសម័យកណ្តាលនាប្រទេសបារាំង ដូចលោក**ដេការត** លោក**ពីតាហ្គ័រ** នៅអាល្លឺម៉ង់ ដូចលោក **Hengel** លោក **Openhaver** លោក **Karl Max** ជាដើម។ អស់លោកទាំងនោះ លោកខ្លះមានគំនិតជាទេវនិយម ខ្លះជាសម្ភារនិយម គ្រាន់តែបញ្ចេញជាទ្រឹស្តីតាមការយល់ឃើញរបស់ខ្លួន ដោយពុំបានអប់រំកាយវាចាចិត្តឱ្យបានបរិសុទ្ធឡើយ។ មានទស្សនវិទូខ្លះដូចលោក **Karl Max** មេបង្កើតទ្រឹស្តីកុម្មុយនិស្តបានបញ្ចេញទស្សនៈធ្វើឱ្យពិភពលោកមានទំនាស់គ្នាបង្កើតជាសង្គ្រាមបង្ហូរឈាមគ្នាស្លាប់មនុស្សរាប់រយលាននាក់ ដោយសារទស្សនវិទូមិច្ឆាទិដ្ឋិនេះឯង។ ចំ-ណែកព្រះពុទ្ធជាម្ចាស់វិញ ព្រះអង្គបានអប់រំព្រះទ័យព្រះអង្គដល់នូវភាពបរិ-សុទ្ធទើបប្រៀនប្រដៅមនុស្សសត្វជាក្រោយ មានប្រៀនប្រដៅមិនឱ្យធ្វើបាបបៀតបៀនគ្នាជាដើម។ ដូចនេះបញ្ជាក់ថា ទស្សនវិទូទាំងនោះពុំអាចយកមកប្រៀបធៀបនឹង **ព្រះពុទ្ធជាម្ចាស់** ដែលជាបុគ្គលបរិសុទ្ធបានឡើយ ទាំងព្រះ

ធម៌ដែលព្រះអង្គសំដែងក៏ជាព្រះធម៌បរិសុទ្ធ ពុំមែនជាធម៌ធ្វើឱ្យអ្នកប្រព្រឹត្តតាមមានទុក្ខបង្កសេចក្តីទុក្ខសោកដល់សង្គមមនុស្ស ដូចជាទស្សនវិទូខ្លះឡើយ ។

ការត្រាស់ដឹងធម៌របស់ព្រះពុទ្ធនិងការរកឃើញរបស់ទស្សនវិទូនូវអ្វីមួយមានលក្ខណៈខុសគ្នា គឺទស្សនវិទូក្នុងលោកបានដឹងបានយល់អ្វីមួយកើតឡើងដោយការពិសោធធម្មតា តាមវិញ្ញាណទាំង៥ គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ និង កាយវិញ្ញាណ មិនមានបញ្ញាជាន់ខ្ពស់ផ្នែកលោកុត្តរបញ្ញាដឹងរឿងពិតឡើយ ។ ចំណែកព្រះពុទ្ធព្រះបរមគ្រូវិញបានទទួលអារម្មណ៍តាមអាយតនៈនោះដែរ ប៉ុន្តែមានញាណមួយសំរាប់ដឹងរឿងពិត គឺវិបស្សនាញាណទុកដូចជាអតិសុខុមទស្សន៍ *(Microscope)* ជាប្រដាប់មួយបែបដែលក្រុមវិទ្យាសាស្ត្រយកទៅឆ្លុះមើលរបស់ដែលល្អិតបំផុតដែលមើលនឹងភ្នែកធម្មតាពុំឃើញ ។ គឺព្រះអង្គមានញាណទស្សនៈដែលចែកជាពីរបទ គឺ **ញាណ** និង **ទស្សនៈ** ។ ទស្សនៈ គឺការដឹងតាមវិញ្ញាណទាំង៥ ឯញាណ គឺប្រាជ្ញាដឹងរឿងពិត ឧទាហរណ៍ដូចការឃើញរូបដែលមនុស្សធម្មតាឃើញរូបថាល្អ ថាស្អាត ដូចជារូបមនុស្ស ប៉ុន្តែបើលើកយក អាការៈ៣២ មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម មកពិនិត្យពិចារណាតាមញាណ និង ទស្សនៈ ឃើញពុំស្អាត ពុំល្អឡើយ គឺចេញផុតអំពីជំនឿដែលពឹងផ្អែកតែទៅលើអាយតនៈទាំង៥ គឺភ្នែកត្រចៀក ច្រមុះ អណ្តាត កាយ ។ ដូច្នេះព្រះពុទ្ធគេពុំអាចហៅព្រះអង្គថាទស្សនវិទូបានឡើយ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹងដោយប្រពៃ គឺ **សម្មាសម្ពុទ្ធោ** ។ ព្រះអង្គមានព្រះនាមថា **ពុទ្ធោ** ប្រែថាការ

ភ្ជាក់រលឹកអំពីអវិជ្ជា ហើយត្រាស់ដឹងនូវអរិយសច្ច៤ *(Four Noble Truth)*។ ព្រះនាម**អរហំ** ប្រែថាការឆ្ងាយចាកសឹកសត្រូវពោលគឺកិលេសជាដើម។ ក្នុងន័យនេះគេមិនត្រូវបញ្ចូលព្រះពុទ្ធឱ្យនៅក្នុងចំណោមទស្សនវិទូទាំងនោះទេ **ព្រោះព្រះពុទ្ធជាអរិយបុគ្គល** ចំណែកទស្សនវិទូទាំងនោះ ជាបុថុជ្ជនបុគ្គល។ មួយទៀត បើគេបន្ថែមពាក្យឱ្យខ្ពស់ជាងនេះថា ព្រះពុទ្ធជា **អភិទស្សនវិទូ** ក៏រឹតតែមិនបានទៅទៀត ព្រោះថាអភិប្រែថា ក្រៃលែង គឺព្រះពុទ្ធជាទស្សនវិទូដ៏ក្រៃលែង បានន័យថា ព្រះពុទ្ធជាទស្សនវិទូយល់ខុសក្រៃលែងជាងទស្សនវិទូដែលយល់ខុសដទៃទៀត។ ប៉ុន្តែគេអាចប្រើពាក្យថា **ព្រះពុទ្ធជាញាណទស្សនវិទូ** គឺត្រូវបញ្ចូល ពាក្យថា **ញាណ** ដែលជាតួបញ្ញាមួយទៀតនៅខាងដើមពាក្យ **ទស្សនវិទូ** ដែលប្រែថា ព្រះពុទ្ធជ្រាបនូវលោកដោយញាណ និង ទស្សនៈ ទើបត្រឹមត្រូវ ព្រោះមានញាណជាតួបញ្ញានៅក្នុងនោះ។ ក្រៅពីញាណទស្សនវិទូនៅក្នុងពុទ្ធគុណ គេហៅព្រះអង្គថាលោកវិទូ ដែលប្រែថា អ្នកត្រាស់ដឹងនូវលោក គឺត្រាស់ដឹងសត្វលោករបស់មានវិញ្ញាណសង្ខារលោករបស់គ្មានវិញ្ញាណ និង ឱកាសលោករចនាសម្ព័ន្ធទំនាក់ទំនងគ្នា។ ការពិត ការត្រាស់ដឹងរបស់ព្រះពុទ្ធនិងការរកឃើញរបស់ទស្សនវិទូឬអ្នកវិទ្យាសាស្ត្រមានលក្ខណៈផ្សេងគ្នា គឺការត្រាស់ដឹងរបស់ព្រះពុទ្ធកើតឡើងពីការពិសោធផ្លូវចិត្តតាមមគ្គប្រកបដោយអង្គ៨រួមឱ្យខ្ចីបានដល់ **សីល សមាធិ បញ្ញា** ទើបជ្រាបការពិតនូវសង្ខារមានខន្ធ៥ជាដើម ដែលប្រព្រឹត្តទៅជា **អនិច្ចំ ទុក្ខំ** និង **អនត្តា**។ ដោយព្រះអង្គមានញាណនិងទស្សនៈជ្រាបរឿងពិតនេះហើយ ទើប

ធ្វើឱ្យ **អវិជ្ជា តណ្ហា ឧបាទាន** និង **កម្ម** នៃព្រះអង្គអស់ទៅ សេចក្តីទុក្ខមានជាតិទុក្ខជាដើមក៏ត្រូវរលត់។ ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្របានស្រាវជ្រាវរកការពិត ដោយពឹងផ្អែកទៅលើអាយតនៈនិងឧបករណ៍ជាសម្ភារៈសំរាប់ធ្វើការពិសោធអាចរកឃើញការពិតខ្លះ ជាលោកិយសច្ចៈសំរាប់សម្រួលការរស់នៅរបស់សង្គមមនុស្សឱ្យបានសុខស្រួល ប៉ុន្តែអ្នកទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រមួយប្រភេទទៀតរកឃើញនិងផលិតសម្ភារៈសម្លាប់មនុស្ស ដូចជាគ្រឿងសាស្ត្រាវុធគ្រាប់បែកបរមាណូប្រល័យលោកជាដើម ចំណែកព្រះពុទ្ធរកឃើញនិងសំដែងព្រះធម៌ដើម្បីរំលត់ទុក្ខរបស់មនុស្សសត្វតែម្យ៉ាងប៉ុណ្ណោះ។

# មិនត្រូវជឿអាការៈ១០យ៉ាង

**កាលាមសូត្រ**សំដែងនៅក្នុងគម្ពីរ **សុត្តន្តបិដកគម្ពីរអង្គុត្តរនិកាយតិក និបាត**ដែលបុរសម្នាក់ឈ្មោះ**កាលាមៈ**បានចូលទៅសួរព្រះសម្ពុទ្ធដោយសេចក្តីសង្ស័យរបស់ខ្លួន អំពីទ្រឹស្តីនៃតាបសឥសីដែលពោលផ្សេងៗគ្នា ពុំដឹងត្រង់ណាជាសេចក្តីពិតបានទូលសួរព្រះពុទ្ធថា បពិត្រព្រះបរមគ្រូដ៏ចំរើន! ពួកតាបសឥសីនិងព្រាហ្មណ៍បានពោលអួតសរសើរអំពីលទ្ធិរបស់ខ្លួន ហើយមើលងាយលទ្ធិអ្នកដទៃទៀត។ ខ្ញុំព្រះអង្គនៅតែមានសេចក្តីសង្ស័យ មិនអស់ក្នុងចិត្តពុំដឹងជាពួកតាបសឥសីនិងព្រាហ្មណ៍ទាំងនោះណាមួយ ពោលតាមសច្ចធម៌មួយណាពោលកុហកយើងទេ។ លំដាប់នោះព្រះអរហន្តសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាល **កាលាមៈ** ពិតមែនហើយ អ្នកដែលមានសេចក្តីសង្ស័យក្នុងរឿងដែលគួរសង្ស័យ។ ដើម្បីរកការពិតឃើញ អ្នកត្រូវពិចារណានិងពិសោធដោយខ្លួនឯងកុំជឿអាការៈ១០យ៉ាងគឺ :

**១. <u>កុំប្រកាន់ជឿដោយឮដោយស្តាប់តាមគ្នា</u>** = ពាក្យនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយពាក្យនេះពុំអាចយកជាការពិតបានឡើយ ព្រោះពាក្យនិយាយតៗគ្នាច្រើនឃ្លៀងឃ្លាតដូចពាក្យខ្មែរ ក្អែក១ជាក្អែក១០ អ្នកខ្លះច្នៃពតិមានខុសពីការពិត។ ដូច្នេះពាក្យនិយាយតគ្នានេះ កុំប្រកាន់ថាជាការពិត ត្រូវពិចារណាជាមុនសិន។

**២. <u>កុំប្រកាន់ជឿដោយឃើញថាជារបស់មានតាំងពីដើមមក</u>** = កុំប្រកាន់ជឿដោយសម្អាងថា របស់នោះមានតាំងពីដើមមក។ បានសេចក្ដីថា កុំយល់ឬជឿថា របស់ពីដើមនោះសុទ្ធតែជាការពិតមានប្រយោជន៍ ត្រូវតែពិចារណាសិន។

**៣. <u>កុំប្រកាន់ជឿដោយឧទ្ទលដឹងថាយ៉ាងនេះៗ</u>** = គ្រប់ដំណឹងទាំងអស់ដែលបានឮចេញពីជនដែលប្រកបដោយ **លោភៈ ទោសៈ មោហៈ** ឬប្រកបដោយអគតិធម៌យកជាការពិតមិនបានឡើយ ត្រូវពិចារណាជាមុនសិន។

**៤. <u>កុំប្រកាន់ជឿដោយអាងតម្រា</u>** = កុំប្រកាន់ជឿដោយសម្អាងក្បួនច្បាប់ ព្រោះសៀវភៅក្បួនច្បាប់ទាំងនោះ កើតពីមនុស្សសរសេរពិតឬពុំពិតទៅលើការសិក្សាពិចារណាពិសោធមើល។ ត្រង់ចំណុចនេះ ព្រះពុទ្ធបានត្រាស់បើកសិទ្ធិថា សូមបីធម៌តថាគតមុននឹងជឿ ចូរអ្នកយកធម៌នោះទៅពិចារណាឱ្យយល់ច្បាស់ដោយខ្លួនឯងជាមុនសិន។

**៥. <u>កុំប្រកាន់ជឿដោយយកការស្មានខ្លួនឯង</u>** = សេចក្ដីសន្និដ្ឋានជាតក្កវិជ្ជា ការត្រិះរិះដោយគំនិតធម្មតានូវបញ្ហាជ្រាលជ្រៅមានអាថិកំបាំងពុំអាចរកការពិតឃើញឡើយ។

**៦. <u>កុំប្រកាន់ជឿដោយយកន័យតាមគម្រោងខាងក្រៅ</u>** = ជឿដោយវិនិច្ឆ័យតាមគម្រោងឬទ្រង់ទ្រាយខាងក្រៅ ពុំអាចដឹងការពិតឡើយ។

**៧. <u>កុំប្រកាន់ជឿដោយនឹកគិតតាមអាការៈ</u>** = មិនត្រូវសន្និដ្ឋានតែតាមអាការៈខាងក្រៅឡើយ ព្រោះភាពជាក់ស្ដែងប្រាកដឡើងខ្លះ ពុំមានការ

ពិតតាមនោះឡើយ ។ ដូចបុគ្គលពាលជាចោរសំដែងអាការៈដូចជាអាចារ្យដើម្បីបោកអ្នកស្រុក ។

៨. **កុំប្រកាន់ជឿដោយចូលចិត្តថាត្រូវនឹងលទ្ធិរបស់ខ្លួន** = លទ្ធិនិងសាសនានីមួយៗមានលក្ខណៈផ្សេងៗគ្នា បើដូចគ្នាវិញពិតជាលទ្ធិនិងសាសនាទាំងនោះមានតែមួយពុំមានច្រើនឡើយ ។ យ៉ាងណាមិញ ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅផ្សេងពីសាសនាទាំងអស់ក្នុងលោក ទាំងការប្រតិបត្តិទាំងគោលដៅ ។ ព្រះពុទ្ធសាសនាប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ ហើយគោលដៅគឺព្រះនិព្វាន ។ ដូច្នេះកុំឱ្យសន្និដ្ឋានថាសាសនាដទៃ មានពាក្យប្រៀនប្រដៅដូចព្រះពុទ្ធសាសនាឡើយ ។

៩. **កុំប្រកាន់ជឿថានិយាយសមគួរនឹងជឿ** = កុំជឿដោយស្មាន ព្រោះមានអ្នកខ្លះប្រើសំនួនវោហារបញ្ចុះបញ្ចូលអ្នកស្តាប់ ឱ្យជឿពាក្យដើម្បីគោលដៅអ្វីមួយ ។ ដូច្នេះមុននឹងជឿពាក្យណាមួយ ត្រូវពិចារណាជាមុនសិន ។

១០. **កុំប្រកាន់ជឿថាអ្នកនេះជាគ្រូរបស់យើង** = សូម្បីអ្នកនោះជាគ្រូរបស់យើងក៏ដោយ ក៏កុំអាលជឿ ត្រូវតែយកពាក្យនោះទៅពិចារណាទៀត ព្រោះលើកលែងតែព្រះពុទ្ធចេញគ្មានអ្នកប្រាជ្ញណាក្នុងលោកដែលចេះអស់គ្មានភ័ន្តច្រឡំឡើយ ។ សូម្បីព្រះពុទ្ធក៏ព្រះអង្គត្រាស់ឱ្យគេយកពាក្យប្រៀនប្រដៅរបស់ព្រះអង្គទៅគិតពិចារណានិងពិសោធឱ្យឃើញការពិត មុននឹងជឿពាក្យរបស់ព្រះអង្គដែរ ។

ទីបំផុត ព្រះពុទ្ធបានត្រាស់ទៅកាន់**ភាលាមៈ**ថា បើអ្នកបានត្រិះរិះពិចារណាបានល្អិតល្អន់ បានពិសោធហើយ យល់ឃើញថាត្រឹមត្រូវជាបុណ្យជាកុសលនាំមកនូវសេចក្តីសុខចំរើនដល់អ្នកនិងជនដទៃនោះ អ្នកគប្បីទទួលជឿហើយយកទៅប្រតិបត្តិចុះ។ បើអ្នកត្រិះរិះពិចារណាទៅឃើញថា ជារឿងផ្ទុយនឹងបុណ្យកុសលដើម្បីខ្លួននិងអ្នកដទៃនោះ ត្រូវតែលះបង់ចោលឱ្យស្រឡះពីខន្ធសន្តានរបស់អ្នក។ នេះជាពាក្យប្រៀបប្រដៅរបស់ព្រះអង្គដ៏សំខាន់ណាស់ក្នុងការពន្យល់ពុទ្ធបរិស័ទរបស់ព្រះអង្គ ឱ្យប្រើបញ្ញាពិចារណាមុននឹងជឿអ្វីមួយដែលគ្មានលទ្ធិសាសនាណាប្រៀបប្រដូចបានឡើយ។ សាសនាដទៃបង្ខំឱ្យគេជឿ ដោយថាតាមតែគម្ពីរមិនបានពិចារណាវែកញែករកការពិតឡើយ។

# វត្ត និង ព្រះសង្ឃ

ពាក្យថា **វត្ត** ជាភាសាខ្មែរ ដែលចេញមកពីភាសាបាលីថា **វត្ថុ** ប្រែថាទីកន្លែងសម្រាប់គោរពបូជា ជាកន្លែងសម្រាប់ព្រះសង្ឃគង់នៅ ។ សេចក្តីថា ព្រះសង្ឃពុំអាចរស់នៅជាមួយគ្រហស្ថបានទេ គឺត្រូវរស់នៅកន្លែងមួយដាច់ដោយឡែក ដែលហៅថាវត្តនេះឯង ។ ក្នុងភាសាបាលី មានប្រើពាក្យមួយទៀតថា **អារាម** ប្រែថា ជាទីរីករាយចិត្ត គឺបើគេមានទុក្ខកង្វល់ផ្លូវចិត្ត ពេលណាគេចូលវត្ត បានទាញអារម្មណ៍គេឱ្យរីករាយផ្លូវចិត្តក្នុងភាពស្ងប់ ព្រោះវត្តជាទីរម្ងាប់នូវអំពើបាបនិងកង្វល់ផ្លូវចិត្ត។ ក្រៅពីព្រះសង្ឃ វត្តនៅមានវត្ថុជាទីគោរពសក្ការៈ ដូចជា ព្រះវិហារ ព្រះពុទ្ធរូប គម្ពីរព្រះត្រៃបិដកជាដើម ។ គេសង្កេតឃើញនៅប្រទេសកម្ពុជា បើមានភូមិនៅកន្លែងណា តែងតែមានវត្តព្រះពុទ្ធសាសនានៅកន្លែងនោះនិងនៅតាមទីក្រុងក៏មានដូចគ្នាដែរ ។ ពុទ្ធសាសនិកជនខ្មែរទុកវត្តអារាមជាទីគោរពបូជារួមគ្នាក្នុងការបំពេញបុណ្យទាននិងការរម្ងាប់អំពើបាប ។

ពាក្យថាព្រះសង្ឃប្រែថាក្រុមឬពួកដែលចេញមកអំពីភាសាបាលីថា **សង្ឃោ** ។ បានដល់ក្រុមឬពួករបស់បព្វជិត ឬអ្នកបួស គឺភិក្ខុនិងសាមណេរ ដែលជាអ្នកលះបង់ពីភេទជាគ្រហស្ថ មកបួសជា**ឧត្តមភេទ** កាន់ព្រះពុទ្ធសាសនាមានកម្រិតខ្ពស់ ព្រោះឃើញភ័យក្នុងវដ្តសង្សារ ពីការកើតចាស់ឈឺស្លាប់

ហើយរស់នៅក្រោមធម្មវិន័យរបស់ព្រះពុទ្ធ។ ព្រះសង្ឃព្រះពុទ្ធសាសនាមានភារកិច្ចពីរយ៉ាង គឺសិក្សាធម្មវិន័យរបស់ព្រះពុទ្ធឱ្យយល់ច្បាស់ និងប្រតិបត្តិតាមឱ្យបានត្រឹមត្រូវ។ ក្រៅពីនោះ ព្រះសង្ឃមានតួនាទីមួយទៀត គឺការយកធម្មវិន័យរបស់ព្រះពុទ្ធ មកពន្យល់ណែនាំពុទ្ធបរិស័ទឱ្យបានយល់ច្បាស់ និងប្រតិបត្តិតាមឱ្យបានត្រឹមត្រូវ។ ដូច្នេះ ព្រះសង្ឃជាភេទពិសេស ជាភេទបរិសុទ្ធ អាចមានឱកាសប្រតិបត្តិធម៌ សីល សមាធិ បញ្ញា និង ផ្សព្វផ្សាយ ព្រមទាំងរក្សាការពារព្រះពុទ្ធសាសនាបានច្រើនជាងគ្រហស្ថ។ ព្រះសង្ឃស្ថិតនៅក្នុងបាវចនាទាំងបី នៃព្រះត្រៃសរណគមន៍ គឺ **ព្រះពុទ្ធ ព្រះធម៌** និង **ព្រះសង្ឃ** ដែលពុទ្ធបរិស័ទខ្មែរយកជាទីពឹងទីរលឹកស្មើដោយជីវិតរបស់ខ្លួន ដូចបាលីសូត្រនមស្ការថា **នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ ធម្មោ សង្ឃោ មេ សរណំ វរំ** ប្រែថា វត្ថុដទៃជាទីពឹង ទីរលឹកនៃខ្ញុំព្រះករុណា ពុំមានឡើយ មានតែ **ព្រះពុទ្ធ ព្រះធម៌** និង **ព្រះសង្ឃ**ជាទីពឹង ទីរលឹក ស្មើដោយជីវិតរបស់ខ្ញុំព្រះករុណា។ ដូច្នេះ **ព្រះសង្ឃជាទីគោរព** ការប្រើពាក្យហៅព្រះសង្ឃ ក៏ឱ្យបានសមរម្យដែរ គឺត្រូវប្រើពាក្យថា "**ព្រះសង្ឃ**" កុំប្រើ ពាក្យថា "លោកសង្ឃ"ដូច្នេះឡើយ ព្រោះពាក្យថា **លោក** គេមានប្រើសម្រាប់ហៅគួរសមជាមួយគ្រហស្ថ ដូចហៅឈ្មោះលោកនេះ លោកនោះជាដើម។ ការហៅដោយមិនប្រើពាក្យ "**ព្រះ**" នៅខាងដើមជាពាក្យហៅខ្វះការគោរពចំពោះព្រះសង្ឃ។ **ព្រះសង្ឃជាឧត្តមភេទ** មានគុណធម៌ មានសីលគុណជាដើម

គួរគោរពជាអ្នកលះបង់អំពើអាក្រក់អស់ហើយ បានដល់ **អរិយសង្ឃ** និង ព្រះសង្ឃកំពុងព្យាយាមលះបង់បានដល់ **សម្មតិសង្ឃ** ។

វត្តអារាមនៃព្រះពុទ្ធសាសនាខ្មែរ ពុំមែនត្រឹមតែជាមជ្ឈមណ្ឌលសំរាប់គោរពប្រតិបត្តិព្រះពុទ្ធសាសនាប៉ុណ្ណោះទេ លើសពីនេះទៀតជាមជ្ឈមណ្ឌលសម្រាប់រក្សានិងផ្សព្វផ្សាយនូវវប្បធម៌អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទម្លាប់គ្រប់ផ្នែករបស់ខ្មែរថែមទៀត។ ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗតែងតែស្តាប់ឱវាទព្រះសង្ឃចៅអធិការអំពីកិច្ចការព្រះពុទ្ធសាសនាក៏ដូចជាជីវភាពប្រចាំថ្ងៃ ដូចជាការរំលឹកដាស់តឿនឱ្យខំប្រឹងប្រែងប្រកបការងារដោយសុចរិត ដោយមិនដេកចាំសំណាង កុំទាស់ទែងខ្វែងគំនិតគ្នារវាងប្តីប្រពន្ធ និងអ្នកជិតខាងជាដើម។ ប្រជាពលរដ្ឋពុទ្ធបរិស័ទខ្មែរទុកព្រះសង្ឃជាគ្រូរបស់ខ្លួនដែលខ្លួនគប្បីយកឱវាទនោះមកពិចារណា។ កូនចៅប្រុសជំទង់ខ្មែរខ្លះត្រូវបានម្តាយឪពុកយកទៅទុកក្នុងវត្ត ដើម្បីសុំព្រះសង្ឃជួយអប់រំខាងសីលធម៌ ហើយឱ្យបួសជាសាមណេរជាភិក្ខុ បើសឹកមកវិញគេហៅថា **អន្ទិត** ដែលក្លាយមកពីពាក្យ **បណ្ឌិត** ដែលប្រែថាអ្នកចេះដឹង។ កូនចៅខ្មែរអ្នកស្រែចំការដែលក្រីក្របានសំណាក់នៅក្នុងវត្តជាពិសេសវត្តនៅទីក្រុង ដើម្បីបន្តការសិក្សានៅអនុវិទ្យាល័យ និងមហាវិទ្យាល័យរបស់រដ្ឋ ព្រោះរដ្ឋពុំបានរៀបចំឱ្យមានផ្ទះសំរាប់និស្សិតស្នាក់នៅឡើយ។ ក្រៅពីនោះ ព្រះសង្ឃបានជួយកិច្ចការខាងសង្គមកិច្ចជាច្រើនទៀត ដូចជាធ្វើជាអ្នកដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម។

ពុទ្ធសាសនិកជនខ្មែរចាត់ទុកវត្តអារាម និងព្រះសង្ឃជាទីកន្លែង និងជាបុគ្គលដែលខ្លួនគប្បីគោរពបូជា។ ដូច្នេះហើយបានជាពេលចូលវត្ត បើមានពាក់មួកតែងដោះមួក ពេលចូលព្រះវិហារ និងទីកន្លែងមានព្រះពុទ្ធរូប បើពាក់ទ្រនាប់ជើងតែងតែដោះចេញ ហើយថ្វាយបង្គំដោយសេចក្តីគោរព។ កាលជំនាន់ដើម បើមានមនុស្សមានការភិតភ័យអំពីបញ្ហាអ្វីមួយរត់ចូលវត្ត ប៉ូលិសមិនហ៊ានចូលលុកលុយចាប់មនុស្សក្នុងវត្តឡើយដោយការគោរពទីវត្ត និងគោរពព្រះសង្ឃ ព្រោះអ្នករត់ចូលវត្ត គឺរត់រកទីពឹងពីការគំរាមកំហែងបែបណាមួយពីជនឬក្រុមណាមួយ។ ប្រៀបដូចមនុស្សរត់ទៅក្រៅប្រទេស ឬរត់ចូលស្ថានទូតណាមួយ ដើម្បីគេចពីការគំរាមកំហែងដល់ជីវិតពីរដ្ឋាភិបាលផ្តាច់ការ ដែលអង្គការសហប្រជាជាតិមានច្បាប់សំរាប់ការពារជនមានលក្ខណៈបែបនេះ។ សម័យពុទ្ធកាល ក្នុងបិដកខ្មែរភាគ៦ក៏មាននិយាយថា **ព្រះបាទពិម្ពិសារ** បានអនុញ្ញាតដល់ជនដែលមានទោស ហើយរត់មកបួសមិនឱ្យបុគ្គលណាមួយធ្វើទោសដល់ជននោះឡើយ ដោយព្រះរាជឱង្ការថាជនទាំងឡាយណាដែលបួសក្នុងសំណាក់ **សមណសក្យបុត្រ** ជនដទៃធ្វើទោសអ្វីដល់ជនពួកនោះមិនបានឡើយ ព្រោះថាព្រះធម៌ព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយ ជនពួកនោះ ចូរខំប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ត្រង់ចំណុចនេះ គួរពិចារណាព្រះវិន័យត្រង់ **បព្វជ្ជា**

**ខន្ធ**ថា ព្រះពុទ្ធមិនអនុញ្ញាតឱ្យបុគ្គលដែលជំពាក់បំណុលគេ បុគ្គលមានទោសបួសឡើយ ព្រោះដើម្បីកុំឱ្យមានរឿងរ៉ាវក្នុងសហគមន៍ព្រះសង្ឃ ។

ពោលដោយសង្ខេប **វត្ត** និង **ព្រះសង្ឃ** ជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ឬជាព្រលឹងអត្តសញ្ញាណខ្មែរស្ថិតនៅក្នុងចិត្តគំនិតខ្មែរជានិច្ចដែលពុំអាចបំបែកបាន ។ ភ័ស្តុតាងខ្មែរក្រហមបានបំផ្លាញព្រះពុទ្ធសាសនាដល់ឫសគល់ តែវាបរាជ័យវិនាសខ្លួនឯង ចំណែកព្រះពុទ្ធសាសនាស្ថិតនៅក្នុងចិត្តគំនិតខ្មែរដដែល ។ ឥឡូវនេះ សាសនាដទៃកំពុងវាយលុកបំផ្លាញព្រះពុទ្ធសាសនាជំនួសខ្មែរក្រហម សូមពុទ្ធសាសនិកជនខ្មែរប្រុងប្រយ័ត្ន ។

# ប្រទេសកម្ពុជា និង ព្រះពុទ្ធសាសនា

ប្រទេសកម្ពុជាមានអារ្យធម៌ចាស់ទុំនៅអាស៊ីភាគអគ្នេយ៍ ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង។ ជនជាតិខ្មែរបានទទួលយកព្រះពុទ្ធសាសនាជាសរណៈទីពឹងប្រចាំជីវិតរបស់ខ្លួនរាប់ពាន់ឆ្នាំមកហើយ ព្រោះព្រះពុទ្ធសាសនាស្របតាមចិត្តគំនិតរបស់ខ្លួន ឯសាសនាព្រាហ្មណ៍ដែលផ្សាយចូលមកកម្ពុជាដែរនោះ ក្រោយមកខ្មែរពុំយកជាសរណៈទីពឹងដូចព្រះពុទ្ធសាសនាឡើយ ទើបសាសនាព្រាហ្មណ៍មកជ្រកនៅតាមទំនៀមទម្លាប់ខ្មែរខ្លះ និង តាមរយៈសិល្បៈដូចជារឿងរាមកេរ្តិ៍ជាដើម។ ដូច្នេះមូលដ្ឋានវប្បធម៌ខ្មែរ គឺព្រះពុទ្ធសាសនាជាព្រលឹងអត្តសញ្ញាណរបស់ខ្លួន។ ខ្មែរជឿកម្ម ជឿផលជឿបាប ជឿបុណ្យ ដឹងគុណដឹងទោស មានហេតុផល តាមច្បាប់ធម្មជាតិ។ អ្វីមួយដែលប្រាសចាកហេតុផល ខ្មែរពុំអាចទទួលយកបានឡើយ។ យ៉ាងណាមិញ ខ្មែរជឿព្រះពុទ្ធសាសនាគឺជឿការពិត ដែលព្រះពុទ្ធបានសំដែង ដូចពាក្យថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប មនុស្សកើត ចាស់ ឈឺ ស្លាប់ ដើម្បីរំលត់ទុក្ខត្រូវរំលត់អវិជ្ជា តណ្ហា ជាហេតុនាំឱ្យមានខន្ធ៥ មានរូបក្ខន្ធជាដើម។

ជនជាតិខ្មែរមានភ័ព្វសំណាងដោយបានទទួលកាន់ព្រះពុទ្ធសាសនាថេរវាទជាសាសនាមួយមានមាគ៌ាប្រតិបត្តិដ៏បរិសុទ្ធ គឺមគ្គប្រកបដោយអង្គ៨ក្នុងដំណើរឆ្ពោះទៅរកការរំដោះទុក្ខ មាន **ជាតិទុក្ខ** ជាដើម។ បច្ចុប្បន្ននេះព្រះពុទ្ធសាសនាបានចំរើនលូតលាស់យ៉ាងខ្លាំងនៅទ្វីបអឺរ៉ុប និង នៅសហរដ្ឋ-

អាមេរិកជាដើម។ អ្នកចូលកាន់ព្រះពុទ្ធសាសនានៃបស្ចិមប្រទេសទាំងនោះ ភាគច្រើនពួកបញ្ញវ័ន្ត អ្នកចេះដឹង ដូចជាសាស្ត្រាចារ្យ មេធាវីជាដើម ដោយពួកនោះមុនចូលព្រះពុទ្ធសាសនា បានអានសៀវភៅព្រះពុទ្ធសាសនាជាច្រើន ស្រាវជ្រាវទៅឃើញថា ព្រះពុទ្ធសាសនាសំដែងអំពីសច្ចធម៌ ជាសច្ចសាកល គឺការពិតទូទៅបានដល់អរិយសច្ច៤មានទុក្ខសច្ចជាដើម សំរាប់ប្រតិបត្តិឆ្ពោះទៅរកការរំដោះទុក្ខរបស់មនុស្សសត្វ។ ដរាបណាវិទ្យាសាស្ត្រកាន់តែលូតលាស់ ព្រះពុទ្ធសាសនាក៏កាន់តែលូតលាស់ដែរ ព្រោះព្រះពុទ្ធសាសនាក៏ដូចជា វិទ្យាសាស្ត្រដែលនិយាយអំពីទំនាក់ទំនងរវាងហេតុ និងផលដែលគេអាចធ្វើការពិសោធបាន ដូចជាវិទ្យាសាស្ត្រខាងគីមីវិទ្យា និងរូបវិទ្យាជាដើម ក៏ដូចជាពុទ្ធសាសនាពោលថា ហេតុយ៉ាងណាផលក៏កើតឡើង យ៉ាងនោះដែរ គឺផលកើតឡើងស្របតាមហេតុរបស់វា។ ការត្រាស់ដឹងហេតុផល ឬកម្មផលរបស់ព្រះពុទ្ធនេះ ជាការពិតសាកលដែលជាអរិយសច្ចៈ *(Noble Truth)* ដែលគេអាចធ្វើការពិសោធបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ពួកបស្ចិមប្រទេសទាំងនោះ មានសទ្ធាជ្រះថ្លាយ៉ាងខ្លាំងក្លាមានខ្លះបានចូលបួសហើយចូលចិត្តចំរើនវិបស្សនា *( Meditation )*។ មានស្ត្រីជនជាតិ អង់គ្លេសម្នាក់ឈ្មោះ ខេរ៉ិន អាមស្ត្រង *(Karen Armstrong)* បានធ្វើដូនជីសាសនាគ្រិស្តអស់៧ឆ្នាំ នាងត្រឡប់មានសទ្ធានឹងព្រះពុទ្ធសាសនាដោយឃើញពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធត្រង់មេត្តាករុណា *(Compassion)* ការរាប់អាន ការអាណិតអាសូរមិនបៀតបៀនគ្នាដែលជាប្រភពសន្តិភាព និងឃើញធម៌អនត្តា *(Non Ego,*

*Non-Self)* បញ្ញាឃើញថាពុំមែនខ្លួន នាំឱ្យមនុស្សដាក់អស្មិមានះ មិនប្រកាន់ខ្លួនជាប្រភពសន្តិភាពពិភពលោក។

នៅឆ្នាំ **១៩៩៩** សមាជិកនៃអង្គការសហប្រជាជាតិ ជិត២០០ ប្រទេសបានអនុម័តជាឯកច្ឆន្ទទទួលស្គាល់ និងចាត់ទុកបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនាជាបុណ្យអន្តរជាតិ ដោយមូលហេតុពីរយ៉ាង គឺទីមួយ បណ្តាសាសនាទាំងអស់ក្នុងសាកលលោក ព្រះពុទ្ធសាសនាកើតមុនគេ។ ចំណែកសាសនាព្រាហ្មណ៍ដែលសព្វថ្ងៃ ហៅថាសាសនាហិណ្ឌូនោះ បានជាគេពុំចាត់ថាកើតមុនព្រះពុទ្ធសាសនា ព្រោះសាសនានេះពុំមានប្រព័ន្ធពាក្យប្រៀនប្រដៅឱ្យបានច្បាស់លាស់ និងទៀងទាត់ ម្តងគោរពព្រះឥន្ទ ម្តងគោរពព្រះព្រហ្មម្តងគោរពព្រះឥសូរ ម្តងគោរពព្រះវិស្ណុ ឬព្រះនរាយណ៍ ម្តងរួមព្រះទាំងបីអង្គបញ្ចូលគ្នា ដែលមាននិយាយក្នុងគម្ពីរត្រៃវេទ និងគម្ពីរឧបនិស័ទជាដើម។ ចំណែកព្រះពុទ្ធសាសនាវិញ មានកាលបរិច្ឆេទត្រាស់ដឹងច្បាស់លាស់របស់ព្រះពុទ្ធ មានពាក្យប្រៀនប្រដៅច្បាស់លាស់ ដែលសព្វថ្ងៃមាននិយាយក្នុងគម្ពីរព្រះត្រៃបិដក មានពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ ទទួលកាន់ជឿពិតប្រាកដ។ ទីពីរព្រះពុទ្ធសាសនាមាន ពាក្យប្រៀនប្រដៅមួយដ៏សំខាន់ គឺធម៌អហឹង្សា *(Non-violence)* ការមិនបៀតបៀនដែលជាមូលដ្ឋាននៃសុខសន្តិ-ភាពពិភពលោក *(Peace in the world )*។ ស្របនឹងសេចក្តីថ្លែងការណ៍ជាសាកលនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្ស *(Human Rights)* នៅថ្ងៃ១០ធ្នូ ឆ្នាំ១៩៤៨ មិនឱ្យមនុស្សបៀតបៀនគ្នា រំលោភលើសិទ្ធិគ្នា ហាក់

ដូចជាអង្គការសហប្រជាជាតិយកពាក្យព្រះពុទ្ធនេះជាមូលដ្ឋានក្នុងការប្រកាស ចំនួន៣០មាត្រានេះ។ បើគិតពីពេលវេលានៃការប្រកាសរវាងអង្គការប្រជាជាតិ និងព្រះពុទ្ធ គឺអង្គការសហប្រជាជាតិប្រកាសឱ្យមនុស្សគោរពសិទ្ធិមនុស្ស នៅឆ្នាំ១៩៤៨ ចំណែកព្រះពុទ្ធវិញប្រកាសឱ្យមនុស្សគោរពសិទ្ធមនុស្ស រហូតឱ្យគោរពសិទ្ធិសត្វ កុំឱ្យបៀតបៀន និងសម្លាប់ដូចមានក្នុងសិក្ខាបទទីមួយនៃសីល៥ មានជាង២៥០០ឆ្នាំមកហើយ។

ក្នុងប្រវត្តិសាស្ត្រពិភពលោក ពុំឃើញព្រះពុទ្ធសាសនាបង្ហូរឈាមគ្នាកន្លែងណាមួយដោយមូលហេតុសាសនាឡើយ។ ដោយឃើញកត្តាសំខាន់ពីរប្រការនេះហើយ បានជាអង្គការសហប្រជាជាតិចាត់ទុកព្រះពុទ្ធសាសនាជាសាសនាសន្តិភាព អាចយកពាក្យប្រៀនប្រដៅរបស់ព្រះអង្គដូចជាធមិអហឹង្សាធមិព្រហ្មវិហារមានមេត្តាករុណាជាដើម ធ្វើជារូបមន្តសំរាប់បំបាត់កំហឹងការបង្ហូរឈាមគ្នាហើយសាងសុខសន្តិភាពជូនមនុស្សក្នុងលោក។

# សិទ្ធិមនុស្ស និង ព្រះពុទ្ធសាសនា

អង្គការសហប្រជាជាតិបានប្រកាសជាសាកលស្ដីអំពីសិទ្ធិមនុស្សនៅថ្ងៃ១០ធ្នូ ១៩៤៨ ចំណែកព្រះពុទ្ធសាសនាវិញ ព្រះពុទ្ធបានប្រកាសសិទ្ធិមនុស្ស និងសិទ្ធិសត្វជាយូរអង្វែងមកហើយ គឺព្រះអង្គប្រកាសជាង២៥០០ឆ្នាំមកហើយ។ ភ័ស្តុតាងនៃសេចក្ដីប្រកាសនោះមានពាក្យថា មនុស្សកើតមកពីធាតុ៤ ស្រឡាញ់សេចក្ដីសុខដូចគ្នា ដូច្នេះកុំបៀតបៀនគ្នា កុំឱ្យព្យាបាទគ្នា កុំឱ្យចងគំនុំនឹងគ្នា ពៀរពុំអាចរម្ងាប់ដោយតបពៀរ ឈ្នះមនុស្សអាក្រក់ដោយសេចក្ដីល្អ សេចក្ដីសុខកើតពីការស្ងប់ កុំធ្វើអំពើបាប ចង់បានសុខខ្លួនឯងទៅបៀតបៀនអ្នកដទៃពុំបានសុខឡើយជាដើម។ នៅក្នុងព្រហ្មវិហារធម៌មានឱ្យផ្សាយមេត្តា រាប់អានគ្នា គោរពសិទ្ធិគ្នាទៅវិញទៅមក។ នៅក្នុងសីល៥មានហាមមិនឱ្យសម្លាប់គ្នា មិនឱ្យកាន់យកទ្រព្យសម្បត្តិជាកម្មសិទ្ធិអ្នកដទៃ មិនឱ្យលួចប្រពន្ធប្ដីនិងកូនអ្នកដទៃតាមផ្លូវកាមគុណ មិនឱ្យនិយាយកុហកភូតភរអ្នកដទៃ មិនឱ្យផឹកនិងជក់គ្រឿងស្រវឹងគ្រឿងញៀនគ្រប់ប្រភេទ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ដែលជាហេតុនាំឱ្យសាងបាបកម្ម មានការបៀតបៀនអ្នកដទៃជាដើម។ សិក្ខាបទទាំង៥នេះ បើប្រព្រឹត្តកន្លង ឈ្មោះថា រំលោភសិទ្ធិមនុស្សនិងសត្វហើយ។ គួរកត់សំគាល់ថា ច្បាប់ផ្លូវអាណាចក្រ ទាំងច្បាប់នៃប្រទេសនីមួយៗ និងច្បាប់អង្គការសហប្រជាជាតិបានចែងឱ្យមនុស្សគោរពតែសិទ្ធិមនុស្ស ពុំមានចែងឱ្យមនុស្សគោរពសិទ្ធិសត្វផងឡើយ។ ចំណែកច្បាប់ ឬព្រះ

ធម៌ព្រះពុទ្ធសាសនាឱ្យគោរពសិទ្ធិមនុស្ស និងសត្វទូទៅ។ បានសេចក្ដីថា ឱ្យតែគេមានជីវិត ស្រឡាញ់ជីវិតរបស់គេ ចង់រស់នៅមិនចង់ស្លាប់ អ្នកដទៃមិនត្រូវបៀតបៀន មិនត្រូវសម្លាប់គេឡើយ។ ដោយព្រះពុទ្ធឱ្យប្រៀបធៀបថា ខ្លួនយើងស្រឡាញ់ខ្លួនយើង ស្រឡាញ់ទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងណា អ្នកដទៃក៏ស្រឡាញ់ដូចគ្នា ដូច្នេះមិនត្រូវបៀតបៀនគ្នាឡើយ។ គួរកត់សំគាល់មួយទៀតថា ពិភពលោកឱ្យគោរពតែសិទ្ធិមនុស្ស មិនឱ្យគោរពសិទ្ធិសត្វឡើយ ហើយមានសាសនាដទៃក្រៅពីពុទ្ធសាសនានិយាយថាសត្វកើតមកជាអាហាររបស់មនុស្ស មនុស្សត្រូវតែសម្លាប់ធ្វើជាអាហារ មិនត្រូវគោរពសិទ្ធិឡើយ។ ដូច្នេះ សីលធម៌របស់ព្រះពុទ្ធសាសនាមានកម្រិតខ្ពស់ណាស់ ដោយព្រះអង្គសំដែងថា មនុស្សដែលហ៊ានសម្លាប់មនុស្ស មកពីដំបូងមានការសម្លាប់សត្វ។ មិនត្រឹមតែព្រះអង្គហាមមិនឱ្យសម្លាប់ទេ សូម្បីតែគិតនៅក្នុងចិត្តចង់សម្លាប់ក៏កុំឱ្យគិតទៅទៀត ដែលបាលីថា **វធកចិត្តំ** ដែលចាត់ចូលក្នុងមនោទុច្ចរិតក្នុងអកុសលមូល។ ដំណោះស្រាយរបស់ព្រះពុទ្ធមិនឱ្យមនុស្សបៀតបៀនគ្នាគឺជាដំណោះស្រាយដល់ឫសគល់ ព្រោះមនុស្សដែលបៀតបៀនគ្នាមកអំពីចិត្តគិតអាក្រក់ជាមុន។ ចំណែកការរកស៊ីគ្រប់យ៉ាង ត្រូវវៀសវាងមុខរបរឬជំនួញខុស ដែលហៅថា **មិច្ឆាជីវៈ** មានជួញមនុស្ស ជួញថ្នាំពិស ជួញគ្រឿងសាស្ត្រាវុធជាដើម ព្រោះការជួញមនុស្សជាការបន្ថោកបន្ទាបតម្លៃរបស់មនុស្ស, ចំណែកការហាមជួញថ្នាំពិស និងគ្រឿងសាស្ត្រាវុធជាដើម

ព្រោះការជួញថ្នាំពិស និងគ្រឿងសាស្ត្រាវុធ នាំឱ្យយកទៅបំពុល និងសម្លាប់គ្នា។ នេះជាការហាមរបស់ព្រះពុទ្ធ ដើម្បីកុំឱ្យមនុស្សរំលោភលើសិទ្ធិគ្នា ។

សិទ្ធិមនុស្សជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ព្រោះអ្វី? ព្រោះថា បើមនុស្សគោរពសិទ្ធិគ្នាទៅវិញទៅមកហើយ មនុស្សតែងគោរពឆន្ទៈ និង មតិយោបល់របស់អ្នកដទៃ ទោះបីផ្ទុយពីឆន្ទៈ និងមតិរបស់ខ្លួនក៏ដោយ ជាហេតុឱ្យមនុស្សរស់នៅជាមួយគ្នាក្នុងសង្គមបានសុខសាន្ត។ សិទ្ធិមនុស្សនេះ ដើម្បីពន្យល់ឱ្យមនុស្សងាយយល់ និងអនុវត្តឱ្យមានប្រសិទ្ធិភាព ត្រូវរួមផ្សំជាមួយវប្បធម៌របស់សង្គមនីមួយៗផង ដូចប្រជាពលរដ្ឋខ្មែរដែលកាន់ព្រះពុទ្ធសាសនាបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធថា កុំឱ្យមនុស្សបៀតបៀនគ្នា ដោយកាន់ធម៌អហិង្សា ហើយត្រូវមានមេត្តាករុណាដល់គ្នានិងគ្នាជាដើម។ ពាក្យទាំងនេះប្រជាពលរដ្ឋខ្មែរស្តាប់បានជាងពាក្យថាឱ្យគោរពសិទ្ធិមនុស្ស ព្រោះអ្វី? ព្រោះថា ខ្មែរធ្លាប់ឮ ហើយយល់ពាក្យនេះជាប់ក្នុងចិត្តរបស់ខ្លួន ជាតំណកូនចៅមកហើយ។ មួយទៀត ពាក្យនេះជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស។ ការរំលោភលើរាងកាយ ការធ្វើឱ្យគេពិបាកផ្លូវចិត្ត ជាពិសេសការរំលោភគ្រប់បែបយ៉ាង ចាត់ទុកជាការបៀតបៀន។ ការមិនបៀតបៀនឈ្មោះថាជាការគោរពសិទ្ធិ។ ដូច្នេះ ព្រះពុទ្ធបានពោលដល់ឫសគល់នៃការគោរពសិទ្ធិមនុស្ស ដូចព្រះអង្គបានប្រើពាក្យថា កុំព្យាបាទ(**អព្យាបាទោ**) កុំបៀតបៀន(**អហឹឝ្សា**) កុំចងកំហឹងទុកក្នុងចិត្ត(**ឧបនាហះ**)ជាដើម។ ការបង្រៀនធម៌របស់ព្រះពុទ្ធសាសនា គឺជាការបង្រៀនសិទ្ធិមនុស្សនេះឯង។ មិនត្រឹមតែព្រះអង្គ

បង្រៀនមិនឱ្យមនុស្សបៀតបៀតគ្នាទេ ថែមទាំងព្រះអង្គបង្រៀនឱ្យមនុស្ស ជួយសង្គ្រោះមនុស្សមានទុក្ខទៀតផង ដែលហៅថា ករុណាចិត្ត គឺចិត្តអាណិតអាសូរចំពោះអ្នកមានទុក្ខហើយទៅជួយសង្គ្រោះ។ ដូចនេះ បើគេចង់ពង្រឹងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា គេត្រូវតែពង្រឹងព្រះពុទ្ធសាសនា ដោយនាំគ្នាសិក្សាព្រះធម៌របស់ព្រះពុទ្ធឱ្យយល់កាន់តែច្បាស់ឡើង ជាពិសេសត្រូវតែបញ្ចូលកម្មវិធីព្រះពុទ្ធសាសនានៅតាមសាលារៀនគ្រប់ភូមិសិក្សា ដើម្បីឱ្យសិស្សនិងនិស្សិតខ្មែរស្គាល់តម្លៃសីលធម៌កាន់តែជ្រៅឡើង ជាការបណ្តុះធនធានមនុស្សឱ្យបានល្អ គឺយុវជននិងយុវនារីខ្មែរ ដែលជាអនាគតរបស់ប្រទេសកម្ពុជា។ ការរៀនព្រះពុទ្ធសាសនាដែលជាមូលដ្ឋាននៃសិទ្ធិមនុស្ស ចាត់ទុកជាគ្រឹះដ៏សំខាន់ណាស់។ ឯការរៀនសិទ្ធិមនុស្សដែលអង្គការសហប្រជាជាតិ បានប្រកាសជាសាកលកាលពីថ្ងៃ១០ធ្នូឆ្នាំ១៩៤៨នោះ ជាចំណេះបន្ថែមទៀតរបស់ផ្លូវអាណាចក្រ។

# ព្រះសង្ឃជាមួយសង្គមខ្មែរ

នៅប្រទេសកម្ពុជា បើមានភូមិកន្លែងណា តែងមានវត្តព្រះពុទ្ធសាស-នាកន្លែងនោះ បានសេចក្តីថា វត្តព្រះពុទ្ធសាសនាតែងមានគ្រប់ភូមិ ស្រុកខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ វត្តជាមជ្ឈមណ្ឌលរបស់ប្រជាជាតិខ្មែរសំរាប់សិក្សា និង ប្រតិបត្តិព្រះពុទ្ធសាសនា។ តាមទំនៀមទម្លាប់ខ្មែរតាំងពីដើមមក កូនប្រុសជំទង់តែងបញ្ជូនទៅប្រគេនលោកគ្រូចៅអធិការដើម្បីឱ្យកូនខ្លួនសិក្សាអក្សរសាស្ត្រជាតិនៅទីវត្ត។ បន្ទាប់មកឱ្យកូនប្រុសជាភិក្ខុជាសាមណេរដើម្បីសងគុណមាតាបិតា។ បើអង្គខ្លះអស់និស្ស័យសឹកមកវិញ គេហៅថាអន្ទិតដែលចេញមកពីពាក្យថា **បណ្ឌិត** ប្រែថា អ្នកចេះដឹង និង មានចរិយាល្អ ព្រោះអ្នកបួសបានសិក្សា និង អប់រំចិត្តបានចេះដឹង និង មានចិត្តបរិសុទ្ធល្អ។ ពេលនោះព្រះសង្ឃពុំមែនសិក្សាតែព្រះពុទ្ធសាសនានិងប្រពៃណីទំនៀមទម្លាប់ខ្មែរប៉ុណ្ណោះទេ វិជ្ជាជីវៈផ្សេងៗដូចជាជាងឈើ ជាងដែក វិធីផ្សំថ្នាំ មើលជម្ងឺ របៀបគូរគំនូរជាដើម ក៏លោកសិក្សាដែរ។ ដូច្នេះបញ្ជាក់ថា ព្រះសង្ឃមានចំណេះខាងព្រះពុទ្ធសាសនាផ្នែកវប្បធម៌ផង វិជ្ជាជីវៈ ផ្នែកសង្គមកិច្ចផង។ ព្រះសង្ឃជាម្លប់នៃពុទ្ធបរិស័ទខ្មែរ ពេលមានវិបត្តិផ្លូវចិត្តតែងតែទៅថ្វាយបង្គំព្រះសង្ឃឱ្យជួយដោះស្រាយ។ ព្រះសង្ឃពេលខ្លះបានដើរតួនាទីជាចៅក្រមសម្រុះសម្រួលការវិវាទរបស់ប្រជាពលរដ្ឋជាជើងវត្តឱ្យស្រុះស្រួលគ្នាតាមវិធីព្រះពុទ្ធសាសនា។ ពេលខ្លះ ព្រះសង្ឃដើរតួនាទីជាគ្រូបង្រៀនដោយពន្យល់

ណែនាំពុទ្ធបរិស័ទចំណុះជើងវត្តរបស់ព្រះអង្គកុំឱ្យឈ្លោះទាស់ទែងគ្នា កូនចៅឱ្យខំប្រឹងប្រែងរៀនសូត្រ ម្ដាយឪពុកឱ្យខំធ្វើការរកស៊ីប្រកបដោយធម៌ជាដើម។ ពេលខ្លះព្រះសង្ឃដើរតួនាទីជាអ្នកផ្ដើមគំនិត កសាងសាលារៀន មន្ទីរពេទ្យ លើកដីធ្វើផ្លូវ ជីកស្រះ ធ្វើអណ្ដូងជូនប្រជាពលរដ្ឋប្រើប្រាស់។ ពេលខ្លះ ព្រះសង្ឃដើរតួនាទីជាគ្រូពេទ្យជួយព្យាបាលជម្ងឺរបស់ប្រជាពលរដ្ឋដោយថ្នាំបូរាណផ្សំនឹងពុទ្ធមន្តលើកកម្លាំងផ្លូវចិត្តផង។ ពេលខ្លះព្រះសង្ឃដើរតួនាទីជាចិត្តវិទូដោយជួយណែនាំពន្យល់ពុទ្ធបរិស័ទ ដែលមានវិបត្តិផ្លូវចិត្ត ឬខូចផ្លូវចិត្តឱ្យជាសះស្បើយដោយឱសថ គឺ ព្រះធម៌។ ព្រះសង្ឃដែលមានសមត្ថភាពខ្លះបានបបួលញាតិញោមប្រមូលបច្ច័យ និង សម្ភារៈ យកទៅជួយសង្គ្រោះពីគ្រោះធម្មជាតិដូចជា ទឹកជំនន់ខ្យល់ព្យុះខូចខាតទ្រព្យសម្បត្តិ និង រាំងភ្លៀងធ្វើឱ្យខូតខាតផលដំណាំជាដើម។ នៅតាមវត្តអារាមស្រុកស្រែចំការ ព្រះសង្ឃចិញ្ចឹមកូនប្រជាពលរដ្ឋក្រីក្រ និង កុមារកំព្រាខ្លះឱ្យសំណាក់ក្នុងវត្ត ដើម្បីសិក្សារៀនសូត្រ ជាពិសេសវត្តនៅទីក្រុងភ្នំពេញ ដូចជាវត្តឧណ្ណាលោម វត្តលង្កា វត្តបុទុមជាដើម មាននិស្សិតស្នាក់នៅរាប់រយនាក់ក្នុងវត្តនីមួយៗ ដើម្បីសិក្សារៀនសូត្រនៅអនុវិទ្យាល័យនិងមហាវិទ្យាល័យ ព្រោះរដ្ឋពុំបានសង់អាគារឱ្យបានគ្រប់គ្រាន់សំរាប់ឱ្យនិស្សិតស្នាក់នៅឡើយ ដូច្នេះហើយបានជាកូនចៅក្រីក្រទាំងនោះមកសំណាក់នៅក្នុងវត្តដោយពុំមានលទ្ធភាពជួលផ្ទះ។ ដូច្នេះបញ្ជាក់ថា វត្តព្រះពុទ្ធសាសនាមានប្រយោជន៍សំខាន់ណាស់សំរាប់ជួយសម្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ។

# ព្រះពុទ្ធសាសនា និង វិបត្តិនយោបាយ

អ្នកសិក្សាព្រះពុទ្ធសាសនាដឹងហើយថា ពាក្យប្រៀនប្រដៅដ៏សំខាន់របស់ព្រះពុទ្ធ គឺការប្រតិបត្តិធម៌អហឹង្សាការពុំបៀតបៀនដែលជាមូលដ្ឋាននៃសន្តិភាពសាកលលោក។ ប្រទេសកម្ពុជាបានឆ្លងកាត់វិបត្តិនយោបាយជាច្រើនប្រភេទរហូតមានការសម្លាប់រង្គាលដូចរាលពិឃាតខ្មែរក្រហមនិងការឈ្លានពានពីបរទេស។ អំពើអមនុស្សធម៌ទាំងនេះផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដូច្នេះអំពើអាក្រក់នេះពុំទាក់ទងនឹងព្រះពុទ្ធសាសនាឡើយ។ ព្រះពុទ្ធពុំដែលប្រៀនឱ្យមនុស្សទាស់ទែងគ្នាកាប់សម្លាប់គ្នាបែកសាមគ្គីគ្នាឡើយ។ មិនថាតែមនុស្សទេ ដែលព្រះអង្គហាមមិនឱ្យបៀតបៀនមិនឱ្យសម្លាប់ ទាំងសត្វមានជីវិតទាំងអស់ក៏ព្រះអង្គហាមមិនឱ្យសម្លាប់ដូចគ្នា។ អ្នកដែលសម្លាប់ប្រជាពលរដ្ឋខ្មែរសម័យរាលពិឃាតខ្មែរក្រហម ពុំមែនជាអ្នកព្រះពុទ្ធសាសនាឡើយ គឺជាអ្នកដើរតាមមាគ៌ាកុម្មុយនិស្តដែលមានបរទេសកុម្មុយនិស្តនៅពីក្រោយ។ តាមន័យនេះ គេពុំអាចចោទថាការសម្លាប់គ្នានេះដោយសារកាន់ព្រះពុទ្ធសាសនាឡើយ។ តាមពិតវិញ ពុទ្ធសាសនិកជនខ្មែរទាំងគ្រហស្ថទាំងបព្វជិត ត្រូវទទួលរងគ្រោះដោយសារពួកនេះ គឺព្រះសង្ឃត្រូវគេធ្វើគត់ចាប់ផ្សឹក ព្រះពុទ្ធរូប វត្តអារាម គម្ពីរក្បួនច្បាប់ ត្រូវគេបំផ្លាញចោល។ បើគេដើរតាមមាគ៌ាព្រះពុទ្ធវិញ ការសម្លាប់គ្នាពុំកើតមានឡើយ។ ដូច្នេះការសម្លាប់គ្នានេះ ដោយសារការពុំដើរតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធវិញទេ។

ចំពោះប្រទេសកម្ពុជាដែលក្រីក្រវិញ ក៏គេពុំអាចបន្ទោសព្រះពុទ្ធសាសនាឡើយ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះអង្គស្ទើរតែគ្រប់ទំព័រតែងបង្រៀនមនុស្សឱ្យខំប្រឹងប្រែងសិក្សារៀនសូត្រ និងធ្វើការងារប្រកបដោយធមិដូចប្រយោជន៍បច្ចុប្បន្ន៤យ៉ាង គឺ ឧបដ្ឋានសម្បទា ប្រែថា ប្រកបព្រមដោយការប្រឹងប្រែងធ្វើការងារពុំខ្ជិលច្រអូសជាដើម។ មានពាក្យបាលីជាច្រើនដែលមានន័យឱ្យខំប្រឹងប្រែង ដូចពាក្យ ថា **វាយាមៈ វីរិយៈ** ជាដើម។ ជិតបរិនិព្វាន ព្រះពុទ្ធប្រទានឱវាទជាចុងក្រោយដាស់តឿនមិនឱ្យមនុស្សសត្វប្រមាទធ្វេសប្រហែស គប្បីបំពេញសេចក្តីល្អឱ្យបានសម្រេច ព្រោះសង្ខារពុំទៀងទេ។ ដូច្នេះបញ្ជាក់ថា ទោះបីព្រះអង្គជិតបរិនិព្វានមានព្រះអាពាធដ៏ធ្ងន់ក៏ដោយ ក៏ព្រះអង្គនៅតែព្យាយាមរំលឹកបន្ថែមទៀតកុំឱ្យមនុស្សសត្វភ្លេចខ្លួនត្រូវតែធ្វើការងារល្អដើម្បីប្រយោជន៍ខ្លួន និង ប្រយោជន៍សង្គមកុំឱ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍ ព្រោះពេលកន្លងទៅអាយុក៏កន្លងទៅជាមួយដែរ។ សេចក្តីប្រមាទធ្វេសប្រហែសជាផ្លូវនៃមច្ចុ សេចក្តីមិនប្រមាទជាផ្លូវនៃអមតៈ។ ពាក្យថាអមតៈ ប្រែថា មិនស្លាប់ បានដល់ការសម្រេចព្រះនិព្វានជាធមិមិនស្លាប់ គឺបុគ្គលព្យាយាមមិនប្រមាទ ពិចារណាសង្ខារ ការកើតរលត់ រហូតឃើញទោសក្នុងខន្ធ៥ មានរូបខន្ធជាដើម រមែងសម្រេចព្រះនិព្វានលែងកើត ចាស់ ឈឺ ស្លាប់។ **ព្រេង** និង **ប្រឹង** ជាគូគ្នា គឺបុគ្គលបើទោះបីដឹងថា មានព្រេងវាសនាពីមុនមកហើយក៏ដោយ ក៏ត្រូវតែខំប្រឹងប្រែងព្យាយាមក្នុងបច្ចុប្បន្នទៀត ទើបសំណាងដែលបានកសាងនោះបញ្ចេញ

ជាផលបាន។ ដូចប្រេងនៅក្នុងដូងទុំ ដើម្បីបានប្រេង គេត្រូវយកដូងនោះទៅកោស រួចយកទៅរំងាស់ទើបចេញជាប្រេងបាន។ ប្រៀបមួយទៀត ដូចបុគ្គលមានគ្រាប់ពូជមួយគ្រាប់ ដើម្បីឱ្យគ្រាប់ពូជនោះដុះជាដើមបែកមែកបញ្ចេញជាផ្លែផ្កា គេត្រូវតែយកគ្រាប់ពូជនោះទៅដាំលើដីដែលមានជីជាតិថែទាំងស្រោចទឹកកុំឱ្យសត្វស៊ីទើបសម្រេចផលបាន។ ដូច្នេះគ្រប់ពាក្យទូន្មានរបស់ព្រះពុទ្ធគ្មានកន្លែងណាមួយ ដែលព្រះអង្គបង្រៀនឱ្យមនុស្សសត្វខ្ជិលច្រអូសដេកចាំសំណាង អុជធូបបន់ស្រន់ឱ្យសេចក្ដីប្រាថ្នារបស់ខ្លួនផ្ដល់ឱ្យខ្លួនឡើយ។ ពាក្យមួយទៀតថា សេចក្ដីសុខចំរើនគ្រប់យ៉ាងពុំមែនកើតពីមនោរថ គឺកើតពីការនឹកគិតឡើយ តែកើតពីការព្យាយាមធ្វើ ហើយក៏ពុំមែនកើតមកពីព្រះជាម្ចាស់ណាប្រទានឱ្យឡើយ គឺកើតមកអំពីអំពើល្អរបស់ខ្លួន។ ចំពោះព្រះពុទ្ធវិញ ព្រះអង្គសំដែងថា តថាគតគ្រាន់តែប្រាប់បង្ហាញផ្លូវប៉ុណ្ណោះ អ្នករាល់គ្នាត្រូវដើរដោយខ្លួនឯង។ បានសេចក្ដីថា ព្រះអង្គបង្ហាញផ្លូវល្អ ផ្លូវអាក្រក់ នរក សួគ៌ និព្វាន ឯមនុស្សត្រូវជ្រើសរើសផ្លូវដើរដោយខ្លួនឯង។ បើចង់ចេះត្រូវខំរៀន បើចង់បានទ្រព្យសម្បត្តិត្រូវប្រឹងប្រែងរកស៊ីប្រកបដោយធម៌ បើចង់បានសួគ៌និព្វានត្រូវខំប្រតិបត្តិធម៌ នេះជាសច្ចធម៌ ជាហេតុផលពិត ដែលគេពុំអាចកែប្រែបានពុំមែនកើតពីអំណាចឥទ្ធិពលព្រះជាម្ចាស់ជាដើមឡើយ។ ពុទ្ធសាសនិកជនខ្មែរពុំមែនជឿព្រះពុទ្ធសាសនាដោយធ្មេចភ្នែកឡើយ គឺជឿដោយបើកភ្នែក គឺសទ្ធាការជឿដោយមានបញ្ញាការពិចារណារកហេតុផលនៅជាមួយ។ បាន

សេចក្ដីថា ជឿព្រះពុទ្ធសាសនាគឺជឿការពិតដែលព្រះអង្គសំដែង ពុំមែនជឿរបៀបយល់សប្ដិរបៀបនិទានរឿងដែលពុំអាចបញ្ជាក់ការពិតបាននោះឡើយ។

ដូចបានទាញយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធខ្លះមកបញ្ជាក់រួចហើយ គឺព្រះពុទ្ធបានប្រៀនប្រដៅកុំឱ្យមនុស្សខ្ជិលច្រអូស ផ្ទុយទៅវិញឱ្យខំប្រឹងប្រែងធ្វើកិច្ចការប្រកបដោយធម៌ដើម្បីប្រយោជន៍ខ្លួន និង ប្រយោជន៍សង្គម។ ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាបានធ្លាក់ខ្លួនក្រីក្រលំបាកតោកយ៉ាកនេះ ដោយសារវិបត្តិនយោបាយ និង អ្នកដឹកនាំរដ្ឋពុំបានរៀបចំក្បួនសេដ្ឋកិច្ចតាមលក្ខណៈបច្ចេកទេសឱ្យបានជាក់លាក់ព្រមទាំងបានប្រព្រឹត្តអំពើពុករលួយផង បានធ្វើឱ្យកម្ពុជាមាតុភូមិធ្លាក់ខ្លួនដុនដាបដូចសព្វថ្ងៃនេះ។ បើប្រៀបធៀបនឹងប្រទេសពីរបីដែលគោរពព្រះពុទ្ធសាសនា គឺប្រទេសកម្ពុជាគោរពព្រះពុទ្ធសាសនាមានភាពក្រីក្រ ចំណែកប្រទេសជប៉ុន ប្រទេសថៃ គោរពព្រះពុទ្ធសាសនាដែរ ទៅជាអ្នកមានស្ដុកស្ដម្ភ សេដ្ឋកិច្ចលូតលាស់តើបណ្ដាលមកពីអ្វី? ភាពខុសគ្នានេះ គឺពិតជាបណ្ដាលមកពីប្រទេសថៃ និង ប្រទេសជប៉ុន អ្នកដឹកនាំគេចេះដឹកនាំបានល្អទាំងផ្លូវនយោបាយ និង ផ្លូវសេដ្ឋកិច្ច ជាពិសេសគេចេះដកស្រង់យកព្រះគំនិតដ៏ល្អៗរបស់ព្រះពុទ្ធមកអនុវត្ត ទើបធ្វើឱ្យប្រទេសគេលូតលាស់ចំរើន។ ចំណែកអ្នកដឹកនាំខ្មែរអនុវត្តព្រះពុទ្ធសាសនាមានលក្ខណៈប្រជាភិថុតិ ជាផ្លូវនយោបាយពុំបានដកស្រង់យកគំនិតល្អៗរបស់ព្រះពុទ្ធមកអនុវត្តឡើយ។ របស់ល្អមានតម្លៃ ប៉ុន្តែគេពុំបានយកមកប្រើដើម្បីជាប្រយោជន៍ទេ របស់មានតម្លៃនោះក៏ពុំបានផ្ដល់ផលដល់អ្នកនោះឡើយ។ យ៉ាង-

ណាមិញ ប្រទេសកម្ពុជាគោរពព្រះពុទ្ធសាសនា ប៉ុន្តែអ្នកដឹកនាំខ្មែរពុំបានយកពាក្យព្រះពុទ្ធមកអនុវត្ត ក៏មានន័យដូចនេះដែរ។ ស្របន័យនេះដែរ ប្រទេសកម្ពុជាកើតវិបត្តិនយោបាយរហូតបង្ហូរឈាមគ្នានេះ ដោយសារអ្នកដឹកនាំខ្មែរពុំគោរពតាមធម៌ព្រះពុទ្ធ គឺព្រះពុទ្ធបានបង្រៀនមនុស្សមិនឱ្យបៀតបៀនគ្នាកាប់សម្លាប់គ្នា តែត្រូវស្រឡាញ់រាប់អានគ្នាប្រកបដោយ ចិត្តមេត្តា និងករុណា។ ប្រវត្តិព្រះពុទ្ធសាសនា ពុំដែលធ្វើចម្បាំង ឈ្លានពានគេឡើយ មានតែគេឈ្លានពានមកខ្លួនវិញ។ ចំណែកសាសនាដទៃក្រៅពីពុទ្ធសាសនាវិញ បានធ្វើចម្បាំងហើយរហូតពេលនេះ ក៏នៅតែធ្វើចម្បាំងបង្ហូរឈាមគ្នាដោយមូលហេតុសាសនារៀងៗខ្លួន។

# ព្រះពុទ្ធប្រោសមនុស្សសត្វ

ព្រះពុទ្ធជាមនុស្សជាតិទ្រង់ប្រសូត មានមាតាបិតានៅលើផែនដី ហើយដែលនាំឱ្យព្រះអង្គមានប្រភេទខុសប្លែកពីមនុស្សធម្មតានោះ គឺត្រង់ព្រះអង្គបានត្រាស់ជាព្រះពុទ្ធឃើញអរិយសច្ចជាធមិសម្រាប់ចម្លងមនុស្សសត្វដែលប្រតិ-បត្តិតាមឱ្យចេញចាកទុក្ខ ។ ព្រះអង្គត្រាស់ដឹងនូវលោកដែលហៅថា**លោកវិទូ** ប្រែថា ព្រះអង្គត្រាស់ដឹងនូវលោកបីគឺ **សង្ខារលោក** បានដល់ព្រះអាទិត្យ ព្រះចន្ទ ផែនដីជាដើម ។ **សត្វលោក** បានដល់មនុស្សសត្វដែលមានចិត្តវិញ្ញាណ និង **ឱកាសលោក** បានដល់រចនាសម្ព័ន្ធរបស់លោកធាតុ ឬចក្រវាលដែលជាចលនាទាក់ទងគ្នាតាមច្បាប់ធម្មជាតិនិងច្បាប់កម្មផល គ្មានអ្នកណាបង្កើតឡើយ ។ ព្រះអង្គត្រាស់ដឹងនូវលោកធាតុឬចក្រវាលទាំងអស់ តែព្រះអង្គពុំសំដែង ព្រោះពុំមានប្រយោជន៍ក្នុងការរំដោះទុក្ខមនុស្សសត្វ ។ ព្រះអង្គសំដែងដោយយកហេតុបច្ច័យនៃលោកក្នុងខ្លួនយើងថា លោកខាងក្រៅក៏ដូចជាលោកខាងក្នុងខ្លួនយើងដែរ ។

ព្រះពុទ្ធប្រោសមនុស្សសត្វ ដោយការសំដែងធមិទេសនាបង្ហាញហេតុផលឱ្យគេពិចារណា ហើយសម្រេចចិត្តជឿនិងប្រតិបត្តិតាមដោយខ្លួនគេ ។ ពាក្យថាព្រះពុទ្ធសំដែងធមិប្រោសមនុស្សសត្វ ដែលមានឧបនិស្ស័យគួរទូន្មានបាន គឺមនុស្សសត្វដែលធ្លាប់ធ្វើទានរក្សាសីលចំរើនភាវនាពីមុនមក (**ទានូបនិ-ស្ស័យ សីលូបនិស្ស័យ ភាវនូបនិស្ស័យ**) ។ មនុស្សសត្វគ្រប់ប្រភេទ

អាចទទួលធម៌ទេសនារបស់ព្រះអង្គយកទៅប្រតិបត្តិតាម។ រោគផ្លូវចិត្តរបស់មនុស្សសត្វបានដល់ **លោភៈ ទោសៈ មោហៈ** ជាឫសគល់អកុសល ដូច្នេះថ្នាំគឺធម្មោសថ ឱសថ គឺព្រះធម៌ដែលត្រូវយកមកបំបាត់រោគទាំងនោះបានដល់ **ទាន សីល ភាវនា** ហ្នឹងឯង។ **ទាន សីល ភាវនា** នេះសម្រាប់ធ្វើឱ្យសង្គមមនុស្សរស់នៅជាមួយគ្នាបានសុខសាន្ត។ ដើម្បីឱ្យសង្គមមនុស្សស្រឡាញ់រាប់អានគ្នា ព្រះសម្ពុទ្ធបង្រៀនមនុស្សឱ្យធ្វើទាន ជួយសង្គ្រោះគ្នាដោយទ្រព្យសម្បត្តិ ដោយគំនិតបញ្ញា គឺជួយយឹតយោងអ្នកទន់ខ្សោយឱ្យរស់នៅក្នុងសង្គមបានសុខស្រួលផង។ ដើម្បីកុំឱ្យមនុស្សនិងសង្គមមនុស្សបៀតបៀនគ្នា ព្រះពុទ្ធបង្រៀនមនុស្សឱ្យរក្សាសីល ឱ្យផ្សាយមេត្តាចិត្តនិងករុណាចិត្ត គឺការអាណិតអាសូរដល់គ្នាទៅវិញទៅមក។ ដើម្បីឱ្យមនុស្សនិងសង្គមមនុស្សមានសាមគ្គីគ្នា ព្រះពុទ្ធបង្រៀនឱ្យមនុស្សអប់រំផ្លូវចិត្ត ឱ្យបានល្អកុំលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះភ័យខ្លាច ព្រោះវង្វេងពុំដឹងការពិតឡើយ។ ខ្ពស់ពីនេះទៅទៀត ដើម្បីផុតទុក្ខពីជាតិជរាព្យាធិមរណៈត្រូវប្រតិបត្តិតាម **សីលសមាធិបញ្ញា** ឬ **ទានសីលភាវនា** នេះឱ្យបានហ្មត់ចត់បំផុត។ ព្រះពុទ្ធបានណែនាំថា អំពើអាក្រក់នាំឱ្យមានទុក្ខត្រូវលះបង់ អំពើល្អនាំឱ្យបានសុខត្រូវធ្វើឱ្យកើតច្រើនឡើង។ ហេតុផលអាក្រក់និងល្អនេះមាននៅក្នុង លោកជានិច្ច ព្រះពុទ្ធបានឃើញការពិតនេះហើយយកមកសំដែងប្រាប់មនុស្សសត្វទាំងអស់គ្នា។ ក្នុងន័យនេះបញ្ជាក់ថា ការពិតនៅជាការពិត ពុំមែនរឿងជឿឬពុំជឿឡើយ គឺធ្វើល្អបានល្អ ធ្វើអាក្រក់បានផលអាក្រក់ ទៅតាមអំពើដែលខ្លួន

បានប្រព្រឹត្ត។ ព្រះពុទ្ធជាអ្នកបង្ហាញផ្លូវ រីឯមនុស្សសត្វត្រូវដើរដោយខ្លួនឯង។ ធម៌របស់ព្រះពុទ្ធជាសច្ចធម៌ មានតថភាពដែលមនុស្សគ្រប់រូបគ្រប់ជាតិសាសន៍ អាចយកមកពិសោធឃើញការពិតដោយខ្លួនឯង (**បច្ចត្តំ វេទិតព្វោ**)។

# ព្រះពុទ្ធសាសនាពុំបង្ខំមនុស្សឱ្យជឿឡើយ

ព្រះពុទ្ធសាសនាមិនដែលឱ្យមនុស្សលះបង់នូវជំនឿរបស់គេ ហើយបង្ខំឱ្យជឿព្រះពុទ្ធឡើយ។ តែព្រះពុទ្ធគ្រាន់តែបង្ហាញហេតុផល ល្អអាក្រក់ បុណ្យបាបគុណទោសប៉ុណ្ណោះ ចំណែកការជឿឬពុំជឿ គឺជាសិទ្ធិសម្រេចចិត្តរបស់មនុស្សសត្វ។ បន្ទាប់ពីត្រាស់ដឹង ព្រះពុទ្ធបានត្រាស់សំដែងធម៌ទេសនាតាមនិស្ស័យរបស់មនុស្សសត្វ ដូចព្រះនាមមួយបទក្នុងពុទ្ធគុណថា **បុរិសទម្មសារថិ** ប្រែថា ព្រះពុទ្ធជានាយសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន។ ព្រះពុទ្ធមានព្រះពុទ្ធដីកាទៅកាន់ភិក្ខុទាំងឡាយដែលមកស្តាប់ធម៌ព្រះអង្គថា ម្នាលភិក្ខុទាំងឡាយ **តថាគត**បើកសិទ្ធិឱ្យមនុស្សសត្វយកធម៌តថាគតមកពិចារណានិងធ្វើការពិសោធឱ្យបានច្បាស់លាស់ មុននឹងសម្រេចចិត្តជឿ។ មួយឃ្លាទៀតថា **អក្ខាតារោ តថាគតា** ប្រែថា តថាគតគ្រាន់តែបង្ហាញផ្លូវទេ ចូរអ្នកដើរដោយខ្លួនឯងចុះ។ សម័យពុទ្ធកាល មានពួកព្រាហ្មណ៍ជាច្រើនបានចូលកាន់ព្រះពុទ្ធសាសនា មានខ្លះចូលបួសដោយសទ្ធាជ្រះថ្លាដោយបានស្តាប់ធម៌ព្រះពុទ្ធ ហើយពិចារណាទៅឃើញថា ធម៌របស់ព្រះអង្គជាមាគ៌ានាំមនុស្សសត្វឱ្យចេញចាកទុក្ខពិតមែន ពុំមែនដោយសារព្រះអង្គបង្ខិតបង្ខំពួកព្រាហ្មណ៍ទាំងនោះឡើយ។ ព្រះពុទ្ធសាសនាមិនត្រឹមតែពុំបង្ខិតបង្ខំឱ្យគេជឿទេ ថែមទាំងមិនសូកប៉ាន់ ឬអង្វរករឱ្យគេជឿឡើយ។ ត្រង់នេះមានន័យថា ព្រះសម្ពុទ្ធគោរពសិទ្ធិជំនឿរបស់គេ។

# ព្រះពុទ្ធសាសនាមិនមែនជាគ្រឿងញៀន

ទ្រឹស្តីកុម្មុយនិស្តបានពោលថា សាសនាជាអាភៀនរបស់ប្រជាជន បានសេចក្តីថា បើជឿសាសនានាំឱ្យមនុស្សងប់ងល់នឹងសាសនាញៀនដូចអាភៀន នាំឱ្យអាក់ដំណើរក្នុងការលូតលាស់ខាងសម្ភារៈរបស់សង្គម ។ ចំពោះព្រះពុទ្ធសាសនាតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គ្មានឃើញត្រង់ណាមួយនៃពាក្យប្រៀនប្រដៅរបស់ព្រះអង្គធ្វើឱ្យពុទ្ធបរិស័ទអ្នកជឿស្រវឹងវង្វេងស្មារតីមិនបំពេញកិច្ចការ ដើម្បីការលូតលាស់របស់សង្គមញៀនដូចអាភៀនឡើយ ។ ចំពោះព្រះពុទ្ធមានព្រះនាមមួយរបស់ព្រះអង្គថា "**អរហំ**" ប្រែថា ព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសគ្រឿងសៅហ្មងគ្រប់យ៉ាង ហើយឆ្ងាយចាកភាពវង្វេងហើយ ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានណែនាំមនុស្សសត្វកុំឱ្យវង្វេងភ្លេចស្មារតីដោយ **មោហៈ** ភ្លេចបំពេញកិច្ចការដែលជាប្រយោជន៍ខ្លួន និងប្រយោជន៍សង្គមឡើយ។ ព្រះពុទ្ធសំដែងដោយសង្កត់ធ្ងន់ថា សេចក្តីប្រមាទធ្វេសប្រហែសជាផ្លូវនៃសេចក្តីស្លាប់ គឺស្លាប់សតិស្មារតី ស្លាប់ការងារដែលត្រូវធ្វើ រហូតស្លាប់មគ្គផលនិព្វាន ដែលជាការរំលត់ទុក្ខថែមទៀត។ ឯការមិនប្រមាទជាផ្លូវនៃការរស់រហូត គឺរស់ការងារសុចរិតគ្រប់យ៉ាង រហូតសម្រេចព្រះនិព្វានជាអមតធម៌ នេះជាឱវាទចុងក្រោយរបស់ព្រះពុទ្ធ។ ក្នុងប្រយោជន៍បច្ចុប្បន្ន៤យ៉ាង មាតិកាទីមួយសំដែងថា **ឧដ្ឋានសម្បទា** សេចក្តីថា កើតមកជាមនុស្សត្រូវខំសិក្សារៀនសូត្រ ប្រឹងប្រែងប្រកបការងារចិញ្ចឹមជីវិតឱ្យ

បានខ្លាំងក្លា ដោយមិនធ្វេសប្រហែសភ្លេចខ្លួន ដែលហៅថាការស្រើងនេះឯង។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធតែងដាស់តឿនមនុស្សសត្វឱ្យមានសតិសម្ប-ជញ្ញៈមានបញ្ញាពិចារណាឱ្យយល់ច្បាស់ ជៀសវាងការដើរផ្លូវខុស ព្រោះថាការងារល្អទើបបានសេចក្តីសុខចំរើន។ ដូច្នេះបញ្ជាក់ថា ការប្រតិបត្តិតាមព្រះពុទ្ធសាសនា នាំឱ្យមនុស្សនិងសង្គមមនុស្សមានបញ្ញាស្មារតីមានសេចក្តីព្យាយាម មិនវង្វេងញៀនដូចអាភៀនវិញទេ គឺពុំមែនពុទ្ធសាសនិកជនគោរពព្រះពុទ្ធសាសនា ភ្លេចមិនធ្វើការងារចិញ្ចឹមជីវិតឡើយ។

# លក្ខណៈព្រះសង្ឃខ្មែរ

ព្រះពុទ្ធសាសនាថេរវាទមានធម៌វិន័យបរិសុទ្ធមិនកែប្រែ គឺបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ ព្រះអរហន្តទាំងឡាយបានធ្វើ **សង្គាយនា** ផ្ទៀងផ្ទាត់ធម៌វិន័យតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទើបសរសេរជាលាយលក្ខណ៍អក្សរក្នុងគម្ពីរព្រះត្រៃបិដក ដែលពុទ្ធបរិស័ទលើកយកមកសិក្សានិងប្រតិបត្តិតាមសព្វថ្ងៃនេះ។ ប្រទេសដែលគោរព សាសនាថេរវាទមានប្រទេស **កម្ពុជា ថៃ លាវ ភូមា ស្រីលង្កា** និងជនជាតិខ្លះទៀតនៅទ្វីបអាស៊ីនិងទ្វីបអឺរ៉ុប។ ពាក្យថា **ថេរវាទ** ប្រែថា ពាក្យរបស់ព្រះថេរៈជាព្រះអរហន្តដែលបានធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យតាមពាក្យពន្យល់របស់ព្រះពុទ្ធមិនកែប្រែ គឺព្រះពុទ្ធសំដែងយ៉ាងណារក្សាទុកយ៉ាងនោះ។ ដូច្នេះប្រទេសដែលគោរពព្រះពុទ្ធសាសនាថេរវាទ មានធម៌វិន័យរបស់ព្រះពុទ្ធដូចគ្នា ខុសត្រង់លើកយកមកប្រតិបត្តិនិងទំនៀមទម្លាប់ពិធីកម្មនៃប្រទេសនីមួយៗផ្សេងៗគ្នាប៉ុណ្ណោះ។

សូមអំពាវនាវចំពោះព្រះសង្ឃខ្មែរដែលនិមន្តមកសិក្សានៅបរទេស មានព្រះសង្ឃមកសិក្សាព្រះពុទ្ធសាសនាក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរ-វាទ សូមរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ព្រោះបើទោះបីកាន់សាសនាថេរវាទដូចគ្នា ប៉ុន្តែមានទំនៀមទម្លាប់ផ្សេងគ្នា។ ប្រទេសកាន់ព្រះពុទ្ធសាសនា ដែលព្រះសង្ឃខ្មែរទៅសិក្សា គឺប្រទេសថៃ ប្រទេសស្រីលង្កា ប្រទេសភូមា និងប្រទេសឥណ្ឌា។ ចំណែកព្រះសង្ឃខ្មែរទៅសិក្សានៅប្រទេសចិនតៃវ៉ាន់ដែលជា

ប្រទេសកាន់ព្រះពុទ្ធសាសនាមហាយាន ដែលមានការកែប្រែធម៌វិន័យខុសគ្នាពីព្រះពុទ្ធសាសនាថេរវាទ សូមកុំធ្វើតាមលក្ខណៈព្រះសង្ឃមហាយាន គប្បីធ្វើតាមតែលក្ខណៈព្រះសង្ឃថេរវាទហើយជាលក្ខណៈព្រះសង្ឃខ្មែរ។ បានសេចក្តីថា នាំគ្នាទៅសិក្សាយកចំណេះវិជ្ជាពីប្រទេសគេ ប៉ុន្តែត្រូវរក្សាលក្ខណៈ និងតម្លៃជាព្រះសង្ឃខ្មែរ។ មួយទៀត បើបានចំណេះវិជ្ជាហើយត្រឡប់មកមាតុប្រទេសវិញ កុំចម្លងយកទំនៀមទម្លាប់នៃប្រទេសទាំងនោះមកអនុវត្តក្នុងប្រទេសរបស់ខ្លួន ដែលនាំឱ្យបាត់បង់អត្តសញ្ញាណនៃព្រះពុទ្ធសាសនាខ្មែរ។ ប្រទេសកម្ពុជាសព្វថ្ងៃមានឯកភាពល្អណាស់ក្នុងការអនុវត្តព្រះពុទ្ធសាសនា បើយកទំនៀមទម្លាប់ប្រពៃណីអំពីបរទេសមកអនុវត្តផ្ទុយពីទំនៀមទម្លាប់របស់ខ្លួន នាំឱ្យបែកគណៈនិកាយផ្សេងៗទៀតដែលជាហេតុនាំឱ្យកើតជម្លោះបែកបាក់សាមគ្គី។ តាមការសង្កេត ព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅតែរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ទោះនៅកម្ពុជាក្រោមក្តី ចូលមកគង់នៅកម្ពុជាកណ្តាលក្តី មករស់នៅបរទេសក្តី។ ចំណែកព្រះសង្ឃខ្មែរដែលគង់នៅប្រទេសថៃអស់កាលយូរ ត្រូវពុទ្ធបរិស័ទខ្មែរធានាមកគង់នៅ **សហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី** មានព្រះសង្ឃភាគច្រើននៅមានលក្ខណៈជាព្រះសង្ឃខ្មែរ ប៉ុន្តែមានព្រះសង្ឃមួយភាគតូចបានចម្លងពិធីកម្មពុទ្ធសាសនារបៀបថៃមកអនុវត្តក្នុងសង្គមខ្មែរ។ របៀបខុសគ្នានៃសាសនពិធីខ្មែរនិងថៃ គឺពេលសូត្រធម៌ជូនពរពុទ្ធបរិស័ទដែលប្រគេនបច្ច័យ៤ ព្រះសង្ឃខ្មែរពុំលើកព្រះហស្តសំពះទេ ចំណែកព្រះសង្ឃថៃលើកព្រះហស្តសំពះគ្រហស្ថ។ ព្រះសង្ឃថៃ

ពេលសូត្រធម៌បង្សុកូលកាន់ខ្សែអំបោះដែលបន្តពីសព ឬពីធាតុ ឬពីរូបថតអ្នកស្លាប់ ចំណែកព្រះសង្ឃខ្មែរមិនកាន់ខ្សែអំបោះដូច្នេះទេ ព្រោះយល់ថា ការបង្សុកូលគឺជាការសូត្រធម៌ **ធម្មសំវេគ** សម្រាប់ពិចារណា ឯការឧទ្ទិសកុសល គឺសម្រេចលើគ្រួសារសពដែលផ្សាយតាមផ្លូវ **មនោទ្វារ** គឺផ្លូវចិត្តពុំមែនផ្សាយតាមខ្សែអំបោះទេ។ ព្រះសង្ឃថៃមុនពេលឆាន់ចង្ហាន់តែងសូត្រ**អជ្ជៈ** ចំណែកព្រះសង្ឃខ្មែរមិនសូត្រទេ ព្រោះយល់ថា ធម៌**អជ្ជៈ**ជាតួ **បច្ចវេក្ខណញ្ញាណ** គឺឱ្យព្រះសង្ឃពិចារណានៅពេលទទួល ឬពេលបរិភោគនិងប្រើប្រាស់បច្ច័យ៤ កុំឱ្យជាប់តណ្ហាក្នុងការប្រើប្រាស់និងការបរិភោគ ដូចសីល៤របស់ភិក្ខុសង្ឃក្នុងខមួយចែងថា ព្រះសង្ឃទទួលប្រើប្រាស់បច្ច័យបរិសុទ្ធដោយការពិរចារណា ដូច្នេះពុំមែនបរិសុទ្ធដោយការសូត្រទេ។ ព្រះសង្ឃខ្មែរលើកព្រះហស្ថសំពះតែនៅពេលនមស្ការទេសនានិងថ្វាយបង្គំព្រះរតនត្រ័យ។ ចម្លែកមួយទៀតព្រះសង្ឃថៃសូត្រធម៌ជូនពរដែលឥតមានអ្នកស្តាប់នៅពេលនោះ នេះក៏ជាការឆ្គង ព្រោះថាការសូត្រធម៌ជូនពរក្នុងបាលី ថា **បត្តានុមោទនា** គឺត្រេកអរចំពោះអ្នកធ្វើកុសលជាការលើទឹកចិត្ត ចុះបើគ្មានអ្នកស្តាប់នៅទីនោះទេ តើសូត្រដើម្បីអ្វី? ដើម្បីឱ្យរួចចាកទោសកុំឱ្យ **ឥណបរិភោគ** ត្រូវពិចារណាជា **បច្ចវេក្ខណញ្ញាណ** ក្នុងការប្រើប្រាស់បច្ច័យ៤ដែលគេប្រគេននោះវិញ។ ព្រះសង្ឃជាឧត្តមភេទជាភេទដ៏ខ្ពង់ខ្ពស់សូម្បីព្រះមហាក្សត្រជាស្តេចផែនដីក៏ថ្វាយបង្គំដែរ តែបែរជាមានព្រះសង្ឃខ្លះមិនត្រឹមតែព្រះមហាក្សត្រលើកព្រះហស្តសំពះក៏សំពះតបវិញទេ ថែមទាំងលើកព្រះហស្តសំពះគ្រហស្ថទូទៅពេល

គ្រហស្ថលើកដៃសំពះ នេះជាការរណោបរណាបយកបុណ្យស័ក្តិ និងលាភសក្ការៈ ខុសធម៌វិន័យ ដោយបញ្ចុះតម្លៃខ្លួនឯង និងនាំឱ្យខូចតម្លៃព្រះពុទ្ធសាសនា។

# សម្មាទិដ្ឋិ និង មិច្ឆាទិដ្ឋិ

ពាក្យថា **ទិដ្ឋិ** ស្មើគ្នានឹងពាក្យថា ទស្សនៈ ប្រែថាការយល់ឃើញ ហើយប្រកាន់ជឿហៅថាលទ្ធិ។ ទិដ្ឋិនេះជាពាក្យកណ្តាល បើដាក់សម្មាខាងដើម ជា**សម្មាទិដ្ឋិ** ប្រែថា **ការយល់ត្រូវ** បើដាក់មិច្ឆាខាងដើមជា **មិច្ឆាទិដ្ឋិ** ប្រែថា **ការយល់ខុស**។ ធម្មជាតិរបស់មនុស្សតែងតែមានគំនិតយល់បែបណាមួយទៅលើបញ្ហាមួយទៅតាមឧបនិស្ស័យ និងតាមសមត្ថភាពរបស់ខ្លួន។ បើយល់បែបណាហើយ តែងតែប្រព្រឹត្តធ្វើអំពើបែបនោះ។ មគ្គទី១ក្នុងបណ្តាមគ្គទាំង៨ គឺ **សម្មាទិដ្ឋិ** ប្រែថា ការយល់ច្បាស់ក្នុងអរិយសច្ច៤ គឺ **ទុក្ខសច្ចៈ** សេចក្តីទុក្ខបានដល់ការកើតមាននៃខន្ធ៥ត្រូវកំណត់ដឹង, **សមុទយសច្ច** ហេតុដែលនាំឱ្យកើតទុក្ខត្រូវលះបង់, **និរោធសច្ច** ការរំលត់ទុក្ខបានដល់មគ្គមានអង្គ៨ត្រូវចម្រើនឱ្យកើតឡើង។ ការឃើញអរិយសច្ចទាំង៤នេះ ឈ្មោះថាការឃើញត្រូវជា **សម្មាទិដ្ឋិ**។ ការឃើញអរិយសច្ច៤នេះ ដោយសារការពិចារណាផ្នែកវិបស្សនា ឃើញសេចក្តីពិតពយ៉ាងនៃខន្ធ៥ គឺ **មិនទៀង ជាទុក្ខ** និង **ជាអនត្តា** ពុំមានខ្លួន។ ការពិចារណាឃើញសភាពពិតដូច្នេះ ឈ្មោះថាជាការយល់ត្រូវ។ ក្នុងកុសលកម្មបថទី១០ ដែលជាវិន័យរបស់ **ឧបាសក ឧបាសិកា** មានឈ្មោះថា **សម្មាទិដ្ឋិ** និង នៅក្នុងបុញ្ញកិរិយាវត្ថុ ១០យ៉ាង មានឈ្មោះថា **ទិដ្ឋុជុកម្ម** ប្រែថា ធ្វើទិដ្ឋិឱ្យត្រង់គឺជឿកម្មនិងផល

របស់កម្ម ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ ជឿព្រះធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធថាជាធម៌ដឹកនាំអ្នកប្រតិបត្តិឱ្យចេញចាកទុក្ខពិតមែន ជឿព្រះសង្ឃជាភេទបរិសុទ្ធប្រតិបត្តិដ៏ប្រពៃពិតមែន ទាំងអស់នេះ ចាត់ជាការយល់ឃើញត្រឹមត្រូវតាមសេចក្តីពិត។ **សម្មាទិដ្ឋិ** ការឃើញត្រូវ និង **សម្មាសង្កប្បោ** ការត្រិះរិះត្រូវ គឺត្រិះរិះមិនព្យាបាទ មិនរំពៃចង់បានចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ ត្រិះរិះចេញចាកកាម។ សម្មាទិដ្ឋិនិងសម្មាសង្កប្បោទាំងពីរនេះ សង្គ្រោះចូលក្នុង **បញ្ញា**។ ពេលដែលព្រះអង្គចម្រើន **វិបស្សនា** បានសម្រេចញាណមួយហៅថា **អាសវក្ខយញ្ញាណ** ដែលប្រែថា ប្រាជ្ញាឃើញអរិយសច្ច៤ ដែលធ្វើឱ្យអាសវៈកិលេសនៃព្រះអង្គអស់ទៅបានដោយសារការយល់ត្រូវ គឺ **សម្មាទិដ្ឋិ** នេះឯង។ ជនដែលមានគំនិតជាសម្មាទិដ្ឋិ គឺ **កល្យាណបុថុជ្ជន** និង **សោតាបន្នបុគ្គល** រហូតដល់ **ព្រះអរហន្ត**។

ចំណែកពាក្យថា **មិច្ឆាទិដ្ឋិ** ប្រែថាការយល់ខុស គឺឃើញប្រាសចាកសេចក្តីពិត។ ក្នុងសុត្តន្តបិដកនៃគម្ពីរព្រះពុទ្ធសាសនា មាននិយាយអំពីទិដ្ឋិការយល់ខុសមានរហូតដល់៦២ប្រការដែលមានសម្តែងក្នុងសូត្រមួយឈ្មោះ **ព្រហ្មជាលសូត្រ**។ **ទិដ្ឋិ៦២**នេះ ព្រះអង្គបានបំព្រួញនូវគំនិតរបស់មនុស្សសត្វដែលយល់ខុស គឺសត្វមានគំនិតយ៉ាងណា ក៏បញ្ញត្តិនូវទិដ្ឋិយ៉ាងនោះ ដូចជាបញ្ញត្តិថា ម្តាយឪពុកគ្មានគុណ លោកនេះទៀងខ្លះមិនទៀងខ្លះ បរលោកគ្មានជាដើម ទាំងអស់នេះចាត់ជាគំនិតយល់ខុស។ មានទិដ្ឋិយល់ខុស២យ៉ាងគឺ :

<u>**សស្សតទិដ្ឋិ**</u> យល់ថា មានធម្មជាតិម្យ៉ាងនៅក្នុងខ្លួនមនុស្សសត្វ ដែលហៅថា **អាត្ម័ន** ជាភាសាសំស្ក្រឹត, ឯបាលីថា **អត្តា** ឬព្រលឹងវិញ្ញាណ ពុំចេះរលត់ បើទោះបីរូបត្រូវរលត់ទៅក៏ដោយ ក៏ធម្មជាតិនេះពុំរលត់ដែរ។ ការយល់ខុស មួយទៀតគឺ <u>**ឧច្ឆេទទិដ្ឋិ**</u> យល់ខុសថា គ្មានហេតុបច្ច័យសម្រាប់បន្តផលមួយ ទៀតទេ។ ក្រៅពីនោះ មានការយល់ខុស៣យ៉ាងទៀតគឺ :

- <u>**អហេតុកទិដ្ឋិ**</u> បដិសេធហេតុ គឺផលដែលកើតឡើង គ្មានហេតុណា មួយបង្កើតឡើងទេ គឺកើតឡើងដោយចៃដន្យ.
- <u>**អកិរិយទិដ្ឋិ**</u> បដិសេធផល គឺអំពើដែលធ្វើ គ្មានបង្កើតជាផលឡើយ.
- <u>**នត្ថិកទិដ្ឋិ**</u> បដិសេធទាំងហេតុ ទាំងផល គឺបដិសេធទាំងពីរ ។

ព្រះពុទ្ធសម្ដែងថា សត្វលោកបើពុំទាន់ឃើញសច្ចធម៌គឺ **អរិយសច្ច៤** ដែលជាធម៌ចេញចាកទុក្ខទេ សត្វលោកនៅតែវង្វេងកើតស្លាប់ក្នុងវដ្តសង្សារ ជានិច្ច។ ប្រៀបដូចជាមនុស្សងងឹតភ្នែកពីកំណើត រមែងដើរខុសផ្លូវ ពុំអាច ដើរត្រូវផ្លូវទៅកាន់គោលដៅរបស់ខ្លួនបានឡើយ។ យ៉ាងណាមិញ មនុស្ស ដែលមានអវិជ្ជាបិទបាំង រមែងពុំឃើញសភាពពិតនៃព្រះធម៌គឺ **អរិយសច្ច៤** ឡើយ។ កាលណាមនុស្សមានមិច្ឆាទិដ្ឋិគឺការយល់ខុស តែងតែប្រព្រឹត្តធ្វើអំពើ អាក្រក់ផ្សេងៗដែលផ្ដល់ផលមកវិញជាទុក្ខ។

ដើម្បីកម្ចាត់បង់ **មិច្ឆាទិដ្ឋិ** ការយល់ខុសឱ្យកើតមាន **សម្មាទិដ្ឋិ** ការយល់ត្រូវ គប្បីអនុវត្តតាម **ចក្កធម៌៤** ប្រការគឺៈ ១- <u>សប្បុរិសូបសំសេវៈ</u>

មានន័យថា សេពគប់សប្បុរស, ២- សទ្ធម្មស្សវន មានន័យថា ស្តាប់ពាក្យប្រៀនប្រដៅរបស់លោក, ៣- យោនិសោមនសិការ មានន័យថា ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញាគឺពិចារណាឱ្យយល់ធមិ, ៤- ធម្មានុធម្មប្បដិបត្តិ មានន័យថា ប្រតិបត្តិនូវធមិដ៏សមគួរដល់ធមិ គឺប្រតិបត្តិឱ្យត្រឹមត្រូវតាមផ្លូវធមិ។

# ប្រពៃណីខ្លះ តើព្រះសង្ឃគួរអនុវត្តបែបណា?

មុខងាររបស់ព្រះសង្ឃពុទ្ធសាសនាថេរវាទ ជាពិសេសព្រះសង្ឃខ្មែរ មានមុខងារពីរយ៉ាងៈ គឺកាសិក្សាឱ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និង ប្រតិបត្តិឱ្យបានល្អត្រឹមត្រូវតាមធម្មវិន័យ។ តួនាទីជាចាំបាច់មួយទៀត គឺការ ពន្យល់ពុទ្ធបរិស័ទខ្មែរឱ្យយល់តម្លៃពុទ្ធសាសនាកាន់តែច្បាស់លាស់ឡើង។ ឱកាសដែលអាចពន្យល់នោះ គឺពេលបុណ្យទានផ្សេងៗ ព្រោះពុទ្ធបរិស័ទពុំអាច មានឱកាសមកសិក្សាធម្មវិន័យឱ្យដូចជាព្រះសង្ឃបានទេ ដោយមានកិច្ចការ រវល់ក្នុងការចិញ្ចឹមជីវិតរបស់ខ្លួន និងក្រុមគ្រួសារ។ ដើម្បីបំពេញកិច្ចនេះបាន ព្រះសង្ឃដែលធ្វើជាគ្រូរបស់ពុទ្ធបរិស័ទ ត្រូវសិក្សាក្បួនគរុកោសល្យ របៀប ពន្យល់ ដើម្បីឱ្យពុទ្ធបរិស័ទងាយយល់។ ការសូត្រធមិគ្រាន់តែជាពិធីកម្មរបស់ សាសនា ការសំខាន់របស់ព្រះពុទ្ធសាសនា គឺសិក្សាព្រះធមិ ហើយយកទៅ ប្រតិបត្តិតាម។

ការអភិវឌ្ឍព្រះពុទ្ធសាសនាឱ្យលូតលាស់ចម្រើន និងរឹងមាំ គឺការ ពន្យល់ឱ្យយល់ កាលណាមនុស្សយល់ចូលចិត្តហើយ មនុស្សនឹងប្រតិបត្តិតាម ព្រះពុទ្ធសាសនានឹងស្ថិតនៅគង់វង់ នេះដោយសារព្រះសង្ឃបានបំពេញកាតព្វ កិច្ចចំពោះពុទ្ធបរិស័ទ គឺការពន្យល់ដោយការធ្វើធម្មកថា ឱ្យឱវាទ និង ទេសនា ពុំមែនត្រឹមតែសូត្រធមិនោះទេ។ ការសូត្រធមិរបស់ព្រះភិក្ខុសង្ឃ ដែលជាពិធីកម្មរបស់ព្រះពុទ្ធសាសនាមាន អត្ថន័យដូចតទៅនេះ:

## ការសូត្រធម៌ថ្វាយបង្គំ

ការសូត្រធម៌ថ្វាយបង្គំដែលហៅថា នមស្ការព្រះរតនត្រ័យ មានន័យត្រឹមតែសរសើរគុណ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ**។ ការសរសើរគុណដោយវាចា ការក្រាបសំពះដោយកាយ និងបង្អោនទៅដោយចិត្ត ជាកិច្ចមួយហើយរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទ ប៉ុន្តែកិច្ចមួយទៀតដែលជាកិច្ចសំខាន់ចាំបាច់ គឺការប្រតិបត្តិធម៌វិន័យរបស់ព្រះពុទ្ធ។ បើគ្រាន់តែសូត្រសរសើរ ប៉ុន្តែមិនបានអនុវត្តតាម ឬអនុវត្តតាមមិនបានត្រឹមត្រូវ មិនឈ្មោះថាជាពុទ្ធសាសនិកជនពេញលក្ខណៈឡើយ។

## ការនិមន្តព្រះសង្ឃសូត្រមន្ត

ការសូត្រមន្ត ឬចម្រើនព្រះបរិត្ត ជាពាក្យពីរដែលគេប្រើ។ ពាក្យទាំងពីរនេះគេប្រើផ្លាស់ប្តូរគ្នា ហើយគេអាចស្តាប់ពាក្យនេះបាន។ ពាក្យថា "**បរិត្ត**" តាមន័យដែលអាចារ្យសូត្រអារាធនាព្រះសង្ឃឱ្យសូត្រមន្ត គឺការការពារ បញ្ចៀសនូវទុក្ខសោករោគភ័យកុំឱ្យកើតមាន។ ឯពាក្យថា "**មន្ត**" ប្រែថាជាគ្រឿងប្រកបឱ្យបានសុខ។ តើការដែលព្រះសង្ឃសូត្រមន្ត ឬចម្រើនព្រះបរិត្តនេះ ត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនាឬទេ? តាមការសង្កេត ការសូត្រមន្ត ឬចម្រើនព្រះបរិត្តមានពីរប្រភេទ <u>គឺប្រភេទទីមួយ</u> ការចំរើនព្រះបរិត្តធម្មតា ក្នុងឱកាសបុណ្យទានផ្សេងៗ ដូចជាការសូត្រមង្គលសូត្រ គឺជាសូត្រមួយដែល និយាយអំពីមង្គល៣៨ប្រការជាដើម ហាក់ដូចជាពន្យល់ធម៌។

ការចម្រើនព្រះបរិត្តបែបនេះ ជាការគួរមិនទាន់ខុសអ្វីឡើយ។ ប៉ុន្តែការចម្រើនព្រះបរិត្តប្រភេទទីពីរ មានការយល់ជ្រុលហួសអំពីអត្ថន័យរបស់ព្រះពុទ្ធសាសនា ហើយមានអង្គខ្លះសូត្រពាក្យខ្លះមិនមាននៅក្នុងព្រះពុទ្ធសាសនា គឺជាពាក្យមន្តអាគមគាថា បែបសាសនាព្រាហ្មណ៍ថែមទៀត។ ការសូត្រចម្រើនព្រះបរិត្តបែបនេះ គេហៅថាសូត្រលើករាសី និងសូត្ររំដោះគ្រោះ។

## ការសូត្រលើករាសី

ការសូត្រមន្តលើករាសីនេះ បើតាមជំនឿរបស់ខ្មែរខ្លះ ហើយព្រះសង្ឃជាអ្នកសូត្រក៏យល់ស្របតាមផង គេនិមន្តព្រះសង្ឃសូត្រមន្តនៅពេលដែលគេយល់ថាខ្លួនគេមានរាសីធ្លាក់ចុះ ដោយធ្វើការអ្វីពុំបានសម្រេច ចង់បានអ្វីមិនបានសម្រេចដូចប្រាថ្នា។ គេយល់ថាបើនិមន្តលោកសូត្រមន្ត រាសីគេនឹងឡើង ហើយធ្វើការអ្វីនឹងបានសម្រេចដូចប្រាថ្នា។ ការយល់បែបនេះផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធសម្ដែងថាចង់បានសេចក្ដីសុខចម្រើនត្រូវរកសាងល្អ គឺប្រព្រឹត្តអំពើជាកុសល។ ដូច្នេះពាក្យថារាសីឡើងបានសេចក្ដីតាមន័យរបស់ព្រះពុទ្ធសាសនា គឺការសាងល្អដោយ កាយ វាចា និងចិត្ត។ ថ្ងៃណា ខែណា ឆ្នាំណា គេសាងល្អ ថ្ងៃខែឆ្នាំនោះ ជាមង្គលមានសិរីសួស្ដី ហើយរាសីគេឡើងនៅពេលនោះឯង។ អត្ថន័យរបស់ព្រះពុទ្ធសាសនាថា ការរៀនសូត្រ ការប្រកបមុខរបរវិជ្ជាជីវៈផ្សេងៗ ដើម្បីឱ្យប្រឡងជាប់ រកស៊ីមានបាន ត្រូវព្យាយាមប្រើបញ្ញាសិក្សាឱ្យមានជំនាញតាមមុខវិជ្ជាជីវៈ

និមួយៗ នោះនឹងបានសម្រេចតាមបំណងពុំខាន។ ដូច្នេះបើតាមន័យនេះ បើនិមន្តលោកសូត្រមន្ត ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌដូចពោលមកហើយទេ រាសីមិនឡើងឡើយ នៅតែចុះដដែល។ ដូច្នេះព្រះសង្ឃដែលទទួលនិមន្តគួរតែអាណិតអាសូរដល់គ្រហស្ថ ជួយពន្យល់ពុទ្ធបរិស័ទខ្មែរដែលយល់ព្រះពុទ្ធសាសនាពុំច្បាស់លាស់ ឱ្យយល់ច្បាស់លាស់ឡើងវិញ កុំគិតតែសូត្រធម៌ដើម្បីលាភសក្ការៈឡើយ។ គួរសង្កេតមួយទៀត ខ្មែរនៅបរទេសដូចជានៅសហរដ្ឋអាមេរិក បារាំង អូស្ត្រាលី ជាដើម ឃើញព្រះសង្ឃពីប្រទេសកម្ពុជាដែលចេះសូត្រមន្តស្រោចទឹក (តាមពិតព្រះសង្ឃណាក៏ចេះសូត្រធម៌នេះដែរ ប៉ុន្តែឃើញឃ្លៀងឃ្លាតពីពុទ្ធសាសនាខ្លាំងពេកលោកពុំធ្វើ) នាំគ្នាល្ងូឆវនិមន្តទៅសូត្រមន្តស្រោចទឹក ជាពិសេសថៅកែហាង ថៅកែភោជនីយដ្ឋាន និងអ្នកលក់ដូរផ្សេងៗ ដោយយល់ថាសកម្មភាពនេះធ្វើឱ្យខ្លួនរកស៊ីមានបាន ម៉្លោះហើយខំចំណាយប្រាក់កាសរាប់រយរាប់ពាន់ដុល្លារ ដោយសារជំនឿភ័ន្តច្រឡំនេះ។ ព្រះសង្ឃដែលតាំងខ្លួនជាគ្រូសូត្រមន្ត ស្រោចទឹក ទស្សន៍ទាយនោះ ក្នុងមួយថ្ងៃៗត្រូវគេនិមន្តវាស់ល្ងាចបួនដប់ផ្ទះស្ទើរគ្មានពេលសម្រាក។ ផ្ទុយទៅវិញចំពោះព្រះសង្ឃអង្គណាដែលចេះធម៌អាថ៌ រហូតចេះធម៌ដែលធ្វើឱ្យមនុស្សបានសុខ ធ្វើមនុស្សឱ្យរៀនឆាប់ចេះដឹង ធ្វើមនុស្សឱ្យរកស៊ីមានបាន គ្មានឃើញខ្មែរទាំងនោះនិមន្តឱ្យជួយពន្យល់ណែនាំឡើយ។ ត្រង់នេះយើងពុំបដិសេធទាំងស្រុងថាការសូត្រមន្តនេះគ្មានប្រយោជន៍សោះទេ បានខ្លះដែរត្រង់ការលើកទឹកចិត្តធ្វើឱ្យមនុស្សមានសង្ឃឹម។ ប៉ុន្តែសង្ឃឹមខ្លះធ្វើឱ្យមនុស្សធ្វេសប្រហែស មិនបំពេញ

ការងារឱ្យបានម៉ត់ចត់ នាំឱ្យខូចប្រយោជន៍វិញក៏មាន។ តាមព្រះពុទ្ធសាសនា ផលសម្រេចគ្រប់យ៉ាងកើតពីការព្យាយាមធ្វើ ពុំមែនកើតឡើងក្រៅពីនេះឡើយ។ សូម្បីព្រះពុទ្ធក៏ព្រះអង្គមិនដែលសម្តែងថា តថាគតជួយអ្នកឱ្យប្រឡងជាប់ ឱ្យអ្នករកស៊ីមានបានដូច្នេះឡើយ។ ប៉ុន្តែព្រះអង្គគ្រាន់តែប្រាប់មធ្យោបាយបង្ហាញវិធីឱ្យរៀនសូត្រចេះចាំ ប្រឡងជាប់ រកស៊ីមានបានប៉ុណ្ណោះ ហើយទុកឱ្យគេជឿ ឬមិនជឿ អនុវត្តតាម ឬមិនអនុវត្តតាមដោយខ្លួនគេ។

អស្ចារ្យមួយទៀត នៅភ្នំពេញប្រទេសកម្ពុជា មានវត្តខ្លះដោយមនុស្សអ្នកសុំស្រោចទឹកច្រើនពេក ព្រះសង្ឃដែលធ្លាប់ស្រោចទឹកឱ្យគេ បើករ៉ូប៊ីណេបន្តបំពង់ស្រោចតែម្តង។ មានព្រះសង្ឃខ្លះនៅក្នុង និងក្រៅប្រទេសកម្ពុជា ស្រោចទឹកឱ្យស្ត្រីនៅក្នុងទីស្ងាត់ ទីកំបាំងតែពីរនាក់។ អំពើនេះខុសនឹងព្រះវិន័យធ្ងន់ណាស់ ព្រះសង្ឃត្រូវតែជៀសវាង។ បើជៀសពុំរួច គ្រាន់តែឱ្យទឹកមន្ត ហើយឱ្យគេយកទៅងូត ដោយខ្លួនគេទៅ។ ទឹកពុំអាចជួយអ្វីបានឡើយ ទឹកដែលព្រះសង្ឃរលាស់ទៅកាន់ពុទ្ធបរិស័ទនោះ គ្រាន់តែជានិមិត្តរូបជាមួយការផ្សាយចិត្តមេត្តាចិត្តចង់ឱ្យពុទ្ធបរិស័ទបានសុខចម្រើនប៉ុណ្ណោះ។ នៅពេលចម្រើនព្រះបរិត្តម្តងៗ គួររក្សាប្រពៃណីនេះចុះ ប៉ុន្តែកុំឱ្យធ្វើ និងអះអាងថាស័ក្តិសិទ្ធិ ឱ្យជ្រុលផ្ទុយពីការពិតរបស់ព្រះពុទ្ធសាសនា។

## សូត្រមន្តរំដោះគ្រោះ

មានជំនឿមួយទៀត គឺនិមន្តព្រះសង្ឃរំដោះគ្រោះ គឺនៅពេលដែលមានទុក្ខ មានជំងឺដម្កាត់បៀតបៀន មានបាត់បង់ទ្រព្យសម្បត្តិជាដើម។ កាលពីសម័យបុរាណ មុននឹងសូត្រមន្ត មានរៀបចំរណ្តាប់ច្រើនណាស់ ប៉ុន្តែមិនរៀបរាប់ក្នុងទីនេះទេ ព្រោះការរៀបរណ្តាប់នោះទាក់ទងនឹងជំនឿលើខ្មោចបិសាច សូមអធិប្បាយតែទៅលើសំណួរថា តើការសូត្រមន្តនេះអាចរំដោះទុក្ខបានឬទេប៉ុណ្ណោះ។

ព្រះពុទ្ធសម្តែងថា សេចក្តីទុក្ខបែបណាមួយកើតមាន ព្រោះអំពើបាបកម្មដែលខ្លួនបានកសាង។ បើចង់មិនឱ្យមានទុក្ខ ត្រូវឈប់សាងអំពើបាបតទៅទៀត ហើយសាងអំពើល្អ មានកាន់សីលប្រាំជាដើម។ ជាឱកាសល្អ ព្រះសង្ឃត្រូវពន្យល់ពុទ្ធបរិស័ទឱ្យយល់ចូលចិត្តអំពីការរំដោះទុក្ខតាមន័យរបស់ព្រះពុទ្ធសាសនា ពុំមែនសូត្រធម៌ឱ្យគេអស់ទុក្ខនោះឡើយ។ ព្រះសង្ឃត្រូវតែសាកសួរអំពីសេចក្តីទុក្ខ ហើយជួយដោះស្រាយសេចក្តីទុក្ខនោះ។ ជួនកាលសេចក្តីទុក្ខកើតពីការព្រួយចិត្តពីរឿងអ្វីមួយ ត្រូវជួយដោះស្រាយនូវហេតុដែលនាំឱ្យកើតទុក្ខ សេចក្តីទុក្ខត្រូវរំលត់ ដូចព្រះពុទ្ធបានសំដែងធម៌ចំពោះ **នាងបដាចា** ដែលកើតទុក្ខព្រោះកូន និងប្តីស្លាប់។ ព្រះពុទ្ធពន្យល់ឱ្យដកចិត្តចេញពីជនទាំងនោះ ព្រោះពួកគេស្លាប់ហើយ។ នាងយល់ព្រះធម៌បានដកចិត្ត តាមការណែនាំរបស់ព្រះពុទ្ធ។ សេចក្តីទុក្ខក៏ត្រូវរលត់ ព្រោះសេចក្តីទុក្ខរបស់នាងកើតអំពីសេចក្តីស្រឡាញ់។ បើមានវិបត្តិផ្លូវចិត្តបែបណាមួយ

ក៏ត្រូវប្រាប់មធ្យោបាយដោះស្រាយតាមយថាហេតុ។ បើមានជំងឺតាមផ្លូវកាយ ត្រូវដោះស្រាយទៅមន្ទីរពេទ្យដើម្បីព្យាបាលរោគ។ ការសូត្រធម៌មិនោះ គ្រាន់តែលើកកម្លាំងផ្លូវចិត្តប៉ុណ្ណោះ។ យើងក៏ធ្លាប់គេ និមន្តឱ្យសូត្រធម៌មិលើករាសី សូត្រធម៌មិរំដោះគ្រោះដែរ បានទទួលទៅសូត្រធម៌មិ ប៉ុន្តែតែងតែពន្យល់ណែនាំតាមន័យដូចពោលមកហើយ។

## ខ្សែកថា និង កន្សែងយ័ន្ត

ជំនឿខ្មែរខ្លះជំនាន់ដើម ឥឡូវនេះនៅមានខ្លះថា **កថា** និង **កន្សែងយ័ន្ត** អាចផ្តល់សេចក្តីសុខឱ្យគេ ជាពិសេសការពារកុំឱ្យសត្រូវបៀតបៀនដូចជាខ្មោចបិសាចបៀតបៀនមិនបាន គេធ្វើអំពើមិនត្រូវ បើធ្វើទាហានវិញ អាចបញ្ចៀសគ្រាប់ រហូតជឿថាគេបាញ់មិនត្រូវ ឬបាញ់មិនមុត។ តាមការសង្កេតការបង្កើតឱ្យមានកថា និងកន្សែងយ័ន្តជាពិធីសាស្ត្រមួយរបស់ចាស់បុរាណខ្មែរឱ្យមនុស្សធ្វើល្អ ព្រោះពេលដែលប្រគល់ខ្សែកថា និងកន្សែងយ័ន្តបាននិយាយថា ដើម្បីឱ្យខ្សែកថា និងកន្សែងយ័ន្តនេះពូកែស័ក្តសិទ្ធិត្រូវកាន់ត្រណមកុំប្រមាថមើលងាយគេ កុំរំលោភកូនប្រពន្ធអ្នកដទៃ ជាពិសេសឱ្យកាន់សីល៥។ ដោយចង់ឱ្យខ្សែកថា និងកន្សែងយ័ន្តពូកែស័ក្តិសិទ្ធិ ក៏កាន់ត្រណមទាំងនោះក៏បានសេចក្តីសុខ។ តាមពិតសេចក្តីសុខដែលគេបានទទួលនោះកើតឡើងពីការកាន់ត្រណម ពុំមែនដោយសារខ្សែកថា និងកន្សែងយ័ន្តនោះឡើយ។ នេះជាពិធីសាស្ត្រមួយផ្នែកដែលនាំឱ្យមនុស្សធ្វើល្អ។ បានសេចក្តីថា បើមិនកាន់ត្រណម

នោះទេ ក៏ពុំបានសេចក្តីសុខដែរ ព្រោះបើមិនរំលោភកូនប្រពន្ធអ្នកដទៃ មិនបានលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃជាដើមទេ អ្នកដទៃឬច្បាប់រដ្ឋពុំមានសិទ្ធិចាប់ចងធ្វើទោសមនុស្សនោះឡើយ។ នេះជាន័យពិតរបស់ព្រះពុទ្ធសាសនាដែលពោលថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ពុំមែនបណ្តាលមកពីខ្សែកថា និងកន្សែងយ័ន្តនោះឡើយ។ ព្រះសង្ឃអ្នកបួសក្នុងព្រះពុទ្ធសាសនាថេរវាទជាពិសេសព្រះសង្ឃខ្មែរ ពុំគួរអនុវត្តជំនឿនេះទេ ហើយពុទ្ធបរិស័ទខ្មែរពុំគួរជឿជំនឿនេះឡើយ។ ផ្ទុយពីនេះត្រូវនាំគ្នាសិក្សារៀនសូត្រធម្មវិន័យឱ្យយល់ច្បាស់លាស់ហើយប្រតិបត្តិតាមឱ្យបានត្រឹមត្រូវ។

## ជំនឿស្នេហ៍មុខ

ស្នេហ៍មុខជាជំនឿមួយដែលគេយល់ថា បើដាក់ទៅអាចឱ្យគេស្រឡាញ់ឱ្យគេចូលចិត្ត។ មនុស្សដែលចង់ឱ្យគេស្រឡាញ់ចូលចិត្តភាគច្រើន គឺអ្នករកស៊ីលក់ដូរ និងអ្នកដែលចង់បានគូស្រករប្រុសស្រ្តី ដែលហៅថាដាក់ស្នេហ៍។ ជំនឿនេះក៏មានមកតាំងពីបុរាណ ឥឡូវនេះក៏នៅមានខ្លះ។ គ្រូដែលតាំងខ្លួនថាចេះវិជ្ជាផ្នែកនេះ មានគ្រហស្ថ និងព្រះសង្ឃខ្លះ។ វិជ្ជានេះទាក់ទងនឹងសាសនាព្រាហ្មណ៍ មិនមានជារបស់ព្រះពុទ្ធសាសនាឡើយ។ បើនិយាយតាមព្រះពុទ្ធសាសនាវិញ ស្នេហ៍មុខដែលនាំឱ្យគេស្រឡាញ់ចូលចិត្ត គឺសម្តីទន់ភ្លន់ចរិយាសុភាពរាបសា ទឹកមុខញញឹមជានិច្ច ជាមួយនឹងទឹកចិត្តប្រកបដោយ **មេត្តា ករុណា** មានចិត្តល្អ ចេះជួយទុក្ខធុរៈអ្នកដទៃ។ មិនថាតែមនុស្សទេ

ដែលស្រឡាញ់ចូលចិត្ត សូម្បីសត្វតិរច្ឆានក៏ចូលមកជិតយកមនុស្សនោះជាមិត្ត ដែរ។ បើគ្រូដាក់ក្រមួនស្នេហ៍នៅមុខនៅមាត់ ហើយមានទឹកមុខក្រញូវ ដើរឈ្លោះគេឯង កំណាញ់ស្វិតស្វាញ ក្រមួនជួយពុំឈ្នះឡើយ ពិតជាគេស្អប់ មនុស្សនោះគេចាត់ថាជាមនុស្សគ្មានអំណាយទាន។

ដូច្នេះព្រះពុទ្ធសាសនាបានបញ្ជាក់យ៉ាងច្បាស់ហើយថា មនុស្សដែល គេស្រឡាញ់ឬស្អប់ មកអំពីអំពើរបស់ខ្លួនឯងវិញទេ។ ព្រះសង្ឃមិនត្រូវអនុវត្ត ជំនឿបែបនេះទេ ព្រោះផ្ទុយនឹងបញ្ញត្តិរបស់ព្រះពុទ្ធ ចាត់ជាតិរច្ឆានវិជ្ជា។ ពិសេសទៅទៀត ក្នុងព្រះវិន័យនិយាយថា បើភិក្ខុណែនាំបុរសស្ត្រីដែលគេឥត ស្រឡាញ់គ្នាសោះ ឱ្យបានគ្នាជាប្តីប្រពន្ធ ឬជាសង្សារ ភិក្ខុនោះត្រូវអាបត្តិមួយ យ៉ាងធ្ងន់។ ក៏ដូចគ្នានឹងភិក្ខុនិយាយបំបែកបំបាក់បុរសស្ត្រីដែលគេកំពុងស្រ-ឡាញ់គ្នា ឱ្យបែកបាក់គ្នា ក៏ត្រូវអាបត្តិមួយយ៉ាងធ្ងន់ដែរ។ សមនឹងសព្វថ្ងៃនេះ នៅប្រទេសកម្ពុជា បុរសខ្លះមានប្រពន្ធច្រើន ម្ល៉ោះហើយប្រពន្ធដើមប្រពន្ធចុង រកវិធីកំចាត់គ្នា ឬរកវិធីឱ្យប្តីស្រឡាញ់ខ្លួនជាងស្ត្រីមួយទៀត ហៅថារកគ្រូ ស្នេហ៍ ឬក៏បុរស ឬស្ត្រីស្រឡាញ់អ្នកណាម្នាក់ក៏រកគ្រូដាក់ស្នេហ៍។ បើព្រះសង្ឃ អង្គណាលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់គ្រួសារគេ ដែលហៅថាដឹកញីប្រសុី ឈ្មោលបែបនេះ ព្រះសង្ឃនោះពុំមែនជាសមណសក្យបុត្រឡើយ។

## **ការទស្សន៍ទាយ**

ការទស្សន៍ទាយនេះ មានក្បួនសម្រាប់ទស្សន៍ទាយ ដែលហៅថា **ព្រហ្មជាតិ** ។ គ្រាន់តែឃើញពាក្យថាព្រហ្មជាតិ យើងឃើញថា ពុំមែនជាព្រះពុទ្ធសាសនាទៅហើយ គឺចេញមកពីសាសនាព្រាហ្មណ៍ ដែលខ្មែរពីដើមធ្លាប់គោរពសាសនាព្រាហ្មណ៍ ដែលសព្វថ្ងៃហៅថា សាសនាហិណ្ឌូ នៅមានសេសសល់ជំនឿខ្លះក្នុងវប្បធម៌ខ្មែរ ។ តាមការសង្កេត ការទស្សន៍ទាយក្នុងព្រហ្មជាតិនោះ គឺការទាយទៅតាមថ្ងៃខែឆ្នាំកំណើតរបស់បុគ្គលមួយរូបៗ ។ ការទាយនេះ ជាការពិនិត្យសង្កេតជាមួយ និងការប៉ាន់ស្មានទូវថ្ងៃខែឆ្នាំដែលកើត មានត្រូវខ្លះខុសខ្លះ អាចថាត្រូវច្រើនជាងខុស ដែលមានលក្ខណៈខុសគ្នាពីព្រះពុទ្ធ គឺព្រះអង្គ មានញាណជ្រាបអំពីបុព្វចរិយារបស់មនុស្ស ។ ការទស្សន៍ទាយនេះ ព្រះពុទ្ធបានហាមភិក្ខុសង្ឃមិនឱ្យអនុវត្តការទាយនេះឡើយ ព្រោះការទាយនេះចាត់ចូលជា **តិរច្ឆានវិជ្ជា** ទោះបីទាយដោយវិធីផ្សេងពីនេះ មានការទាយមើលក្រយៅនិងអញ្ចាញដៃក៏ដោយ ហើយបរិក្ខារឬបច្ច័យដែលបានមកពីការទាយនេះ ជារបស់បានមកមិនប្រកបដោយធម៌ឡើយ ។ ពាក្យខ្មែរថា **ពាក្យសត្យ ពាក្យសច្ចៈ**។ ពាក្យថា **សត្យ** ជាពាក្យ សំស្ក្រឹត បាលីថា **សច្ចៈ** ប្រែថាពិត ។ គឺព្រះសង្ឃត្រូវនិយាយពិត ។ ចំណែកការទាយពុំមែនពាក្យពិតទាំងអស់ឡើយ កន្លែងខ្លះផ្សំនិយាយតម្រូវចិត្តអ្នកមកឱ្យទាយ ដើម្បីលាភសក្ការៈ ។ បើគេអនុវត្តខុសខូចប្រយោជន៍គេដោយជឿការទាយ ព្រះ

សង្ឃអ្នកទាយត្រូវមានទោសដោយប្រាប់គេពាក្យពុំពិត គេយកទៅធ្វើតាមខូចប្រយោជន៍គេ។ ឧទាហរណ៍ ការទាយថា បើតាមជើងលេខបុរស និងស្ត្រីនេះមានជើងលេខល្អអាចរៀបការជាប្ដីប្រពន្ធបាន។ ក្រោយពេលរៀបការហើយ ស្រាប់តែទាស់ទែងខ្វែងគំនិតគ្នា បាក់បែកគ្នា រស់នៅជាមួយគ្នាមិនកើតដោយជឿការទស្សន៍ទាយនេះឯង។ បើព្រះសង្ឃជាអ្នកទាយ ត្រូវមានទោសពីរយ៉ាង គឺទីមួយ ត្រូវអាបត្តិមួយយ៉ាងធ្ងន់ គឺ **អាបត្តិសង្ឃាទិសេស** ដោយការទស្សន៍ទាយឱ្យគេបានគ្នាជាប្ដីប្រពន្ធ ទីពីរ ត្រូវមានទោសព្រោះនាំឱ្យគេទាស់ទែងគ្នាដោយការជឿការទាយរបស់ខ្លួន។ បើទាស់គ្នាមានអំពើហិង្សាផងព្រះសង្ឃអ្នកទាយមានទោសធ្ងន់ទៅទៀត។

ចំពោះការរើសគូស្រករនេះ បើការទស្សន៍ទាយតាមផ្លូវព្រះពុទ្ធសាសនាវិញ គឺត្រូវពិនិត្យមើលចរិយាមារយាទ កម្រិតវិជ្ជាចេះដឹង កាយសម្បទាពូជអំបូរ ដោយខ្លួនឯងផ្ទាល់ តើបុរសនេះ ឬស្ត្រីនេះ យកមកជាគូស្រករបានល្អឬទេ។ ពាក្យខ្មែរក៏បាននិយាយថា ធ្វើស្រែឱ្យមើលស្មៅទុកដាក់កូនចៅអោយមើលផៅសន្ដាន។ បានជាសម័យដើមគេឱ្យកូនប្រុសមកបម្រើខាងស្ត្រីមួយឆ្នាំពីរឆ្នាំ ក្នុងគោលបំណងខាងស្ត្រីពិនិត្យមើលទឹកចិត្ត និងចរិយាខាងប្រុស។ ជួនកាលគេផ្ដាច់ចោល បើខាងស្ត្រីមិនពេញចិត្ត។ ជួនកាលគេរើសកូនប្រសារតែក្នុងភូមិជាមួយគ្នា ព្រោះធ្លាប់ស្គាល់ចិត្តគ្នា។ បើពិនិត្យមើលខ្លួនឯងហើយនៅតែខុសទៀត គេអស់ចិត្ត មិនសូវស្ដាយក្រោយ បើជឿទាយហើយខុសវិញ គេនឹកស្ដាយខ្លាំងណាស់។ ដូច្នេះគួរធ្វើការទស្សន៍ទាយតាមបែប

ព្រះពុទ្ធសាសនា គឺពិនិត្យមើលខ្លួនឯងឱ្យច្បាស់លាស់ មុននឹងសម្រេចបែបណាមួយ ។ នេះគ្រាន់តែជាឧទាហរណ៍រឿងមួយ ។

## សេចក្តីសន្និដ្ឋាន

ដូចបានរៀបរាប់មកហើយ ពុទ្ធសាសនិកជនខ្មែរបានចាត់ទុកព្រះសង្ឃជាគ្រូជាទីគោរពសក្ការៈរបស់ខ្លួន។ ដូច្នេះព្រះសង្ឃគប្បីបំពេញកាតព្វកិច្ចរបស់ខ្លួនពន្យល់ណែនាំពុទ្ធបរិស័ទឱ្យដើរតាមគន្លងធម៌ កុំធ្វើតាមជំនឿខ្លះដែលផ្ទុយនឹងព្រះពុទ្ធសាសនា ដូចបានពន្យល់ខ្លះមកហើយ។ ការនិមន្តសូត្រមន្តការកូនសូត្រមន្តឡើងផ្ទះ និងនិមន្តសូត្រមន្តក្នុងបុណ្យទានផ្សេងៗ ព្រះសង្ឃត្រូវនិមន្តតាមធម្មតា គ្រាន់តែធ្វើសំណូមពរថា សូមឆ្លៀតពន្យល់ធម៌អាថ៌ស្របតាមបុណ្យទានមុននឹងចាប់ផ្តើមសូត្រធម៌។ បើពុទ្ធបរិស័ទនិមន្តដោយប្រើពាក្យថា និមន្តសូត្រមន្តលើករាសី និមន្តសូត្ររំដោះគ្រោះ ក៏គួរទទួលនិមន្ត ប៉ុន្តែមុននឹងសូត្រ សូមពន្យល់ពុទ្ធបរិស័ទឱ្យប្រើចិត្តឱ្យបានត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនា។ ព្រោះពុទ្ធមន្ត គឺមន្តរបស់ព្រះពុទ្ធបានដល់ការយកធម៌របស់ព្រះអង្គមកប្រតិបត្តិ ទើបរាសីឡើង និងរំដោះគ្រោះបាន ។

# អបិយជំនឿផ្សេងៗ នៅកម្ពុជា

មានពុទ្ធបរិស័ទខ្មែរជាច្រើនដែលចង់ដឹងការពិតអំពីការបង្កើតជំនឿផ្សេងៗរបស់ខ្មែរខ្លះនៅប្រទេសកម្ពុជា ដូចជា **សម្តេចជួនណាត** ដឹងជាតិជាដើម តើត្រឹមត្រូវតាមការពិតរបស់ព្រះពុទ្ធសាសនាឬទេ?

ដោយចង់រក្សាតម្លៃរបស់ព្រះពុទ្ធសាសនា យើងសូមឆ្លើយទៅនឹងសំណួរខាងលើនេះ ដោយយោលទៅតាមព្រះពុទ្ធដីកា និងដោយចិត្តបរិសុទ្ធគ្មានបំណងបំផ្លាញផលប្រយោជន៍របស់ជនណាឡើយ ។

ជំនឿត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា គឺជំនឿលើកម្មផល ។ ជំនឿប្រាសចាកការពិតនាំឱ្យមានវិបត្តិឧបាសកឧបាសិកា ដូចជាវិបត្តិទីបីនៃវិបត្តិទាំងប្រាំគឺ **កោតុហល មង្គលិកោ ហោតិ** ប្រែថា ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល ។ គឺមានជំនឿទៅលើហេតុការណ៍ណាមួយដែលប្រាសចាកការពិតដែលគេប្រឌិតឡើង ដើម្បីគោលដៅអ្វីមួយ មានដើម្បីលាភសក្ការៈ និងដើម្បីគោលដៅនយោបាយ ដោយមធ្យោបាយដែលយកមកប្រើស្របទៅតាមជំនឿរបស់ខ្មែរ ។

ក្នុង **កាលាមសូត្រ** ព្រះពុទ្ធសំដែងកុំឱ្យជឿតាមអាការ១០យ៉ាង មានមិនឱ្យប្រកាន់ជឿដោយឮតាមគ្នា ដោយការនឹកស្មាន ដោយការសន្និដ្ឋាន គឺដោយការចូលចិត្តតាមអាការខាងក្រៅជាដើមឡើយ ។ ប៉ុន្តែមុននឹងជឿជាយ៉ាងណា ត្រូវពិនិត្យពិចារណា និងធ្វើការពិសោធ ឱ្យបានល្អិតល្អន់ជាមុនសិន ។

យ៉ាងណាមិញ ពុទ្ធសាសនិជនខ្មែរបើឮការឃោសនារឿងអ្វីមួយ កុំអាលជឿ មុនពិចារណារកការពិត បើមិនទាន់ច្បាស់លាស់ខ្លួនឯងទេ គួររកជំនួយសាកសួរអ្នកចេះដឹងព្រះពុទ្ធសាសនាច្បាស់លាស់ ព្រោះជំនឿខុសអនុវត្តខុសនាំឱ្យខូចប្រយោជន៍ មាននាំឱ្យខាតបង់ទ្រព្យសម្បត្តិជាដើម។ ពេលនេះយើងលើកយកតែអបិយ៍ជំនឿខ្លះនាំឱ្យខូចប្រយោជន៍សាធារណជន និងនាំឱ្យខូចតម្លៃរបស់ព្រះពុទ្ធសាសនាមករៀបរាប់ដូចតទៅនេះ :

មុននឹងលើកយកបញ្ហាសម្ដេចជួនណាតដឹងជាតិ នៅទូលព្រះរាជា យើងសូមលើកយករឿងរ៉ាវជាអបិយជំនឿខ្លះ ដែលបានកើតឡើង ហើយឥឡូវនេះបានបាត់បង់ទៅវិញហើយ។

គ្រួសារខ្មែរមួយនៅប្រទេសកម្ពុជា បានឃោសនាអំពីកូនគោរបស់ខ្លួនដែលទើបនឹងកើតថាជាព្រះគោ ដោយគោនោះកើតមកគ្មានដុះរោម។ អ្នកស្រុកខ្លះជឿបាននាំគ្នាទៅថ្វាយបង្គំសុំសេចក្ដីសុខ មានអ្នកខ្លះត្រងយកទឹកនោមកូនគោនោះទៅធ្វើជាថ្នាំ។ អ្នកម្ចាស់គោក៏បានលាភសក្ការៈខ្លះ។ សេចក្ដីពិត កូនគោដែលគ្មានរោមនោះ ជាគោមានកាយសម្បទាពុំគ្រប់គ្រាន់ ចាត់ជាគោអភ័ព្វ ជាគោពិការដែលយូរៗមានមួយ ជាការធម្មតាពុំមែនចម្លែកអ្វីឡើយ ពុំគួរជឿថាជាអ្នកមានបុណ្យឡើយ។

មួយទៀត ព្រះគោព្រះកែវគឺជារឿងមួយដែលគេតែងក្នុងសម័យលង្វែក ពេលដែលសៀមចូលឈ្លានពានប្រទេសកម្ពុជា។ ព្រះគោជាតំណាងគម្ពីរក្បួនច្បាប់របស់ខ្មែរដែលសៀមប្រមូលយកទៅ។ ឯព្រះកែវជាតំណាង

អ្នកប្រាជ្ញខ្មែរដែលសៀមនាំយកទៅ ព្រោះសៀមចង់បានគម្ពីរក្បួនច្បាប់ និងអ្នកប្រាជ្ញខ្មែរ ដើម្បីយកទៅជួយអភិវឌ្ឍប្រទេសគេឱ្យលូតលាស់ចម្រើន។ មិនយូរប៉ុន្មានជំនឿនេះ បានសាបរលាបទៅវិញ ប៉ុន្តែអ្នកស្រុកខ្លះបានខាតបង់ទ្រព្យសម្បត្តិដោយផ្តល់ឱ្យអ្នកម្ចាស់កូនគោ ដោយសារជំនឿខុស។

រឿងលោកតាល្ងង់អាយុវែង ជារឿងមួយដែលលោកតាចាស់ម្នាក់នៅប្រទេសកម្ពុជា បានតាំងខ្លួនឯងថាតាល្ងង់អាយុវែង ហើយបើអ្នកណាជឿគាត់ អ្នកនោះនឹងបានសេចក្តីសុខ។ គាត់និយាយថា គាត់តែងតែទាក់ទងជាមួយព្រះឥន្ទ្រ បើគាត់ចង់ដឹងអ្វីមួយតែងតែសួរព្រះឥន្ទ្រ។ មានអ្នកជឿខ្លះនាំគ្នាទៅសុំសេចក្តីសុខពីគាត់ ដោយយកវត្ថុផ្សេងៗ និងប្រាក់ខ្លះទៅជូនគាត់ ឱ្យគាត់សូត្រធមមិជូនពរ, លាភសក្ការៈក៏កើតឡើងដល់គាត់យ៉ាងច្រើន រហូតគាត់ធ្វើបានប្រាសាទ និងផ្ទះជាច្រើនខ្នង។ ក្រោយមកបានត្រូវសាបទៅវិញ ប៉ុន្តែធ្វើឱ្យអ្នកជឿ ជាពិសេសអ្នកជឿច្រើននៅបរទេសត្រូវចំណាយប្រាក់ជាច្រើន។ សូមពិនិត្យមើលអ្នកជឿ គាត់បានប្រាប់ថាគាត់ជាមនុស្សល្ងង់ ហេតុអ្វីបានជាជឿមនុស្សល្ងង់ តើមនុស្សល្ងង់អាចជួយអ្វីបាន? ព្រះពុទ្ធសម្តែងថា សេចក្តីសុខទុក្ខ ចម្រើនវិនាស ត្រូវស្ថិតនៅលើអំពើរបស់ខ្លួនបើចង់បានសេចក្តីសុខត្រូវសាងល្អ ពុំអាចសុំសេចក្តីសុខពីអ្នកដទៃ ដូចពីតាល្ងង់បានឡើយ។

មានបុរសម្នាក់តាំងខ្លួនជាតាបសនៅភ្នំច្បារអំពៅ បាននិយាយថា បើគេយកវត្ថុផ្សេងៗទៅកប់ក្នុងដីបានចំនួនពីរបីឆ្នាំ នឹងក្លាយជាមាស។ មានខ្មែរខ្លះជាពិសេសខ្មែរនៅបរទេស ដោយឃើញការឃោសនាតាមរយៈវីដេអូ

ដោយចង់បានមាស ក៏យកវត្ថុផ្សេងៗតាមការតម្រូវការរបស់គាត់ទៅកប់ក្នុងដី។ លុះគ្រប់ឆ្នាំតាមការកំណត់ ក៏ទៅគាស់មើលមិនឃើញមាស ឃើញតែវត្ថុនោះក្លាយជាចំណីដី សូម្បីសារមន្ទីរដែលបុរសនោះបានឱ្យគេកសាងពីដី ក៏ត្រូវរបេះបាក់ស្រុតហើយរលំ។ ទំរាំតែដឹងថាខ្លួនជឿខុស បានត្រូវចំណាយអស់ប្រាក់ជាច្រើន ទីបំផុតបុរសតាំងខ្លួនជាតាបសនោះប្រមូលបានប្រាក់ជាច្រើនហើយរត់គេចខ្លួនបាត់ទៅ។ នេះជាជំនឿខុសដោយមិនបានពិចារណាថា តើវត្ថុផ្សេងៗ ដូចជាល្ពៅ គ្រឿងធ្វើពីឈើជាដើម កប់ទៅអាចក្លាយជាមាសបានឬទេ?

មានបុរសម្នាក់នៅកម្ពុជា តាំងខ្លួនថាព្រះពុទ្ធមកចូលរូប។ ក្នុង **ភទ្ទកប្ប** នេះមានព្រះពុទ្ធត្រាស់ដឹង៥ព្រះអង្គ គឺ **ព្រះពុទ្ធព្រះនាម ព្រះកក្កុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ព្រះសមណគោត្តម** និង **ព្រះសិរិអារ្យ-មេត្រីយ៍** ដែលនឹងបានត្រាស់ពេលខាងមុខ។ នៅពេលបុរសនោះចូលរូប ព្រះពុទ្ធព្រះនាមព្រះកក្កុសន្ធោបាននិយាយទៅកាន់ព្រះពុទ្ធត្រាស់ក្រោយមកទៀតថា លោកប្អូនដូចលោកប្អូនព្រះពុទ្ធកោនាគមនោជាដើម។ ពុំអាចជាការពិតដូច្នេះឡើយ ព្រោះព្រះពុទ្ធបានរលត់ខន្ធបរិនិព្វានហើយ មិនត្រឡប់មកភពថ្មីទៀតឡើយ គឺពុំមានព្រះវិញ្ញាណមកសណ្ឋិត ឬមកចូលរូបដូចជាបិសាចដូច្នេះឡើយ។

# ពាក្យឃោសនា សម្តេចដូនឈាតដឹងជាតិ

បុរសម្នាក់ឈ្មោះ **ឆាន-ខុន្ធី** អាយុ៣១ឆ្នាំក្នុងឆ្នាំ២០០៧នេះ បានកសាងវត្តទួលព្រះរាជា ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា។ លោក **ឆាន-ខុន្ធី** មិនបានបួសទេ នៅជាគ្រហស្ថ ស្លៀកពាក់សហើយទុកសក់ដូចគ្រហស្ថធម្មតា។ សព្វថ្ងៃនៅក្នុងវត្តមានព្រះសង្ឃជាង២០អង្គ ដែលបំបួសដោយលោក **ឆាន-ខុន្ធី**។ ដោយឆ្លើយតបទៅនឹងសំណួរដែលគេចង់ដឹងអំពីភាពខុសប្រក្រតី ដែលគ្រហស្ថបំបួសព្រះសង្ឃ លោក **ឆាន-ខុន្ធី** ឆ្លើយថា គាត់ជាអ្នកមានបុណ្យ គាត់បានសម្រេចធមិជាន់ខ្ពស់ គ្មានព្រះសង្ឃណាអាចធ្វើឧបជ្ឈាយ៍គាត់បានទេ គាត់អាចបំបួសព្រះសង្ឃបាន។ នេះជាសម្តីរបស់អ្នកដែលគាំទ្រគាត់និយាយប្រាប់។ សូមពុទ្ធបរិស័ទទាំងឡាយពិចារណាមើល តើមានអ្នកជំនាញការខាងព្រះពុទ្ធសាសនា ឬគណៈកម្មការឯកទេសខាងព្រះពុទ្ធសាសនាឱ្យតម្លៃថា គាត់ជាអ្នកមានបុណ្យ បានសម្រេចធមិជាន់ខ្ពស់ពិតមែន ក្រៅពីការឱ្យតម្លៃតែខ្លួនគាត់។ មួយទៀតគ្រហស្ថជាហីនភេទពុំអាចបំបួសព្រះសង្ឃជាឧត្តមភេទបានឡើយ គឺផ្ទុយនឹងពុទ្ធប្បញ្ញត្តិ។ គ្រឿងអលង្ការមាសពេជ្រខ្លះថាជាកែវមុនីជោតិ ដូចជាចិញ្ចៀនបន្តោងខ្សែកកងដៃ និងគ្រឿងអលង្ការផ្សេងៗទៀតជាច្រើន បានយកមកលក់ពាសពេញនៅបរទេស។ អ្នកដែលយកមកលក់នេះ អះអាងថាបានមកពីទួលព្រះរាជា។ គ្រឿងអលង្ការទាំងនោះមានតម្លៃរាប់រយដុល្លារ។ អ្នកលក់បានឃោសនាថា

កែវមុនីជោតិនេះស័ក្តិសិទ្ធិណាស់ អ្នកណាជាវនឹងបានសុខចម្រើន ព្រោះគ្រឿងទាំងនោះពុំមែនកើតឡើងដោយធម្មតាទេ គឺកើតឡើងដោយព្រះអង្គម្ចាស់ **ឆាន-ទុន្ធី** យកមកពីភ្នំ។ សូមពុទ្ធបរិស័ទទាំងឡាយពិចារណា តើគ្រឿងអលង្ការទាំងនោះពិតជាបានមកពីភ្នំ ឬពួកទេតាប្រទានឱ្យគាត់ តើគួរជឿបានឬទេ? តើភ្នំឯណាដែលមានគ្រឿងអលង្ការទាំងនោះ ហេតុដូចម្តេចបានជាអ្នកដទៃទៀតមិនឃើញ? អ្នកជំនាញការខាងគ្រឿងអលង្ការអាចពិនិត្យមើលដឹងការពិតថាជាគ្រឿងអលង្ការពិតមកពីភ្នំ ឬជាគ្រឿងអលង្ការគេកាឡៃច្នៃនៅភ្នំពេញ ឬនៅសហរដ្ឋអាមេរិក។ ពាក្យឃោសនាថាពាក់ទៅបានសុខចម្រើន ជាពាក្យមិនស្របតាមន័យរបស់ព្រះពុទ្ធសាសនាឡើយ ព្រោះព្រះពុទ្ធពុំដែលសម្តែងថាវត្ថុផ្សេងៗមានគ្រឿងអលង្ការនេះជាដើម ថាឱ្យសុខដល់មនុស្សក្រៅពីអំពើល្អរបស់ខ្លួនឡើយ។ នេះជាការឃោសនានាំឱ្យពុទ្ធបរិស័ទខ្មែរភ័ន្តច្រឡំ។ ចំពោះបញ្ហាថាប្រាក់ដែលបានមកពីការលក់ដូរ គឺយកទៅកសាងកុដិ ព្រះវិហារ និងព្រះពុទ្ធរូបយ៉ាងធំៗ ដើម្បីឱ្យព្រះពុទ្ធសាសនាល្អលាស់ចម្រើនទេតើ។ គេឃើញមានការកសាងដូច្នេះមែន ប៉ុន្តែចំនួនប្រាក់ផ្សេងពីនេះដែលមិនបានយកទៅកសាងគ្មានគណៈកម្មការណាពិនិត្យឱ្យដឹងការពិតឡើយ។

គេឃើញរូបលោក**ឆាន-ទុន្ធី**ផ្តិតភ្ជាប់ជាមួយព្រះឆាយាលក្ខណ៍សម្តេច**ជួន-ណាត** ដែលគេយកមកផ្សាយនៅបរទេស។ ត្រង់ថាគាត់ពីដើមជាសម្តេច **ជួន-ណាត** ឬពុំមែនការពិតទេនោះគ្មានអ្នកជំនាញការខាងព្រះ

ពុទ្ធសាសនាណាថាទេ ក្រៅពីខ្លួនគាត់ថាខ្លួនគាត់។ ឥឡូវនេះ គេឃើញរូបមួយ ប្លែកទៀត គឺរូបលោក**ឆាន-ទុន្ធី** ដាក់ចំកណ្ដាលព្រះពុទ្ធរូបទាំង៤ព្រះអង្គ ដែលជាសញ្ញាបញ្ជាក់ថា ខ្លួនគាត់ជា**ព្រះសិអារ្យមេត្រីយ៍** ។ សូមបញ្ជាក់ថា ក្នុងភទ្ទកប្បមានព្រះពុទ្ធត្រាស់៥អង្គ ឥឡូវនេះបានត្រាស់៤ព្រះអង្គ ហើយនៅសល់មួយព្រះអង្គទៀត នឹងត្រាស់នៅពេលខាងមុខ គឺព្រះសិអារ្យមេត្រីយ៍ ដែលគេដាក់រូបលោក **ឆាន-ទុន្ធី** នៅចំកណ្ដាលនេះឯង។ បើតាមរូបភាព ដែលគេយកមកផ្សាយនៅបរទេសនេះបញ្ជាក់ថា ឆាកទីមួយ គឺលោក **ឆាន-ទុន្ធី**ជាសម្ដេច**ជួន-ណាត** ឥឡូវឆាកនេះជិតសាបហើយ ក៏បង្កើតឆាកមួយទៀត គឺគាត់ជាព្រះសិអារ្យមេត្រីយ៍។

បើយោងតាមព្រះពុទ្ធសាសនាផ្នែកសមោធាន៨យ៉ាង ដែលអាចទៅជាព្រះពោធិសត្វបាន គឺក្នុងអត្តភាពបច្ចុប្បន្នអាចសម្រេចជាព្រះអរហន្ត បានជួបនឹងព្រះពុទ្ធអង្គណាមួយ បានបួសក្នុងសាសនាព្រះពុទ្ធជាដើម ដូចជាព្រះសុមេធតាបស មានទំនាយពីព្រះពុទ្ធថា តាបសនេះនៅអនាគតនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមព្រះសមណគោតម។ ដូច្នេះលក្ខខណ្ឌនេះ ពុំមានក្នុងលោក **ឆាន-ទុន្ធី** នៅទូលព្រះរាជាឡើយ។ ប៉ុន្តែមានលោកតាម្នាក់ដែលគាំទ្រទូលព្រះរាជាបានពោលថា លោក **ធាន-វុទ្ធី** ពុំទាន់តាំងខ្លួនជាព្រះសិអារ្យមេត្រីយ៍នៅឡើយទេ បើមានរូបភាពបែបនេះពុំមែនចេញពីគាត់ឡើយ។

អំពីការឃោសនាបុណ្យកឋិននៅបរទេសយកទៅទូលព្រះរាជា បើតាមអ្នកផ្សាយរកអ្នកដើមបុណ្យកឋិនឆ្នាំ២០០៧នេះនិយាយថា គេរកបាន

ប្រាំពាន់រៀល-ទៅមួយម៉ឺនរៀល ២០០ដុល្លារ/ក្នុង១រៀល អ្នកឃោសនាបាននិយាយថា បើបងប្អូនណាបានទទួលធ្វើបុណ្យកឋិន នឹងបានបុណ្យទាន់ហន់ ហើយនឹងបានជួបព្រះសិអារ្យមេត្រីយ៍ ព្រោះលោក ធាន-វុទ្ធី ជាតួអង្គព្រះសិអារ្យមេត្រីយ៍។ យើងពុំប្រឆាំងនឹងការធ្វើបុណ្យកឋិនទាន ប៉ុន្តែយើងមិនយល់ស្របចំពោះការឃោសនារបៀបនេះ ព្រោះជារឿងពុំពិត នាំឱ្យពុទ្ធបរិស័ទខ្មែរភ័ន្តច្រឡំ ខូចតម្លៃព្រះពុទ្ធសាសនា បើនិយាយបែបនេះមែន។

បញ្ហាមួយអំពីការក្រាលគ្រងបុណ្យកឋិននេះ បើគាត់ក្រាលគ្រងកឋិនដោយខ្លួនឯងក្តី ប្រគេនព្រះសង្ឃឱ្យក្រាលកឋិនក្តី មិនឡើងជាកឋិនឡើយ ព្រោះខុសពីវិន័យបញ្ញត្តិរបស់ព្រះពុទ្ធ។ តាមព្រះវិន័យ មិនថាគ្រហស្ថទេដែលមិនអាចគ្រងកឋិន សូម្បីសាមណេរក៏មិនអាចក្រាលគ្រងកឋិនបានឡើយ។ មួយទៀត បើការបំបួសនោះមិនឡើងជាភិក្ខុ ព្រះសង្ឃទាំងនោះក៏មិនអាចក្រាលឱ្យឡើងជាកឋិនបានឡើយ ។

បញ្ហាមួយទៀត គេមើលវីដេអូដែលថតមកពីទូលព្រះរាជា លោក ធាន-វុទ្ធី បានពោលថាពលរដ្ឋខ្មែរមិនបាច់ព្រួយបារម្ភទេ បន្តិចទៀតអ្នកមានបុណ្យនឹងចេញមកហើយ របស់ដែលបាត់បង់ទៅមានទឹកដីជាដើម នឹងបានមកខ្មែរវិញ។ បើពាក្យដែលគេប្រាប់នេះ គាត់ពោលពិតមែននោះ គួរឱ្យស្តាយ ព្រោះផ្ទុយពីពាក្យរបស់ព្រះពុទ្ធគឺ ព្រះពុទ្ធសម្តែងថាសេចក្តីសម្រេចគ្រប់យ៉ាងកើតមកពីសេចក្តីព្យាយាម មិនខ្ជិលច្រអូសដេកចាំសំណាង។ មិនថាតែដីដែល

បាត់បង់ទៅដែលមិនត្រូវបានមកខ្មែរវិញ សូម្បីតែទឹកដីក្នុងព្រំដែនបច្ចុប្បន្ននេះ ប្រទេសទាំងពីរកំពុងតែរំកិលចូលមកដីខ្មែរជាបន្តមកទៀត។

ចំពោះបញ្ហាទូលព្រះរាជានេះ ក្រសួងធម្មការ និងកិច្ចការសាសនា និងក្រសួងសង្ឃរាជគ្មានប្រតិកម្មអ្វីទាំងអស់។ យើងយល់ថា មានអ្នកធំជាន់ខ្ពស់នៅពីក្រោយ បើទោះបីគេដឹងថាមានការខុសឆ្គងខ្លះតាមផ្លូវព្រះពុទ្ធសាសនា ក៏គេត្រូវតែបិទភ្នែក ព្រោះវាមានប្រយោជន៍បែបណាមួយ។ ចំពោះយើងវិញ យើងចង់ឱ្យព្រះពុទ្ធសាសនាលូតលាស់ចំរើនក្នុងភាពបរិសុទ្ធ។ មួយទៀត យើងមិនយល់ស្របធ្វើសំណង់តាមព្រះឥន្ទ្រប្រាប់ ឬតាមគំនិតខ្លួនផ្ទុយពីពុទ្ធប្បវត្តិនិងស្ថាបត្យកម្មខ្មែរ ដែលធ្វើឱ្យបច្ច័យដែលគេយកទៅបូជា ប្រែជាគ្មានន័យ។

# អង្គការមនុស្សធម៌ខ្លះបំផ្លាញវប្បធម៌ខ្មែរ

យើងសង្កេតឃើញថា នៅពេលដែលប្រទេសកម្ពុជាឆ្លងពីវិបត្តិមួយទៅវិបត្តិមួយ គឺសង្គ្រាមបង្ហូរឈាម ការសម្លាប់រង្គាល ការរំលោភឈ្លានពានពីបរទេស ការរំលោភសិទ្ធិប្រជាពលរដ្ឋជាដើម បានបន្សល់ទុកនូវកុមារកំព្រា មនុស្សពិការ ស្ត្រីមេម៉ាយ ភាពអវិជ្ជាមិនចេះអក្សរ និងភាពក្រីក្រ។ ឆ្លៀតឱកាសនោះ មានអង្គការមនុស្សធម៌បរទេសនានាមកជួយសង្គ្រោះប្រជាពល-រដ្ឋខ្មែរដែលមានទុក្ខទាំងនោះ។ អង្គការមនុស្សធម៌ទាំងនោះ មានពីរប្រភេទមានគំនិតផ្សេងគ្នា គឺអង្គការមនុស្សធម៌មួយប្រភេទមានគំនិតបំពេញនាទីរបស់ខ្លួនស្របតាមឈ្មោះខាងលើ គឺមានករុណាធម៌អាណិតអាសូរប្រជាពល-រដ្ឋខ្មែរដែលមានទុក្ខ បានចូលទៅជួយដោយផ្តល់អំណោយមនុស្សធម៌ពិតប្រាកដ ទាំងខាងសម្ភារៈ ទាំងខាងបញ្ញាស្មារតី ដោយមិនធ្វើឱ្យប៉ះពាល់ដល់វប្បធម៌របស់ជនជាតិខ្មែរឡើយ។ ផ្ទុយទៅវិញ អង្គការមនុស្សធម៌មួយប្រភេទទៀត មានសកម្មភាពផ្ទុយពីនេះ គឺធ្វើចលនាខុសពីនាទីរបស់ខ្លួនដោយយកអំណោយខ្លះទៅចែកប្រជាពលរដ្ឋខ្មែរ គ្រាន់តែជារបាំងបិទមុខ ឬជានុយសម្រាប់ទាក់ទាញទឹកចិត្តប្រជាពលរដ្ឋឱ្យលះបង់សាសនាដើមរបស់ខ្លួនគឺព្រះពុទ្ធសាសនា ហើយចូលកាន់សាសនាដទៃទៀត។ ក្រុមសាសនាជាច្រើនដែលកំពុងធ្វើចលនានៅប្រទេសកម្ពុជានោះ គេកត់សម្គាល់ឃើញថាសាសនាគ្រិស្តមានចលនាខ្លាំងជាងគេ ព្រោះក្រុមសាសនានេះមានមធ្យោបាយច្រើនជាងសាសនា

ដទៃទៀត។ ល្បិចដែលសាសនានេះយកទៅប្រើ គឺគេយកអំណោយទៅចែក ហើយប្រាប់ប្រជាពលរដ្ឋខ្មែរថា នេះជាអំណោយរបស់ព្រះជាម្ចាស់ ចូរលះបង់ព្រះពុទ្ធសាសនាហើយកាន់គ្រិស្តសាសនាវិញ បងប្អូននឹងបានអំណោយជាបន្តទៅទៀត។ កន្លែងខ្លះគេជួយព្យាបាលជម្ងឺប្រជាពលរដ្ឋខ្មែរ ហើយពោលថាព្រះយេស៊ូនឹងជួយឱ្យជា ចូរនឹកដល់ព្រះជាម្ចាស់ តែបើបែរជាពុំជាស្លាប់ទៅវិញគេជួយយកទៅបូជាហើយប្រាប់គ្រួសារសពថា គ្រួសារអ្នកឯងស្លាប់ទៅបានឡើងស្ថានសួគ៌ស្ថិតនៅជាមួយព្រះហើយ។ ពាក្យនេះផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្រះអង្គមានព្រះពុទ្ធដីកាថា សេចក្តីសុខទុក្ខ ចម្រើនវិនាស សួគ៌នរក និព្វាន កើតឡើងអំពីអំពើរបស់ខ្លួន (**កម្មស្សកោម្ហិ**) ពុំមែនព្រះជាម្ចាស់ឯណាទេ។ មធ្យោបាយទាក់ទាញមួយទៀត គឺការបង្រៀនភាសាអង់គ្លេស និងការធ្វើកម្មវិធីឱ្យសប្បាយផ្សេងៗក្នុងផ្លូវកាមគុណ មានការរាំការច្រៀងជាដើម ដើម្បីទាក់ទាញយុវជន និងយុវនារីខ្មែរ ឱ្យបំភ្លេចវប្បធម៌ និងទំនៀមទម្លាប់ដើមរបស់ខ្លួនដែលមានព្រះពុទ្ធសាសនាជាមូលដ្ឋាន មានមិនឱ្យដឹងគុណមាតាបិតា ឱ្យដឹងគុណតែព្រះជាម្ចាស់គឺព្រះយេហូវ៉ា ដែលមានព្រះយេស៊ូជាបេសកជនព្រោះព្រះអង្គបង្កើតអ្វីទាំងអស់។ ដូច្នេះសាសនាគ្រិស្តកំពុងតែព្យាយាមសម្លាប់ព្រលឹងខ្មែរហើយ។ មតិទូទៅដែលកំពុងតែតាមដានដោយយកចិត្តទុកដាក់នោះ គឺត្រង់សាសនាគ្រិស្តកំពុងតែបំពេញសកម្មភាពដោយឥតអៀនខ្មាស ដោយពុំកោតញញើតនឹងច្បាប់អន្តរជាតិ គឺការប្រើល្បិចលួងលោមកុមារខ្មែរនៅតូចដែលជាវ័យពុំទាន់ចេះពិចារណា ពុំអាចទទួលខុស

ត្រូវតាមផ្លូវច្បាប់ ឱ្យលះបង់សាសនាដូនតារបស់គេឱ្យជឿសាសនាខ្លួន។ ទង្វើនេះជាការរំលោភច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស។ ក្រុមផ្សាយសាសនាគ្រិស្តគប្បីគិតថា បើមានអ្នកផ្សាយសាសនាដទៃមកលួងលោមអូសទាញកូនចៅរបស់ខ្លួន ដែលកាន់សាសនាគ្រិស្តឱ្យទៅកាន់សាសនាដទៃវិញ ក៏ខ្លួនមិនអនុញ្ញាតឱ្យគេធ្វើដូច្នេះ ហើយនឹងធ្វើវិធីទប់ទល់ដូចគ្នាដែរ ព្រោះប្រជាជាតិនីមួយៗតែងតែរក្សាការពារសាសនារបស់ខ្លួនរៀងៗខ្លួន មិនចង់ឱ្យសាសនារបស់ខ្លួនបាត់បង់ដូចគ្នា។ ក្រុមអ្នកផ្សាយសាសនាគ្រិស្តតែងឃោសនាថា ខ្លួនជាអ្នកផ្សាយដំណឹងល្អ ជួយមនុស្សវង្វេងដែលមិនជឿព្រះ។ ខ្លួនថាសាសនាខ្លួនល្អ គេក៏ថាសាសនាគេល្អដែរ។ ដូច្នេះទុកសាសនាដែលខ្លួនថាល្អនោះសម្រាប់ខ្លួនឯងទៅចុះ កុំរំលោភសិទ្ធិខាងជំនឿដោយវិធីលួងលោមទឹកចិត្តបែបនេះ។ ទាក់ទងនឹងការផ្សាយគ្រិស្តសាសនានេះ មានមធ្យោបាយមួយដែលអ្នកផ្សាយគ្រិស្តសាសនាយកទៅប្រើ គឺនៅជនបទមួយនៅប្រទេសថៃដែលសម្បូរដោយអ្នកជឿអបិយជំនឿ គឺជំនឿមិនសមហេតុផល អ្នកផ្សាយគ្រិស្តសាសនាបានដឹងដូច្នេះ ក៏ប្រើល្បិចឱ្យមនុស្សម្នាក់ធ្វើពុតជាឈឺ ហើយឱ្យមនុស្សម្នាក់ទៀតធ្វើជាចូលរូបឱ្យនិយាយថា អ្នកដែលឈឺនោះមកពីពុំជឿព្រះយេស៊ូ ហើយគេឱ្យគ្នាគេម្នាក់ទៅនិយាយថា ឥឡូវនេះអ្នកឈឺនោះសុខចិត្តជឿព្រះយេស៊ូហើយសូមឱ្យជាទៅ។ រំពេចនោះគ្នាគេដែលធ្វើពុតជាឈឺនោះ ក្រោកឡើងសម្តែងអាការថាខ្លួនជាហើយ។ ល្បិចបោកបញ្ឆោតនេះបានធ្វើឱ្យអ្នកស្រុកថៃនៅជនបទនោះពុំដឹងការពិត ក៏ចូលកាន់សាសនាគ្រិស្តមួយភាគធំ។ រឿងដូចគ្នា

នេះដែរនៅស្តាតអូឡាំពិកទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា អាចារ្យប្រដៅគ្រិស្តសាសនានិយាយឃោសនាថា ព្រះយេស៊ូជួយមនុស្សខ្វាក់ឱ្យភ្លឺ មនុស្សគឱ្យនិយាយបាន មនុស្សថ្លង់ឱ្យស្តាប់ឮជាដើម។ និយាយមិនបានប៉ុន្មានម៉ាត់ផងកំហឹងប្រជាពលរដ្ឋខ្មែរអ្នកស្តាប់បានកើតឡើង ដោយសង្កេតឃើញការពុំពិតជាមួយនឹងសកម្មភាពអំពើហិង្សាដុតពាក្យស្លោកដែលបិទជុំវិញស្តាត លោកអាចារ្យគ្រិស្តរត់គេចខ្លួនស្ទើរតែមិនទាន់។ តាមពិត ព្រះពុទ្ធសាសនាមិនត្រូវប្រើអំពើហិង្សាទេ ប៉ុន្តែទំនងជាប្រជាពលរដ្ឋខ្មែរមានកំហឹង ដល់កទប់ពុំបានព្រោះខ្លះបានលក់គោលក់ក្របីលក់របស់របរផ្សេងៗ ខ្លះខ្ចីប្រាក់គេដោយខ្លួនជាអ្នកក្រីក្រ បានប្រាក់សម្រាប់ចំណាយការធ្វើដំណើរពីស្រុកស្រែចំការមកក្រុងភ្នំពេញ ស្តាប់អាចារ្យគ្រិស្តក្រែងខ្លួនបានជារោគបានជាពីពិការ តែពុំបានសម្រេចដូចបំណង ឯប្រាក់ក៏អស់ ក៏កើតការក្តៅក្រហាយនេះឡើង ណាមួយក្តៅក្រហាយនឹងអាជ្ញាធរខ្មែរពុករលួយឱ្យច្បាប់ឱ្យអាចារ្យគ្រិស្តនេះនិយាយបោកប្រាស់ប្រជាពលរដ្ឋរបស់ខ្លួន ធ្វើឱ្យប្រជាពលរដ្ឋដែលក្រីក្រស្រាប់ហើយនោះ ខាតបង់ទ្រព្យសម្បត្តិថែមទៀត។ ភ័ស្តុតាងក្នុងពេលនោះមួយទៀតគឺមានបុរសម្នាក់ដែលមានភ្នែកភ្លឺ ប៉ុន្តែគេជួលឱ្យក្លែងធ្វើជាខ្វាក់ដើម្បីឱ្យអាចារ្យគ្រិស្តធ្វើជាវេជ្ជបណ្ឌិតមើលភ្នែកដែលជាឱ្យជាដដែល។ ប្រជាពលរដ្ឋខ្មែរបានដឹងការពិតអំពីបោកប្រាស់នេះហើយ ទើបកើតការប្រឆាំងនេះឡើង។ នៅសម័យអាណានិគមបារាំងជិតមួយសតវត្សរ៍ បារាំងបានខំពន្យល់អូសទាញប្រពលរដ្ឋខ្មែរឱ្យចូលកាន់សាសនាគ្រិស្ត ប៉ុន្តែលទ្ធផលជាអវិជ្ជមានគឺប្រជា

ពលរដ្ឋពុំចូលកាន់សាសនាគ្រិស្តឡើយ បើមានក៏មានចំនួនតិចបំផុត។ បេសកជនសសនាគ្រិស្តបញ្ចុះបញ្ចូលបានជនជាតិខ្លះដែលស្ថិតនៅប្រទេសក្រីក្រ និងប្រទេសដែលមានវិបត្តិនយោបាយនៅទ្វីបអាស៊ី អាហ្វ្រិក និង អាមេរិកឡាទីនតាមរយៈការផ្តល់អំណោយមានចំណង។ បេសកជនសាសនាគ្រិស្តជាជាតិខ្មែរដែលចេញពីបរទេសទៅខំឃោសនាអួតក្អេងក្អាងថាពី១០ទៅ២០ឆ្នាំនឹងធ្វើឱ្យប្រទេសខ្មែរទៅជាប្រទេសកាន់គ្រិស្តសាសនាទាំងអស់។ ពួកវង្វេងបឹងទាំងនោះ មិនត្រឹមតែលើកតម្កើងសាសនារបស់ខ្លួនដើម្បីបញ្ចុះបញ្ចូលឱ្យពុទ្ធសាសនិកជនខ្មែរចូលកាន់គ្រិស្តសាសនាប៉ុណ្ណោះទេ ថែមទាំងពោលប្រមាថតិះដៀលព្រះពុទ្ធសាសនា និងព្រះសង្ឃជាទីគោរពរបស់ពុទ្ធសាសនិកជនខ្មែរថែមទៀតផង។ ដូចជាមានកន្លែងខ្លះ គេបង្ខំឱ្យជនជាតិខ្មែរ ដែលជឿគ្រិស្តសាសនាឱ្យជាន់ព្រះពុទ្ធរូបទើបគេជឿថាជឿគ្រិស្តសាសនាពិតមែន។

តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការជួយសង្គ្រោះមនុស្សសត្វត្រូវធ្វើឡើងប្រកបដោយមេត្តាធម៌ ដោយទឹកចិត្តបរិសុទ្ធ ពុំមានលក្ខខណ្ឌគឺមិនចង់បានប្រយោជន៍អ្វីពីអ្នកដែលខ្លួនជួយឡើយ។ បើការជួយនោះ ព្រោះតែចង់ទាញយកផលប្រយោជន៍អ្វីមួយមកវិញ នោះពុំឈ្មោះថាជួយប្រកបដោយករុណាធម៌ក្នុងនាមសង្គហធម៌តាមឧត្តមគតិព្រះពុទ្ធសាសនាឡើយ។ យ៉ាងណាមិញ ក្រុមផ្សាយសាសនាគ្រិស្តគួរតែធ្វើខ្លួនឱ្យថ្លៃថ្នូរជាជនមានអរិយធម៌ខ្ពស់ក្នុងនាមសាសនាគ្រិស្ត មិនគួរប្រើមធ្យោបាយបោកប្រាស់ប្រជាពលរដ្ឋខ្មែរដែលនៅទន់ខ្សោយដោយប្រាជ្ញាស្មារតីបែបនេះឡើយ។ ចូរពិចារ

ណាគ្រឿងឧបមាមួយថា អ្នកស្ទូចត្រីបោះសន្ទូចទៅក្នុងទឹក ពេលត្រីស៊ីនុយត្រីជាប់ង៉ៀងសន្ទូច គេក៏វ៉ាត់សន្ទូចឡើងសម្លាប់ត្រីយកមកធ្វើម្ហូប។ តើអ្នកស្ទូចត្រី ដែលដាក់នុយត្រង់ង៉ៀងសន្ទូចឱ្យត្រីវាស៊ីនោះ តើអ្នកនោះមានធម៌សប្បុរសធ្វើទានដល់ត្រី ឬជាការញ្ឆោតត្រីឱ្យត្រីវាស៊ីជាប់ង៉ៀងសន្ទូច គេក៏វ៉ាត់សន្ទូចឡើងសម្លាប់ត្រីយកមកធ្វើម្ហូបទេ ? ជាការពិតណាស់ ក្រុមផ្សាយសាសនាគ្រិស្តដែលចែកអំណោយដល់ខ្មែរ ហើយបង្ខំឱ្យគេជឿសាសនាខ្លួនមានលក្ខណៈដូចគ្នានឹងអ្នកស្ទូចត្រីនេះដែរ។ ដូច្នេះគេអាចទាញផលវិបាកមកថាអ្នកផ្សាយសាសនាគ្រិស្តកំពុងតែធ្វើសកម្មភាពសម្លាប់វប្បធម៌ដែលជាព្រលឹងរបស់ខ្មែរ គឺព្រះពុទ្ធសាសនាយ៉ាងពិតប្រាកដណាស់។ ក្រុមផ្សាយសាសនាគ្រិស្តត្រូវតែបញ្ឈប់សកម្មភាពរំលោភសិទ្ធិមនុស្សបែបនេះ ហើយបែរមកបំពេញសកម្មភាពមនុស្សធម៌ឱ្យត្រឹមត្រូវ ដូចអង្គការមនុស្សធម៌នានានៅប្រទេសកម្ពុជា។ បើអាណិតអាសូរប្រជាពលរដ្ឋខ្មែរ សូមទុកឱ្យកូនចៅខ្មែររក្សាជំនឿដើមរបស់ពួកគេ គឺព្រះពុទ្ធសាសនាដែលសព្វថ្ងៃនេះមាន៩៥%។ គួរយកតម្រាប់តាមតារាភាពយន្តហូលីវូត គឺនាង **អន់ជូលីណា ជូលី** ដែលបានសុំកូនកំព្រាខ្មែរម្នាក់មកចិញ្ចឹម។កូនប្រុសនេះមានអាយុ៣ឆ្នាំនៅឆ្នាំ២០០៤នេះ។ នាងឱ្យកូនប្រុសនោះរក្សាវប្បធម៌ដើម គឺព្រះពុទ្ធសាសនា ដោយបានជាវព្រះពុទ្ធរូបមួយអង្គពីកម្ពុជា ឱ្យកូនចិញ្ចឹមនោះថ្វាយបង្គំរាល់ពេល។ ចំពោះពុទ្ធសាសនិកជនខ្មែរនៅបរទេស ដែលបង្កើតវត្តអារាមគ្រប់ទីកន្លែងនោះ គ្មានបំណងផ្សាយសាសនារបស់ខ្លួនទៅជនបរទេសឡើយ គឺគ្រាន់តែរក្សាវប្បធម៌

ទំនៀមទម្លាប់ព្រះពុទ្ធសាសនារបស់ខ្លួនដែលធ្លាប់ប្រតិបត្តិមកឱ្យគង្វង់ប៉ុណ្ណោះ ប៉ុន្តែបើមានគេចង់ដឹង មានចិត្តរីករាយពន្យល់គេ ហើយគ្មានបំណងទាក់ទាញឱ្យគេជឿឡើយ។ ព្រះពុទ្ធខ្លួនព្រះអង្គបានពោលថា តថាគតទេសនាពន្យល់ធម៌ដល់អ្នករាល់គ្នា ប៉ុន្តែមុននឹងជឿតថាគត ចូរអ្នកពិចារណាឱ្យយល់ដោយខ្លួនឯងជាមុនសិន។ ដូច្នេះព្រះពុទ្ធសាសនាជាសាសនាពុំបង្ខំគេឱ្យជឿឡើយ តែជាសាសនាទុកសិទ្ធិឱ្យគេសម្រេចចិត្ត ជឿឬពុំជឿ ដោយខ្លួនគេ។

ចំពោះរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ការបើកសិទ្ធិខាងជំនឿជាការត្រឹមត្រូវហើយតាមច្បាប់អន្តរជាតិចំពោះប្រជាពលរដ្ឋខ្មែរ ដែលរស់នៅប្រទេសកម្ពុជាជាមាតុភូមិរបស់ខ្លួន ប៉ុន្តែបើមានជនបរទេសមកផ្សាយសាសនាគេនៅប្រទេសកម្ពុជាត្រូវស្ថិតនៅក្រោមច្បាប់មួយទៀត សម្រាប់ប្រទេសខ្មែរដែលជាប្រទេសទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ រដ្ឋាភិបាលត្រូវឧបត្ថម្ភនិងរក្សាការពារជំនឿរបស់ប្រជាពលរដ្ឋខ្មែរ។ ហួសពីនាទីរបស់ខ្លួន មានអង្គការមនុស្សធម៌ខ្លះពេលសុំច្បាប់ ប្រាប់អាជ្ញាធរខ្មែរថាខ្លួនមកជួយប្រជាពលរដ្ឋខ្មែរក្នុងនាមមនុស្សធម៌ ប៉ុន្តែនេះគ្រាន់តែជាផ្លាកខាងក្រៅភាពពិតខាងក្នុងគឺផ្សាយសាសនាគ្រិស្តរហូតទាក់ទាញយុវវ័យខ្មែរ ដែលជាវ័យនៅទន់ខ្សោយខាងប្រាជ្ញាស្មារតី ឱ្យបោះបង់ព្រះពុទ្ធសាសនាហើយកាន់គ្រិស្តសាសនាវិញថែមទាំងរិះគន់ព្រះសង្ឃពុទ្ធសាសនា ដែលជាស្ថាប័នដ៏ធំរបស់ប្រទេសកម្ពុជា និងមិនឱ្យដឹងគុណមាតាបិតា ដែលជាមូលដ្ឋានវប្បធម៌ខ្មែរ។ នេះជាភារកិច្ចរបស់រាជរដ្ឋាភិបាលខ្មែរដែលទទួលខុសត្រូវចំពោះវាសនាជាតិ ដែលមាននាទី

ការពារព្រះពុទ្ធសាសនារបស់រដ្ឋ ដែលជាបាវចនារបស់ជាតិមានចែងក្នុងធម្មនុញ្ញខ្មែរបច្ចុប្បន្ន ត្រូវចាត់វិធានការបែបណា ចំពោះអង្គការមនុស្សធម៌ខ្លះដែលធ្វើការហួសព្រំដែនរបស់ខ្លួនរំលោភច្បាប់ខ្មែរបែបនេះ។ គេសង្កេតឃើញការិយាល័យគ្រិស្តសាសនាមានស្ទើរតែគ្រប់កន្លែងនៅពាសពេញប្រទេសកម្ពុ-ជារហូតចុងកាត់មាត់ញកជនបទក៏មានដែរ នេះដោយសារអំពើពុករលួយរបស់អាជ្ញាធរខ្មែរចង់បានដុល្លារផ្ទាល់ខ្លួន និងចង់ចំណេញខាងផ្លូវនយោបាយដោយពុំគិតពីគំនិតជាតិនិយមរបស់ខ្លួន និងពុំគិតពីគ្រោះថ្នាក់ទៅអនាគតដែលអាចកើតសង្គ្រាមសាសនា។ ប៉ុន្តែស្មារតីដ៏ខ្ពង់ខ្ពស់របស់ប្រជាពលរដ្ឋខ្មែរចំពោះព្រះពុទ្ធសាសនាដែលជាព្រលឹងរបស់ខ្លួន មានភាពរឹងមាំពុំរង្គោះរង្គើឡើយ គឺពុំព្រមលក់ឧត្តមគតិឱ្យអ្នកណាទាំងអស់។ បានសេចក្តីថា គេឱ្យអំណោយទទួលយក ប៉ុន្តែរឿងមិនជឿគឺជាសិទ្ធិរបស់ខ្លួនជាប្រជាពលរដ្ឋខ្មែរឯករាជ្យ ចំពោះអំណោយដែលបង្កប់ពាក្យឃោសនានៅក្នុងនោះ។ ក្រុមផ្សាយសាសនាគ្រិស្តកុំយល់សប្តិថា ខ្លួនអាចធ្វើឱ្យប្រទេសកម្ពុជាដែលគោរពព្រះពុទ្ធសាសនាស្ទើរតែ១០០% ក្លាយជាប្រទេសកាន់គ្រិស្តសាសនាតាមការឃោសនារបស់ខ្លួនឡើយ ព្រោះប្រជាពលរដ្ឋខ្មែរសុខចិត្តក្រ មិនលក់ឧត្តមគតិខាងជំនឿនេះឱ្យជនណាឡើយ។ ភស្តុតាងឃើញស្រាប់ហើយ ពួកឃាតករខ្មែរក្រហមបានព្យាយាមរំលាយព្រះពុទ្ធសាសនាឱ្យដល់ឫសគល់ ឥឡូវនេះពុទ្ធសាសនាជាសច្ចធម៌ពុំស្លាប់នៅរស់ដដែល ហើយពួកបំផ្លាញព្រះពុទ្ធសាសនាត្រូវវិនាសខ្លួនឯង។ ដរាបណានៅមានខ្មែរ ដរាបនោះនៅមានព្រះពុទ្ធសាសនា

ព្រោះព្រះពុទ្ធសាសនាបានរលាយជាសាច់ជាឈាមនៅក្នុងខ្លួនរបស់ពួកគេអស់ទៅហើយ។ ដូច្នេះគ្រិស្តសាសនាកុំសាកល្បងដើរតួឱ្យពួកខ្មែរក្រុមរុយនិស្តខ្មែរក្រហមបន្តទៅទៀត ពិតជាពុំបានជោគជ័យឡើយ។ ជឿព្រះពុទ្ធសាសនាគឺជឿការពិតដែលព្រះអង្គបានសំដែង ហើយយកពាក្យនោះមកពិចារណា និងអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ពុំអាចប្រែក្រឡាស់ពីញាណទស្សនៈឃើញការពិតនេះទៅជឿអ្វីដែលពុំមានការពិតនោះឡើយ។ ចំពោះសាសនាឥស្លាមនៅប្រទេសកម្ពុជាសព្វថ្ងៃ មានវិហារឥស្លាមទាំងតូចទាំងធំមានចំនួនយ៉ាងច្រើន។ ការលូតលាស់របស់នេះ ដោយការឧបត្ថម្ភពីប្រទេសកាន់សាសនាឥស្លាមក្រៅប្រទេស។ ការសិក្សាពីសាសនាឥស្លាមរបស់ឥស្លាមសាសនិកមិនជាការអ្វីទេ ប៉ុន្តែមតិទូទៅមានការព្រួយបារម្ភនោះ គឺក្រែងពួកភេរវជនយកសាសនាឥស្លាមជាបង្អែកសម្រាប់សិក្សាអំពីល្បិចភេរវកម្ម និងការអនុវត្តភេរវកម្ម ដែលពេលថ្មីៗនេះតំណាង**អ.ស.ប.**បានថ្លែងថា កម្ពុជាអាចជាជំរកសុខសាន្តរបស់ក្រុមភេរវជន រាជរដ្ឋាភិបាលខ្មែរក៏យកចិត្តទុកដាក់បានធ្វើច្បាប់ផ្តន្ទាទោសពួកភេរវជនដែរ។

# **នាមអ្នកបរិច្ចាគបច្ច័យបោះពុម្ព**

១. ឧបាសក **ឡូ ប៊ុនឡេង** និង ឧបាសិកា **អៀប ផៃគីម**
ព្រមទាំងកូនចៅ $៤៥០
២. ឧបាសិកា **អៀប ផៃហុង** ព្រមទាំងកូនចៅ $១៥០
៣. ឧបាសិកា **លន់ អេង** $១០០
៤. ឧបាសិកា **សុខ សាមឿន** និង
ឧបាសិកា **តាន់ សម្បត្តិ** $១០០
៥. **ឃិន ឆេង** $១០០

សៀវភៅនេះចែកជាធម្មទាន ទូរស័ព្ទទំនាក់ទំនងៈ

ក. ព្រះភិក្ខុ **ទិប៊ុល** ០១១ ២២៥ ៥៤៧ និង
០១២ ៣១២ ៩០៨
ខ. ឧបាសិកា **សាមឿន** ០១២ ២២១ ៥០៥

---

រៀបរៀងដោយព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**